សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

## ការទទួលខុសត្រូវលើវិការៈទំនិញ

ស្រាវជ្រាវចាប់ពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ហាច្យ វរៈឥស្សរៈវច្យ**

**ខុយ គឹមហុង**

សាស្ត្រាចារ្យណែនាំ

**លោក ព្រុំ រិទ្ធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី១៨

ឆ្នាំចូលសិក្សា ២០១៤

ឆ្នាំសរសេរសារណា ២០១៨

# លិខិតថ្លែងអំណរគុណ

សូមគោរពប្រតិបត្តិដោយសេចក្តីកតញ្ញូតាធម៌

- នាងខ្ញុំឈ្មោះ វុយ គីមហុង និងខ្ញុំបាទឈ្មោះ ហង្ស វរៈឥស្សរៈវង្ស ជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី១៨ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា២០១៤-២០១៨។ ជាបឋម យើងខ្ញុំសូមថ្លែងអំណរគុណ និងសម្តែងនូវការដឹងគុណកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតចំពោះ៖

  លោកឪពុក វុយ ខ្វាត់ និង អ្នកម្តាយ ហាក់ ផន

  លោកឪពុក ហង្ស ច័ន្ទ វរៈ និង អ្នកម្តាយ សត្យា វុធចន្ទ្រា

- ពួកខ្ញុំជាកូន សូមថ្វាយបង្គំទៅកាន់លោកឪពុក អ្នកម្តាយទាំងពីរ ដោយសេចក្តីគោរព និងស្រលាញ់អស់ពីចិត្ត និងបេះដូង។ ការមើលថែរក្សាកូនៗ តាំងពីកំណើតរហូតដល់សព្វថ្ងៃនេះលោកទាំងពីរអង្គប្រាកដជាជួបការលំបាកជាច្រើនយ៉ាង។ លោកទាំងពីរបានចិញ្ចឹមបីបាច់ អប់រំទូន្មាន តាំងពីតូចរហូតដល់ធំ និងក្រេបយកចំនេះដឹងធ្វើអោយពួកយើងខ្ញុំក្លាយជាកូនល្អ ពលរដ្ឋល្អនៅក្នុងសង្គមនេះ។
- ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាការរង គណៈកម្មការ និងសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិស្រាស្ត និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំដឹកនាំ និងគ្រប់គ្រងផ្តល់ចំណេះដឹង ដំបូន្មាន ក៏ដូចជាបទពិសោធន៍ ដល់ពួកយើងខ្ញុំអស់រយៈពេល៤ ឆ្នាំមកនេះក្នុងគោលបំណងបណ្តុះបណ្តាលធនធានមនុស្សដើម្បី ក្លាយជាសសរទ្រូងប្រទេស។
- ជាពិសេស ពួកយើងខ្ញុំសូមលើកមម្រាមដៃដប់គោរពថ្លៃអំណរគុណចំពោះលោកសាស្ត្រាចារ្យ **ព្រុំ រិទ្ធី** ដែលបានចំណាយពេលដ៏មានតម្លៃ ទាំងកំលាំងកាយ នឹងកម្លាំងចិត្ត ក្នុងការណែនាំជួយសម្រួលលើកទឹកចិត្ត ត្រួសត្រាយផ្លូវ និងផ្តល់ចំណេះដឹង ដំបូន្មានល្អៗទៅកាន់ ពួកយើងខ្ញុំក្នុងការសរសេរសារណា ដើម្បីឲ្យកាន់តែមានភាពល្អប្រសើរនឹងងាយស្រួលហើយបញ្ចប់ដោយជោគជ័យ។
- ជាចុងក្រោយខ្ញុំសូមប្រសិទ្ធពរដល់លោកទាំងអស់គ្នាអោយជួបតែ ពុទ្ធិពរទាំងបួនប្រការ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាត និងជោគជ័យរាល់កិច្ចការទាំងឡាយ។

# អារម្ភកថា

ដោយយល់ឃើញថាប្រទេសកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍន៍ សេដ្ឋកិច្ចមានការចម្រើនលូតលាស់ជាហេតុធ្វើឱ្យមានការជួញដូរពាណិជ្ជកម្មក្នុង និងក្រៅប្រទេស ការជួញដូរទំនិញខ្លះខូចគុណភាព សំបូរដោយជាតិគីមីប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ ទទួលរងការខូចខាត និងប៉ះពាល់ដល់ប្រយោជន៍ក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ។ បានជាយើងខ្ញុំធ្វើការសិក្សាស្រាវជ្រាវប្រធានមួយនេះដោយយល់ឃើញថាទំនិញមានសារធាតុគីមីបានធ្វើឱ្យខូចខាតដល់ផលប្រយោជន៍អ្នកប្រើប្រាស់ ហេតុដូចនេះហើយផលិតករ និងអ្នកលក់ទំនិញនោះត្រូវតែទទួលខុសត្រូវចំពោះភាគីដែលបានរងគ្រោះ និងសងសំណងនៃការខូចខាត។

ម្យ៉ាងទៀតមូលហេតុដែលជំរុញឱ្យយើងខ្ញុំបានជ្រើសរើសយកប្រធានបទស្តីពី **"ការទទួលខុសត្រូវលើវិការៈទំនិញ"** គឺដើម្បីទុកឯកសារនេះជាជំនួយផ្នែកស្មារតីសម្រាប់និស្សិតទាំងឡាយដែលមានបំណងសិក្សាស្រាវជ្រាវ និងចង់ដឹងអំពីការទទួលខុសត្រូវទៅលើទំនិញដែលមានវិការៈ។ ប្រធានបទនេះផ្តល់ជាមូលដ្ឋាននៃចំណេះដឹងមួយផ្នែក ដើម្បីស្វែងយល់អំពីការទទួលខុសត្រូវដោយតាមកិច្ចសន្យា និងដោយតាមអំពើអនីត្យានុកូល ការកំណត់អំពីសំណងដែលត្រូវបានសង នីតិវិធីក្នុងការទប់ស្កាត់ហាមឃាត់កុំឱ្យមានការនាំចូលទំនិញខុសច្បាប់ និងទណ្ឌកម្មចំពោះអ្នកប្រព្រឹត្តិ។ ក្នុងការសិក្សាស្រាវជ្រាវមួយនេះ ទោះបីជាមានការលំបាក និងចំណាយពេលវេលាជាច្រើនក្នុងការស្រាវជ្រាវក្តី ក៏យើងខ្ញុំមិនដែលគិតថាបោះបង់ចោល ដោយកាន់តែខិតខំស្វះស្វែងរកប្រភពឯកសារ និងច្បាប់នានាដែលពាក់ព័ន្ធយកមកធ្វើការសិក្សាស្រាវជ្រាវ។ យើងខ្ញុំសង្ឃឹមថាស្នាដៃមួយនេះនឹងក្លាយជាឯកសារជំនួយស្មារតី និងឯកសារពិគ្រោះសម្រាប់អស់លោក លោកស្រី មិត្តនិស្សិត និងអ្នកសិក្សាជំនាន់ក្រោយ ទុកជាឯកសារស្រាវជ្រាវបន្ត។

ជាទីបញ្ចប់យើងខ្ញុំសុំអធ្យាស្រ័យទុកជាមុន ប្រសិនបើមានកំហុសខុសឆ្គងដោយអចេតនាណាមួយទោះបីជាមានការខិតខំប្រឹងប្រែងក្នុងការស្រាវជ្រាវ ដើម្បីឱ្យកិច្ចការនោះល្អយ៉ាងណាក៏ដោយ យើងខ្ញុំជឿជាក់ថាកំហុសដោយអចេតនានឹងកើតមានឡើង និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការយកចិត្តទុកដាក់ក្នុងការអាន និងសិក្សាស្រាវជ្រាវ។

# មាតិកា


**ទំព័រ**

**សេចក្តីផ្តើម ........................................................................................................ ១**

**ជំពូកទី១**

**ការទទួលខុសត្រូវលើអំពើអនីត្យានុកូលនៃផលិតផលទំនិញ**

**ផ្នែកទី១៖ សញ្ញាណទូទៅនៃអំពើអនីត្យានុកូល ........................................................ ៣**

**កថាខណ្ឌ១៖ ទស្សនៈរបស់ច្បាប់ចំពោះអនីត្យានុកូល ............................................ ៥**

១.ការធ្វើបដិទានចំពោះការខូចខាត ................................................................ ៥

២.ទណ្ឌកម្មចំពោះចារីនៃអំពើអនីត្យានុកូល ...................................................... ៦

៣.ការទប់ស្កាត់ការខូចខាត ............................................................................ ៦

**កថាខណ្ឌ២៖ លក្ខខណ្ឌនៃការទទួលខុសត្រូវ .......................................................... ៧**

១.ប្រភេទនៃព្យសនកម្ម ឬការខូចខាត ........................................................... ៧

១.១.ព្យសនកម្ម ផ្នែករូបកាយ .............................................................................. ៧

១.២.ព្យសនកម្ម ផ្នែកសម្ភារៈ ............................................................................ ៧

១.៣.ព្យសនកម្ម ផ្នែកផ្លូវចិត្ត ............................................................................. ៧

២.ទំនាក់ទំនងហេតុនិងផល .............................................................................. ៨

៣.កំហុស ............................................................................................................. ៩

៣.១.កំហុសចេតនា ................................................................................................ ៩

៣.២.កំហុសអចេតនា ............................................................................................ ៩

**ផ្នែកទី២៖ ការទទួលខុសត្រូវនៃអំពើអនីត្យានុកូល ................................................. ១០**

**កថាខណ្ឌ១៖ការទទួលខុសត្រូវលើផលិតផល ............................................................ ១០**

១.ផលិតផលរបស់បុគ្គលជាផលិតករ ................................................................ ១០

២.វត្ថុមានគ្រោះថ្នាក់ ......................................................................................... ១១

**កថាខណ្ឌ២៖ ការរួចផុតពីរការទទួលខុសត្រូវនៃលើអំពើអនីត្យានុកូល.១២**

១.ផលិតផលរបស់បុគ្គលជាផលិតករ ................................................................ ១២

២.វត្ថុមានគ្រោះថ្នាក់ ......................................................................................... ១៣

**កថាខណ្ឌ៣៖ ការគណនាសំណង .......................................................................... ១៣**

## ជំពូកទី២

## វិធានការទទួលខុសត្រូវតាមកិច្ចសន្យា


**ផ្នែកទី១៖ ការទទួលខុសត្រូវលើវត្ថុមានវិការៈ ........ ១៦**

**កថាខណ្ឌ១៖ ការទទួលត្រូវក្នុងការធានាលើវត្ថុមានវិការៈ........ ១៦**

១.បញ្ញាត្តិទូទៅ........ ១៨

**កថាខណ្ឌ២៖ ការទទួលត្រូវក្នុងកិច្ចសន្យាដឹកជញ្ជូន........ ១៩**

១.ការទទួលខុសត្រូវរបស់អ្នកដឹកជញ្ជូនទំនិញ........ ១៩

២.ការទទួលត្រូវរបស់អ្នកបញ្ជូន និងអ្នកទទួល........ ២០

**ផ្នែកទី២៖ វិធានការនៃការសងសំណង........ ២១**

**កថាខណ្ឌ១៖ សំណងនៃការខូចខាត........ ២២**

១.លក្ខខណ្ឌទូទៅ........ ២២

២.ទំហំនៃសំណងនៃការខូចខាត........ ២៣

៣.អាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយកិច្ចសន្យា........ ២៣

**ផ្នែកទី៣៖ នីតិវិធីក្នុងការប្តឹងទាមទារ........ ២៤**

**កថាខណ្ឌ១៖ សមត្ថកិច្ចតុលាការ........ ២៤**

**កថាខណ្ឌ២៖ ការគណនាសំណងនៃការខូចខាត........ ២៥**

១.សំណងនៃការខូចខាតផ្នែកសម្ភារៈ........ ២៥

១.១.ការខូចខាតទាំងអស់ដែលជាបន្ទុករបស់ម្ចាស់បំណុល........ ២៥

១.២.សំណងនៃការខូតខាតដែលម្ចាស់បំណុលអាចទាមទារបាន........ ២៦

១.៣.ការគណនាផលប្រយោជន៍........ ២៦

១.៣.១. ការគណនាតម្លៃនៃកម្មវត្ថុដែលបាត់បង់........ ២៦

១.៣.២. ការគណនាតម្លៃនៃការប្រើប្រាស់ដែលបានបាត់បង់........ ២៧

២.ការខូចខាតផ្លូវចិត្ត........ ២៧

**កថាខណ្ឌ៣៖ ការចាប់បង្ខំ និងអនុភាព........ ២៨**

១.ប្រភេទ នៃការអនុវត្តដោយបង្ខំ........ ២៨

១.១.ការអនុវត្តដោយផ្ទាល់ ........................................ ២៨
១.២.ការអនុវត្តជំនួស ........................................ ២៩
១.៣.វិធានបង្ខំដោយប្រយោជន៍ ........................................ ២៩

**ជំពូកទី៣**

**ការទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌទៅលើទំនិញដែលខូចគុណភាព**

**ផ្នែកទី១៖ ការបន្លំការក្លែងបន្លំ** ........................................ ៣០
**កថាខណ្ឌ១៖ គោលបំណង** ........................................ ៣០
**កថាខណ្ឌ២៖ មូលហេតុ** ........................................ ៣១
**កថាខណ្ឌ៣៖ យន្តការក្នុងការបន្លំ** ........................................ ៣២
**ផ្នែកទី២៖ នីតិវិធីនៃការត្រួតពិនិត្យគុណភាពលើផលិតផលទំនិញ** ........................................ ៣៤
**កថាខណ្ឌ១៖ ការត្រួតពិនិត្យលើទំនិញ** ........................................ ៣៤
**កថាខណ្ឌ២៖ តួនាទីរបស់ភ្នាក់ងារត្រួតពិនិត្យទំនិញ** ........................................ ៣៨
**ផ្នែកទី៣៖ ការដាក់ទណ្ឌកម្មចំពោះជនល្មើស** ........................................ ៤០
**កថាខណ្ឌ១៖ ការពិន័យជាប្រាក់** ........................................ ៤០
**កថាខណ្ឌ២៖ ការបង្ខំលើរូបរាងកាយ** ........................................ ៤២
**សេចក្តីសន្និដ្ឋាន** ........................................ ៤៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

ដើម្បីអាចគ្រប់គ្រងប្រទេសជាតិមួយឱ្យមានរបៀបរៀបរយ និងសណ្តាប់ធ្នាប់ល្អ គ្រប់បណ្តារដ្ឋទាំងអស់បានព្យាយាមបង្កើតនូវគោលការណ៍ថ្មីៗ ជាច្រើនដើម្បីគ្រប់គ្រងលើបាតុភូតសង្គមដែលតែងតែវិវឌ្ឍន៍ឥតឈប់ឈរដែលបានបង្កបញ្ហាជាច្រើននៅក្នុងសង្គម។ កត្តាទាំងនេះជាហេតុដែលបង្កឱ្យមានការរាំងស្ទះដល់ដំណើរការអភិវឌ្ឍន៍នៃសង្គមជាតិ ដែលជាហេតុនាំឱ្យមានការបង្កើតច្បាប់បន្ថែម និងការធ្វើវិសោធនកម្មច្បាប់ជាបន្តបន្ទាប់។ ជាធម្មតាសេដ្ឋកិច្ចរបស់ជាតិមួយ ជាកត្តាសំខាន់សម្រាប់ជំរុញដល់ដំណើរការក្នុងការអភិវឌ្ឍន៍ប្រទេសឱ្យកាន់តែរីកចម្រើនទៅមុខ។ បើនិយាយពីសេដ្ឋកិច្ចក៏ពុំត្រូវមើលរំលងទៅលើវិស័យពាណិជ្ជកម្មនោះទេ ព្រោះពាណិជ្ជកម្មជាវិស័យមួយដ៏សំខាន់សម្រាប់ជំរុញឱ្យសេដ្ឋកិច្ចនៃប្រទេសមួយរីកចម្រើនទៅមុខបាន មិនថាចំពោះប្រទេសអភិវឌ្ឍន៍ ឬប្រទេសកំពុងអភិវឌ្ឍន៍ឡើយ។

ប្រទេសទាំងនោះសុទ្ធតែមានសកម្មភាពពាណិជ្ជកម្មទាំងក្នុង និងក្រៅប្រទេស ក្រៅពីការធ្វើជំនួញក្នុងស្រុក ប្រទេសនីមួយៗតែងតែខិតខំស្វះស្វែងរកដៃគូរទំនាក់ទំនងពីប្រទេសខាងក្រៅក្នុងការដោះដូរទំនិញនានា ដើម្បីបំពេញតម្រូវការចាំបាច់ក្នុងការបង្កើនផលិតផលនៃជំនួញរបស់ខ្លួន។ ចំណែកឯប្រទេសកម្ពុជាវិញ គឺជាប្រទេសកំពុងអភិវឌ្ឍន៍មួយនៅក្នុងទ្វីបអាស៊ីអាគ្នេយ៍។ សេដ្ឋកិច្ចកម្ពុជាក៏មានភាពជឿនលឿន និងរីកចម្រើនជាលំដាប់ក្រោមការដឹកនាំយ៉ាងយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាភិបាល។ ក្នុងនោះក៏មានការបើកទូលាយឱ្យឈ្មួញមានការនាំចេញនាំចូលទំនិញក្នុង និងក្រៅប្រទេសដើម្បីធ្វើអាជីវកម្ម ប៉ុន្តែដោយសារតែតម្រូវការចាំបាច់របស់មនុស្សវិវឌ្ឍន៍ឥតឈប់ឈរ សម្រាប់ជីវភាពរស់ប្រចាំថ្ងៃ ដូចជាវត្ថុសម្រាប់ប្រើប្រាស់ រួមទាំងចំណីអាហារ ដើម្បីបរិភោគជារៀងរាល់ថ្ងៃ។ ទាំងនេះជាហេតុនាំឱ្យមានការនាំចូលទំនិញយ៉ាងច្រើនសន្ធឹកសន្ធាប់ចូលមកក្នុងប្រទេសកម្ពុជា ប៉ុន្តែក្នុងចំណោមការនាំចូលទាំងនោះ ក៏មាននាំចូលនូវទំនិញក្លែងក្លាយរួមទាំង ទំនិញមានសារធាតុគីមីលើសកម្រិតសុវត្ថិភាព ទំនិញខូចគុណភាព និងទំនិញផុតកាលកំណត់ប្រើប្រាស់ដែលជាហេតុ នាំឱ្យប៉ះពាល់ដល់សុខភាពពលរដ្ឋនៅក្នុងប្រទេស។ ជាពិសេសប្រភេទអាហារបរិភោគដែលមានសារធាតុគីមីទាំងនោះដូចជាចំណីអាហារត្រីសាច់ បន្លែ បង្គា រួមទាំង ឱសថ គ្រឿងសំអាង និងគ្រឿងឧបភោគបរិភោគដែលហួសរយៈពេលប្រើប្រាស់ជាដើម។

នៅពេលដែលពលរដ្ឋប្រើប្រាស់ផលិតផលដែលគ្មានគុណភាព វានឹងបង្កឱ្យមានបញ្ហា និងការខាតបង់ជាច្រើនដូចជា ការខាតបង់ពេលវេលា ទ្រព្យសម្បត្តិ ជាពិសេសគឺ សុខភាព។ ដោយយល់ឃើញអំពីបញ្ហាទាំងអស់នេះដែលកំពុងតែជះឥទ្ធិពលអាក្រក់ដល់សេដ្ឋកិច្ច និងខូចផល

ប្រយោជន៍ប្រជាពលរដ្ឋយ៉ាងខ្លាំង ទើបលើកយកប្រធានបទ **"ការទទួលខុសត្រូវលើវិការៈទំនិញ"** មកធ្វើការសិក្សាស្រាវជាវឱ្យកាន់តែច្បាស់អំពីបញ្ហា និងស្វែងរកដំណោះស្រាយ ដើម្បី ទប់ស្កាត់ការនាំចូលទំនិញគ្មានគុណភាព រួមទាំងសិទ្ធិទាមទារសំណងដែលជនរងគ្រោះអាចធ្វើបាន និងទណ្ឌកម្មផ្នែកព្រហទណ្ឌចំពោះចារីដែលប្រព្រឹត្តិល្មើស តាមច្បាប់ស្ដីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពទំនិញ និងសេវា និងការទទួលខុសត្រូវតាមកិច្ចសន្យា និងអំពើអនីត្យានុកូលដែលមានចែងក្នុងក្រមរដ្ឋប្បវេណី។

នៅក្នុងខ្លឹមសារនៃប្រធានបទទាំងមូលដែល ចង់សិក្សាស៊ីជម្រៅអំពីការទទួលខុសត្រូវទៅលើវិការៈនៃទំនិញ។ ដោយក្នុងការសិក្សាស្រាវជ្រាវចែកចេញជាបីជំពូក ដោយជំពូកទី១ ការទទួលខុសត្រូវលើអំពើអនីត្យានុកូលនៃផលិតផលទំនិញ ជំពូកទី២ វិធានការទទួលខុសតាមកិច្ចសន្យា និងជំពូកទី៣ ការទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌទៅលើទំនិញដែលខូចគុណភាព។

# ជំពូកទី១

# ការទទួលខុសត្រូវលើអំពើអនីត្យានីកូលនៃ
# ផលិតផលទំនិញ

# ជំពូកទី១៖ ការទទួលខុសត្រូវលើអំពើអនីត្យានុកូលនៃផលិតផលទំនិញ

ការទទួលខុសត្រូវ គឺសិក្សាជាដំបូងទៅលើសញ្ញាណ និងលក្ខខណ្ឌទូទៅ មុននឹងឈានទៅរកគន្លឹះ នៃការដោះស្រាយបញ្ហាទាក់ទងទៅនឹងការទទួលខុសត្រូវ លើអំពើអនីត្យានុកូលនៃផលិតផលទំនិញ ។ វាក៏ជាគន្លឹះនៃការដោះស្រាយនូវរាល់បញ្ហា ដែលបានកើតឡើងដោយគ្មានការព្រមព្រៀង ឬរវាងភាគីដែលពុំធ្លាប់មានទំនាក់ទំនងគតិយុត្តជាមួយគ្នាពីមុនមក ដែលអាចជាទំនាក់ទំនងនៃកិច្ចសន្យាជាដើម ដោយភាគីម្ខាងបានប្រព្រឹត្តិអំពើមួយដែលបង្ក ឲ្យមានការខូចខាតដល់ភាគីម្ខាងទៀត ដែលបានកំណត់ថារាល់អំពើដែលបានកើតឡើងក្រៅការព្រមព្រៀងបែបនេះ ថាតើជនណាជាអ្នកទទួលខុសត្រូវ? តើសំណងបែបណាដែលជនរងគ្រោះអាចទទួលបានពីអំពើអនីត្យានុកូល ?

ការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល ត្រូវបានទទួលស្គាល់ថា ជាការទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាត រវាងភាគីដែលពុំមានទំនាក់ទំនងគតិយុត្តជាមុន ។ ចំពោះសំណងនៃការខូចខាត ដោយការមិនអនុវត្តកិច្ចសន្យារវាងភាគីនៃកិច្ចសន្យាវិញ មានបញ្ញត្តិផ្សេងពីអំពើអនីត្យានុកូល ដែលចែងអំពីការទទួលខុសត្រូវ ក្នុងការបញ្ជាក់អំពីកំហុសអំឡុងពេល នៃអាជ្ញាយុកាលជាដើម ដោយគិតដល់លក្ខណៈពិសេសនៃទំនាក់ទំនងនៃកិច្ចសន្យា ដូច្នេះតាមទស្សនៈ បញ្ញត្តិនៃអំពើអនីត្យានុកូលមិនអាចយកមកអនុវត្តចំពោះភាគីនៃកិច្ចសន្យាឡើយ ។ ដែលវាគឺជាការផ្ដើមឲ្យបានយល់អំពីភាពខុសគ្នារវាងការទទួលខុសត្រូវដែលកើតចេញពីកិច្ចសន្យា និងការទទួលខុសត្រូវ ដែរបានកើតចេញអំពីការដែលមិនបានព្រាងទុក ឬការទទួលខុសត្រូវដែលបានបង្កមកពីបុគ្គល តែម្ខាងដែលបានធ្វើអោយខូចខាតផល់ប្រយោជន៍របស់បុគ្គលម្ខាងទៀត ។

## ផ្នែកទី១៖ សញ្ញាណទូទៅនៃអំពើអនីត្យានុកូល

តើសញ្ញាណនៃកាទទួលខុសត្រូវលើអំពើអនីត្យានុកូលគឺជាអ្វី?

ការទទួលខុសត្រូវលើអំពើអនីត្យានុកូល វាគឺជាការទទួលខុសត្រូវទៅលើអំពើដែលធ្វើឡើងហើយបានធ្វើអោយខូចខាតដល់ទ្រព្យសម្បត្តិរបស់អ្នកដទៃ ដោយចេតនា ឬដោយកំហុសអចេតនាក្តីនេះបើយោងទៅតាមមាត្រា៧៤២ នៃក្រមរប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ។ ករណីបែបនេះ ជាហេតុធ្វើអោយមានការសងនូវសំណងនៃការខូចខាត ការសងសំណងជំងឺចិត្ត ដល់ជនរងគ្រោះ ដែលវាជាកាតព្វកិច្ចរបស់អ្នកដែលបានប្រព្រឹត្ត ជនល្មើសក៏ត្រូវធ្វើការសង និងទទួលខុសត្រូវចំពោះអ្វី ដែល

មិនមែនជាទ្រព្យសម្បត្តិរបស់ជនរងគ្រោះផងដែរនេះបើយោងតាម មាត្រា ៧៤៥ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ។

អ្នកដែលមានសមត្ថកិច្ចត្រួតពិនិត្យអសមត្ថជន ក៏ត្រូវបានចាត់ទុកថាជាអ្នកមានសមត្ថកិច្ចក្នុងការទទួលខុសត្រូវនូវសំណងនៃការខូចខាតចំពោះទង្វើដែលបានបង្ករបស់អសមត្ថជន ឬជនដែលគ្មានសមត្ថភាពក្នុងការទទួលខុសត្រូវ ។ ឯនីតិបុគ្គលក៏ត្រូវទទួលខុសត្រូវចំពោះសំណងនៃការខូចខាតដែរ ចំពោះអំពើដែលបង្កអោយមានការខូចខាតរបស់អភិបាលនៃនីតិបុគ្គលនោះ ចំណែករដ្ឋ ឬស្ថាប័នសាធារណៈ ក៏មានភារកិច្ចទទួលខុសត្រូវនូវសំណាងនៃការខូចខាត ចំពោះទង្វើដែលបង្កអោយមានការខូចខាតពីសំណាក់មន្ត្រីរាជការផងដែរ ។[1] ហើយអ្នកដែលមានសត្វចិញ្ចឹមក៏ត្រូវទទួលខុសត្រូវនូវការសងសំណងនៃការខូចខាតដែលបង្កមកពីសត្វចិញ្ចឹមរបស់ខ្លួនផងដែរ ។[2]

ម្យ៉ាងទៀត ក៏មានករណីពិសេស ដែលបានទទួលស្គាល់អំពីការទទួលខុសត្រូវ ដែលវាជាការទទួលខុសត្រូវ ចំពោះការខូចខាតបណ្តាលមកពីវត្ថុមានគ្រោះថ្នាក់ ដោយវាមិនចាំបាច់ត្រូវមានលក្ខខណ្ឌកំហុស ។[3] ដូចជាក្នុងសង្គមជាតិបច្ចុប្បន្ន បានទទួលហានិភ័យច្រើនបែបច្រើនយ៉ាងដែលកើតឡើងដោយសារការជឿនលឿននៃបច្ចេកវិជ្ជារបស់វិទ្យាសាស្ត្រទំនើបថ្មីៗ។ ដូចបានឃើញស្រាប់ទាក់ទងទៅនឹងគ្រោះថ្នាក់បង្កមកពីរោងចក្រ គ្រោះថ្នាក់បណ្តាលមកពីថ្នាំពេទ្យគ្មានគុណភាព ធ្វើឲ្យខូចបរិស្ថានដោយសារធាតុគីមី គ្រោះថ្នាក់ដោយសារតែរបស់សម្រាប់បរិភោគ ដូចជា ត្រី សាច់ បន្លែ ផ្លែឈើជាដើម ដែលបានដាក់ថ្នាំគីមីសម្រាប់ធ្វើអោយវត្ថុទាំងនោះ រក្សាទុកបានយូរ និងនៅស្រស់ដូចថ្មី ព្រមទាំងការចាក់ថ្នាំឲ្យឆាប់ធំ ចំពោះបន្លែផ្លែឈើផងដែរ ។ វាក៏បានកើតឡើងរួចហើយដែរ ប៉ុន្តែចំពោះករណីបែបនេះ ពិតជាពិបាកដោះស្រាយ ព្រោះសព្វថ្ងៃវាមានករណីនេះ កើតឡើងតែមិនអាចដោះស្រាយបាន ដោយសារតែការខូចខាត មិនមែន ជាការខូចខាតផ្នែកសម្ភារៈ ឬទ្រព្យសម្បត្តិឡើយ ។ ករណីបែបនេះ វាពិបាកក្នុងការបង្ហាញអំពីទំនាក់ទំនងហេតុផលរវាងគ្រោះថ្នាក់ និងលទ្ធផលដែលបានកើតឡើង តាមផ្លូវបច្ចេកទេស ម៉្យាងទៀតវាពិតជាពិបាកក្នុងការគណនានូវសំណាងនៃការខូចខាចបង្កពីបញ្ហាសារធាតុគីមីនេះ ។[4]

---

[1] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី( ភ្នំពេញៈក្រសួងយុត្តិធម៌,២០១០), ៣៖១៨០។

[2] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៧៥២(ពីពេលនេះទៅហៅថា ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧)។

[3] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី( ភ្នំពេញៈក្រសួងយុត្តិធម៌,២០១០), ៣៖១៨០។

[4] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី( ភ្នំពេញៈក្រសួងយុត្តិធម៌,២០១០), ៣៖១៨០។

ក្នុងករណីដូចបានរៀបរាប់ខាងលើ ជនរងគ្រោះអាចទាមទារសំណងការខូចខាត ដែលខ្លួនទទួលរងពីចារីបានតាមមាត្រា ៧៤៣ នៃក្រមរដ្ឋប្បវេណី ។ មានន័យថា ជនរងគ្រោះដោយអំពើអនីត្យានុកូលធ្វើលទ្ធកម្មនូវសិទ្ធិលើបំណុលនៃសំណងការខូចខាតចំពោះចារី ។ បើមើលពីទស្សនៈម្ខាងទៀត ចារីត្រូវសងសំណងការខូចខាតដែលកើតមានឡើងនោះទៅជនរងគ្រោះ ។ មានន័យថាចារីមានកាតព្វកិច្ចសងការខូចខាតចំពោះជនរងគ្រោះ ។ ករណីបែបនេះ គឺជាការកើតឡើងនូវទំនាក់ទំនងនៃសិទ្ធិលើបំណុល និងកាតព្វកិច្ចដោយសារអំពើអនីត្យានុកូល។[5]

ភាគី"**ក**"គឺជាឱសថការីម្នាក់ ដែលភាគី"**ក**"បានធ្វើការលក់នូវថ្នាំ ដែលបានយកពីភាគី"**ខ**" ជាអ្នកនាំចូលទៅឲ្យភាគី"**គ**"ដោយថ្នាំនោះគឺជាថ្នាំគ្មានគុណភាព ក្រោយពេលលេបថ្នាំនោះរួច ភាគី"**គ**"ក៏ទទួលរងនូវគ្រោះថ្នាក់ ដោយរលាកក្រពះបណ្តាលមកពីឥទ្ធិពលនៃថ្នាំនោះ ។

យោងទៅតាមករណីខាងលើ បានឲ្យឃើញថា វាសុទ្ធសឹងតែជាអំពើដែលធ្វើឲ្យមានការខូតខាតកើតឡើង ។ ម្យ៉ាងវិញទៀត វាមិនមែនជាការខូចខាតបណ្តាលមកពីការមិនបានអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យាឡើយ ។ វាគឺជាការខូចខាតបណ្តាលមកពីអំពើ ដែលខ្វះខាតនូវការប្រុងប្រយ័ត្ន ក៏ដូចជាវត្ថុមានសារធាតុគីមីជាដើម ដែលវាពិបាកក្នុងការសម្រេចនូវការទទួលខុសត្រូវ រួមទាំងពិបាកក្នុងការគណនាសំណងដែលជនរងគ្រោះត្រូវទទួលបាន ។

### កថាខណ្ឌ១៖ ទស្សនៈរបស់ច្បាប់ចំពោះអំពើអនីត្យានុកូល

តើរបបសំណងការខូចខាតដោយសារអំពើអនីត្យានុកូល ដើរតួរនាទីក្នុងសង្គមត្រឹមកម្រិតណា ? ដោយជាទូទៅសំណងនៃការខូតខាតដោយសារអំពើអនីត្យានុកូល វាមានមុខងារ ៣ យ៉ាងដែលច្បាប់បានកំណត់។

#### ១.ការធ្វើបដិទានចំពោះការខូចខាត

តាមរយៈរបបអំពើអនីត្យានុកូលការខូចខាត ដែលជនរងគ្រោះបានទទួលរងអាចត្រូវបានធ្វើបដិទាន ។ រវាងជនរងគ្រោះ ដែលទទួលរងនូវការខូចខាត និងចារីដែលបង្កឲ្យមានខូចខាតដោយសារអំពើអនីត្យានុកូលជារបបដាក់បន្ទុកទទួលខុសត្រូវទៅលើចារី ចំពោះការខូចខាត ដែលបានកើតឡើង ។ ជាធម្មតាសកម្មភាពរបស់ចារី គឺជាមូលហេតុនៃការកើតឡើង នូវការខូចខាតដល់អ្នកដទៃ

[5] ណូមូរ៉ា តូយ៉ូហ៊ីរ៉ូ,សេចក្តីផ្តើមនីតិរដ្ឋប្បវេណី (ភ្នំពេញ, ២០១១),៥៖១០០។

អាចនិយាយបានថា ការដាក់ឲ្យចារីទទួលកាតព្វកិច្ចសងការខូចខាត គឺមានភាពយុត្តិធម៌ណាស់សម្រាប់គូភាគី។[6]

### ២.ទណ្ឌកម្មចំពោះចារីនៃអំពើអនីត្យានុកូល

របបអំពើអនីត្យានុកូល មានន័យថាជាទណ្ឌកម្មចំពោះចារីនៃអំពើអនីត្យានុកូល ។ នាសម័យដើមមិនមានការបែងចែកច្បាស់លាស់រវាងច្បាប់រដ្ឋប្បវេណី និងច្បាប់ព្រហ្មទណ្ឌទេ ។ នៅក្នុងក្រមហាម៉ុរ៉ាប៊ី (Hammurabi) របស់អរិយធម៌មេសូប៉ូតាមៀ (Mesopotamia) និងច្បាប់មូលដ្ឋានទាំង១២របស់រ៉ូម៉ាំងជាដើម មានបទដ្ឋានដែលចែងថា "ភ្នែកសងភ្នែក ធ្មេញសងធ្មេញ"។[7] បទដ្ឋានបែបនោះ (ភាសាឡាតាំងហៅថាTalio) គឺមានន័យថាយុត្តិធម៌ត្រូវបានផ្តល់ឲ្យនៅពេលដែលមានការផ្តល់ការខូចខាតដល់ចារីវិញ ដូចគ្នាទៅនឹងការខូចខាតដែលជនរងគ្រោះបានទទួលរង(ដោយអនុលោមតាមរបបអំពើអនីត្យានុកូលនេះ កម្រិតនៃការសងសឹកនឹងត្រូវបានរឹតបន្តឹង) ។ របបអំពើអនីត្យានុកូលដែលមានន័យជាទណ្ឌកម្មនេះមានន័យដូចគ្នាទៅនឹងការដាក់ទណ្ឌកម្ម(ការដាក់ទោសទណ្ឌ)ចំពោះជនដែលបានប្រព្រឹត្តអំពើអាក្រក់ និងធ្វើអោយជនរងគ្រោះបានស្កប់ចិត្ត (បដិទាននូវការខូចខាត) ។ នៅពេលដែលសម័យកាលបានផ្លាស់ប្តូរ បើទោះច្បាប់រដ្ឋប្បវេណី និងព្រហ្មទណ្ឌបាន ត្រូវបែងចែកដាច់ពីគ្នាក៏ដោយ ក៏សំណងការខូចខាតនៅតែមានអត្ថន័យជាទណ្ឌកម្មប្រឆាំងនឹងចារី ដែលបង្កការខូចខាតដែរ ។

### ៣.ការទប់ស្កាត់ការខូចខាត

របបអំពើអនីត្យានុកូលត្រូវបានចាត់ទុកថា មានតួនាទីទប់ស្កាត់ចំពោះការខូចខាត មានន័យថាជនបានបង្កឲ្យមានការខូចខាតកើតឡើងចំពោះជនដទៃ ដោយចេតនា ឬកំហុសរបស់ខ្លួនត្រូវរ៉ាប់រងកាតព្វកិច្ចសងការខូចខាត ចំពោះជនរងគ្រោះដែលទទួលរងការខូចខាត។

ដូច្នេះ ដើម្បីជៀសវាងការទទួលកាតព្វកិច្ចសងការខូចខាតជាទូទៅ ត្រូវមានការប្រុងប្រយ័ត្នខ្ពស់ចំពោះរាល់សកម្មភាពរបស់ខ្លួន ដើម្បីកុំឲ្យមានការខូចខាតដោយកំហុសនៃក្រមរដ្ឋប្បវេណី ។ ក្នុងករណីដែលចារីគ្មានចេតនានិងគ្មានកំហុស គឺមិនទទួលកាតព្វកិច្ចសងការខូចខាតទេ ។ ជាលទ្ធផលការខូចខាតនឹងត្រូវបានទប់ស្កាត់ ។[8]

---

[6] ណូមូរ៉ា តូយ៉ូហ៊ីរ៉ូ,សេចក្តីផ្តើមនីតិរដ្ឋប្បវេណី (ភ្នំពេញ, ២០១១),៥៖១០១។
[7] ណូមូរ៉ា តូយ៉ូហ៊ីរ៉ូ,សេចក្តីផ្តើមនីតិរដ្ឋប្បវេណី (ភ្នំពេញ, ២០១១),៥៖១០១។
[8] ណូមូរ៉ា តូយ៉ូហ៊ីរ៉ូ,សេចក្តីផ្តើមនីតិរដ្ឋប្បវេណី (ភ្នំពេញ, ២០១១),៥៖១០១។

## កថាខណ្ឌ២៖ លក្ខខណ្ឌនៃការទទួលខុសត្រូវ

### ១.ប្រភេទនៃព្យសនកម្ម ឬ ការខូចខាត

ការខូចខាត និងព្យសនកម្ម គឺមានន័យដូចគ្នា ដែរគេឲ្យនិយមន័យព្យសនកម្មបានថា ជាការខូចខាត ឬសេចក្តីវិនាសអន្តរាយដល់សម្ភារៈក្តី រូបរាងកាយក្តី ដល់ផ្លូវចិត្ត បណ្តាលមកពីអំពើរបស់អ្នកដទៃ។

អ្នកលក់ ឡេលាបអោយស ម្នាក់ទោះបានដឹងថា ឡេលាបខ្លួនអោយសនោះមានលាយសារធាតុគីមីក៏ដោយក៏គេនៅតែយកវាមកលក់អោយអតិថិជន ដើម្បីផលប្រយោជន៍អាជីវកម្មរបស់ខ្លួន ដែលវាបណ្តាលឲ្យមានការខូចខាតដល់អ្នកប្រើប្រាស់យ៉ាងខ្លាំង (ប្រតិកម្មស្បែក) ។

ក្នុងករណីដូចដែលបានរៀបរាប់ខាងលើ តើអ្នកណាជាអ្នកទទួលខុសត្រូវទៅលើព្យសនកម្មមួយនេះ? ព្យសនកម្ម ឬការខូចខាតរួមមានបីប្រភេទ៖

- ព្យសនកម្ម ផ្នែករូបកាយ
- ព្យសនកម្ម ផ្នែកសម្ភារៈ
- ព្យសនកម្ម ផ្នែកផ្លូវចិត្ត

#### ១.១.ព្យសនកម្ម ផ្នែករូបកាយ

គឺជាការអន្តរាយទាំងឡាយណាដែលប៉ះពាល់ដល់រូបកាយរបស់ជនរងគ្រោះ ឬដល់អាយុជីវិតរបស់ជនរងគ្រោះ ដែលការខូចខាតនេះដែលបង្កអោយមានពិការភាព ខូចសម្ផស្ស ដែលបណ្តាលមកពីអំពើល្មើសណាមួយ ដែលចារីបានបង្ក។

#### ១.២.ព្យសនកម្ម ផ្នែកសម្ភារៈ

ការខូចខាតផ្នែកសម្ភារៈ គឺជាការខូចខាតទាំងឡាយណាដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិរបស់ភាគី។ ដូចជាការខូចខាចទៅលើសម្ភារៈប្រើប្រាស់ និងប្រាក់កាក់ក្នុងការព្យាបាល។

#### ១.៣.ព្យសនកម្ម ផ្នែកផ្លូវចិត្ត

ពីដើមឡើយ គេយល់ថាការខូចខាតផ្នែកផ្លូវចិត្ត គឺជាការខូចខាតដែលគេមិនអាចមើលឃើញ ដែលគេអនុញ្ញាតអោយមានការសងការខូចខាតត្រឹមតែផ្នែកសម្ភារៈ និងផ្នែករូបកាយតែប៉ុណ្ណោះ ។

ប៉ុន្តែបន្តិចម្តងៗ គំនិតខាងលើនេះបានផ្លាស់ប្តូរ ការប៉ះពាល់ដល់កិត្តិយសរបស់ សិល្បៈករ តួសំដែង ឬជនណាមួយ ដែលទទួលរងនូវការខូចខាត អាចជាការខូចខាតមុខមាត់ ដោយសារតែការរងគ្រោះ ដែលអាចបណ្តាលអោយបាត់បង់វិជ្ជាជីវៈ គឺនាំអោយបាត់បង់នូវប្រាក់ចំណូលសម្រាប់ជីវិត ដែលវាជាហេតុនាំអោយបច្ចុប្បន្ននេះ មានការជួសជុលព្យសនកម្មផ្នែកផ្លូវចិត្តត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ។

### ២.ទំនាក់ទំនងហេតុ និងផល

ទំនាក់ទំនងហេតុផល គឺជាទំនាក់ទំនងរវាងអំពើដែលជាកំហុសជាមួយនឹងព្យសនកម្ម មានន័យថាព្យសនកម្មបានកើតឡើងភ្លាមៗ ឬបន្ទាប់ពីអំពើប្រព្រឹត្តបានកើតឡើង ឬក៏អាចនិយាយម្យ៉ាងទៀតបានថា ទំនាក់ទំនងហេតុផលមានន័យថា ជាទំនាក់ទំនងហេតុផលនៃការកើតឡើងនូវការខូចខាតចំពោះជនរងគ្រោះ និងកំហុសរបស់ចារី ។ វាជារឿងធម្មតាទេដែលចាំបាច់ត្រូវមានអត្ថិភាពនៃទំនាក់ទំនងហេតុផល ដើម្បីកំណត់ថា ចារីបានបង្កឲ្យមានការខូចខាតដល់ជនរងគ្រោះ ។ ដូចមានចែងក្នុងកថាខណ្ឌទី៣ មាត្រា៧៨៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ "ចំពោះកំហុសចេតនា ឬកំហុសអចេតនារបស់ចារីនេះ ទំនាក់ទំនងនៃហេតុផលរវាងអំពើរបស់អ្នកប្រព្រឹត្តអំពើបំពាន និងការកើតឡើងនៃការខូចខាត និងការខូចខាតដែលកើតមានឡើងលើជនរងគ្រោះ បុគ្គលដែលទាមទារសំណងការខូចខាតនោះត្រូវបញ្ជាក់បង្ហាញ" ។ ដូច្នេះវាមានសារៈសំខាន់ណាស់ ក្នុងការបង្ហាញឲ្យឃើញនូវអត្ថិភាពនៃទំនាក់ទំនងមួយយ៉ាងពិតប្រាកដ អំពីទំនាក់ទំនងរវាងអំពើដែលបានប្រព្រឹត្តិជាមួយនឹងព្យសនកម្ម។

ដូចជាករណីថា ភាគី"**ក**" ជាម្ចាស់ផលិតកម្មចំណីអាហារមួយ ដោយបានធ្វើការលក់ចែកចាញនូវផលិតផលចំណីអាហាររបស់ខ្លួនទៅ ភាគី"**ខ**" ដែលជាអ្នកទិញ ។ ក្រោយពីបានទិញចំណីពីភាគី "**ក**" យកទៅបរិភោគរួចនោះ ភាគី"**ខ**" ស្រាប់តែមានការរាករូសខ្លាំង ។

ក្នុងករណីខាងលើនេះ ចំណងហេតុផល គឺស្ថិតនៅត្រង់ការរាករូសរបស់ភាគី"**ខ**" បណ្តាលមកពីការបរិភោគចំណីគ្មានគុណភាព មិនមែនការរាករូសរបស់ភាគី"**ខ**" បណ្តាលមកពីការឈឺអ្វីផ្សេងនោះទេ ។ ដូច្នេះទំនាក់ទំនងហេតុនឹងផលត្រូវតែទាក់ទងគ្នាទើបអាចមានព្យសនកម្មបាន ។

### ៣.កំហុស

កំហុស គឺជាទង្វើដែលបុគ្គលណាមួយបានប្រព្រឹត្តដោយផ្ទុយនឹងច្បាប់ទាក់ទងទៅនឹងសិទ្ធិ ឬផលប្រយោជន៍របស់អ្នកដទៃ ដោយចេតនាក្តី ឬដោយអចេនាក្តី ដែរចារីត្រូវទទួលខុសត្រូវសង ការខូចខាតដែលបានកើតឡើងដោយអំពើនោះ។[9]

កំហុស គឺជាលក្ខខណ្ឌមួយនៃការទទួលខុសត្រូវ។ ដើម្បីអោយមានការទទួលខុសត្រូវចំពោះ ព្យសនកម្មទៅបាន លុះត្រាតែអំពើដែលបង្កឡើងនូវព្យសនកម្មនោះជាកំហុស។

នៅក្នុងន័យបច្ចេកទេសកំហុស គឺជាអាកប្បកិរិយាខាងផ្លូវចិត្តរបស់បុគ្គលណាមួយដែលបាន ប្រព្រឹត្តិនូវអំពើនាំអោយមានព្យសនកម្មកើតឡើងដល់អ្នកដទៃ ដែលអំពើនោះកើតឡើងក្រោមរូប ភាពចេតនា ឬអចេតនា។

#### ៣.១.កំហុសចេតនា

កំហុសដោយចេតនា ជាទង្វើដែលកើតឡើងក្រោមឆន្ទៈរបស់ចារី។ កំហុសចេតនា សំដៅទៅ លើ អំពើដែលត្រូវនឹងចំណុចខាងក្រោម៖

- ធ្វើអំពើបំពានដោយព្យាករណ៍ទុកជាមុនអំពីការកើតឡើងនៃលទ្ធផល ហើយដោយ ទទួលយកការកើតឡើងនៃលទ្ធផលនោះ។ [10]

លោក “**ក**” ជាកសិករម្នាក់ ដោយលោកចង់បានផលច្រើន លោកក៏សម្រេចចិត្តបាញ់ថ្នាំ គីមី ទៅលើបន្លែទាំងនោះ ។ ក្នុងករណីនេះអំពើរបស់ លោក “**ក**” ជាកំហុសដោយចេតនា ដោយហេតុថា ខ្លួនបានដឹងរួចហើយអំពីលទ្ធផលនៃទង្វើរបស់ខ្លួនដែលបានប្រព្រឹត្ត ។

#### ៣.២.កំហុសអចេតនា

កំហុសអចេតនា គឺជាកំហុសដែលកើតឡើងដោយសារការធ្វេសប្រហែស ឬខ្វះការប្រុង ប្រយ័ត្ន ធ្វើឲ្យមានការខូចខាតដល់អ្នកដទៃ។ ដោយយោងតាមមាត្រា ៧៥២ កថាខណ្ឌទី២ នៃក្រម រដ្ឋប្បវេណីឆ្នាំ ២០០៧ ចែងពីកំហុសដោយ អចេតនាថា “... ខ. ធ្វើអំពើដែល បើតាមប្រក្រតី បុគ្គល ដែលមានឋានៈនៃការងារ ឬបទពិសោធន៍ស្មើគ្នានឹងអ្នកធ្វើអំពើនោះ អាចព្យាករណ៍ទុកជាមុនអំពី ការកើតឡើងនៃលទ្ធផលក៏ដោយ ក៏អ្នកធ្វើអំពើនោះនៅតែពុំបានព្យាករណ៍ទុកជាមុនអំពីការកើត

[9] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រ ៧៥៣

[10] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រ ៧៥២

ឡើងនៃលទ្ធផលនោះ ដោយសារការធ្វេសប្រហែសមិនប្រុងប្រយ័ត្ន ហើយទោះជាមានករណីយកិច្ចជៀសវាងនូវលទ្ធផលនោះក៏ដោយក៏នៅតែប្រព្រឹត្តផ្ទុយនឹងករណីយកិច្ចនោះ"។

## ផ្នែកទី២៖ ការទទួលខុសត្រូវនៃអំពើអនីត្យានុកូល

នៅខាងលើបានសិក្សារួចទៅហើយទាក់ទងទៅនឹងសញ្ញាណ នៃអំពើអនីត្យានុកូល ដែលបានកំណត់យ៉ាងច្បាស់រួចមកហើយថាអំពើអ្វីខ្លះ ឬបែបណាខ្លះដែលជាអំពើអនីត្យានុកូល ។ បន្ទាប់មកទៀតនោះ គឺជាការសិក្សាអំពីការដែលទទួលខុសត្រូវវិញម្តង ថាតើអំពើអនីត្យានុកូលដែលបានកើតឡើងដោយសារតែទំនិញនីមួយៗ ដែលគ្មានគុណភាពរួមទាំងផ្ទុកទៅដោយសារធាតុគីមីនោះនឹងមានការទទួលខុសត្រូវបែបណាខ្លះ ហើយតើមានការទទួលខុសត្រូវទៅលើអ្វីខ្លះ ។

### កថាខណ្ឌ១៖ ការទទួលខុសត្រូវលើផលិតផល

វាជាការទទួលខុសត្រូវតែទៅលើផលិតផលទំនិញគ្មានគុណភាព ទំនិញមានសារធាតុគីមីហួសកម្រឹត ធ្វើអោយប៉ះពាល់ដល់សុខភាពរបស់អ្នកប្រើប្រាស់ ដែលអ្វីៗទាំងអស់គឺបង្កមកពី ផលិតផលរបស់បុគ្គលជាអ្នកផលិត និងវត្ថុមានគ្រោះថ្នាក់ ។

#### ១.ផលិតផលរបស់បុគ្គលជាផលិតករ

អ្នកដែលត្រូវទទួលខុសត្រូវចំពោះផលិតផល គឺជាផលិតករ ។ មិនត្រឹមតែអ្នកផលិតចុងក្រោយទេដែលទទួលខុសត្រូវចំពោះវត្ថុនោះ គឺរួមទាំងអ្នកផលិតសារធាតុមានវិការៈផងដែរ ដែលត្រូវទទួលខុសត្រូវ ។ ចំពោះទំនិញដែលនាំចូលវិញ អ្នកនាំចូលត្រូវចាត់ទុកថាជាផលិតករ ។ រីឯបុគ្គលដែលបានដាក់សញ្ញានៃនាមករណ៍របស់ខ្លួន ឬអ្នកលក់ទំនិញ ក៏ត្រូវចាត់ទុកថាជាផលិតករនៃទំនិញនោះដែរ ។[11] ម្ចាស់កម្មសិទ្ធ ឬផលិតករ ឈ្មួញ មន្ត្រីកាំកុងត្រូល ត្រូវតែទទួលខុសត្រូវទៅលើទំនិញ រឺផលិតផលដែលបាននាំចេញពីរោងចក្រ ឧស្សាហាកម្ម សហគ្រាស សិប្បកម្ម ដែលធ្វើអោយអ្នកដទៃរងគ្រោះថ្នាក់ខូចខាតជាទ្រព្យសម្បត្តិ ឬផ្លូវចិត្ត នៅពេលដែលអ្នកទិញបានទិញផលិតផលនោះយកទៅប្រើប្រាស់នៅពេលដែលផលិតករនោះ បានបញ្ចេញផលិតផលរបស់ខ្លួនទៅតាមទីផ្សារជាច្រើន ។ ការទទួលខុសត្រូវចំពោះផលិតផលរបស់ផលិតករ គឺជាទ្រឹស្តីច្បាប់នៃការទទួលខុសត្រូវយ៉ាងតឹងរឹងមួយដែលត្រូវបានអភិវឌ្ឍន៍ តាមរយៈយុត្តិសាស្ត្ររបស់អាមេរិក ចាប់ពីទសវត្សរ៍១៩៦០

[11] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រ ៧៥១៖ ២-៣-៤។

មក ។[12] កម្មវត្ថុដែលផលិតករត្រូវទទួលខុសត្រូវចំពោះវិការៈដែលបានកើតឡើងដោយសារតែវត្ថុរបស់ខ្លួនផលិតនោះ គឺផលិតផលនោះត្រូវតែជាចលនវត្ថុ ដូច្នេះក្នុងករណីដែលមានវិការៈចំពោះអចលនវត្ថុនោះ មិនអាចយកបញ្ញត្តិស្តីពីការទទួលខុសត្រូវរបស់ផលិតករលើវិការៈផលិតផលទំនិញ ដែលខ្លួនបានផលិតមកអនុវត្តបាននោះទេ។[13]

ព្យសនកម្មដែលបង្កឡើងដោយផលិតផល គឺវិការៈដែលនាំអោយមានគ្រោះថ្នាក់មិនសមហេតុផល។ វិការៈ សំដៅទៅលើកង្វះនូវសុវត្ថិភាពដែលចាំបាច់ត្រូវមានជាធម្មតាសម្រាប់ផលិតផលដែលបានផលិតឡើង ដោយគិតពិចារណានូវលក្ខណៈពិសេសនៃផលិតនោះ និងវិធីប្រើប្រាស់ផលិតផលនោះផងដែរ។

នៅពេលដែលមានវិការៈកើតឡើង ផលិតករត្រូវតែទទួលខុសត្រូវ ចំពោះការខូចខាត ផ្នែករដ្ឋប្បវេណី ពេលខ្លះទៀតបើសិនផលិតផលនោះធ្វើអោយប៉ះពាល់ដល់អាយុជីវិតរបស់អ្នកប្រើប្រាស់នោះ ផលិតករថែមទាំងអាចជាប់ចោទពីបទល្មើសព្រហ្មទណ្ឌថែមទៀតផង។

**២.វត្ថុមានគ្រោះថ្នាក់**

ការទទួលខុសត្រូវចំពោះអំពើរបស់វត្ថុមានគ្រោះថ្នាក់ គឺជាការទទួលខុសត្រូវលើការខូចខាតដែលបណ្តាលមកពី អំពើរបស់វត្ថុមានគ្រោះថ្នាក់ដែលស្ថិតនៅក្រោមការមើលថែទាំរបស់អ្នកថែរក្សាវត្ថុនោះ ។ ការទទួលខុសត្រូវចំពោះអំពើរបស់វត្ថុមានគ្រោះថ្នាក់ត្រូវមានធាតុផ្សំបីះ

- វត្ថុមាននៃវត្ថុមានគ្រោះថ្នាក់

ត្រូវចាត់ទុកថាជាវត្ថុមានគ្រោះថ្នាក់ចំពោះគ្រប់វត្ថុដែលជា រថយន្ត គ្រឿងចក្រសម្រាប់ដឹកជញ្ជូនផ្សេងទៀត គ្រឿងផ្ទុះ វត្ថុធាតុវិទ្យុសកម្ម វត្ថុធាតុគីមីដែលមានជាតិពុល អតិសុខុមប្រាណឧត្បាត ឬគ្រឿងដែលមានកម្រិតគ្រោះថ្នាក់ខ្ពស់ផ្សេងទៀត។[14]

- បុគ្គលដែលមានសិទ្ធិថែរក្សាវត្ថុមានគ្រោះថ្នាក់

ត្រូវចាត់ទុកថាជា កម្មសិទ្ធិករ ឬបុគ្គលដែលមានសិទ្ធិថែរក្សាវត្ថុមានគ្រោះថ្នាក់ ចំពោះបុគ្គលទាំងឡាយណាដែលជាអ្នកមើលថែរក្សា គ្រប់គ្រង ឬកំពុងប្រើប្រាស់វត្ថុមានគ្រោះថ្នាក់នោះ លើកលែងតែមានភស្តុតាងផ្សេងមកបញ្ជាក់ ។

[12] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី( ភ្នំពេញះក្រសួងយុត្តិធម៌,២០១០), ៣, មាត្រា ៧៥១។
[13] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី( ភ្នំពេញះក្រសួងយុត្តិធម៌,២០១០), ៣ះ១៨៩, មាត្រា ៧៥១។
[14] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ៧៥២។

- ការចូលរួមរបស់វត្ថុក្នុងការកើតមានព្យសនកម្ម

វត្ថុដែលបង្កអោយមានព្យសនកម្មកើតឡើងចាំបាច់ត្រូវតែជាវត្ថុមានគ្រោះថ្នាក់ ។ ដូច្នេះការទទួលខុសត្រូវលើព្យសនកម្ម គឺជាបន្ទុករបស់បុគ្គលដែលជាអ្នកមើលថែរក្សាវត្ថុនោះដោយយោងតាមមាត្រា ៧៥២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ចែងថា "បុគ្គលជាកម្មសិទ្ធិករ ឬអ្នកគ្រប់គ្រងរថយន្ត គ្រឿងចក្រសម្រាប់ដឹកជញ្ជូនផ្សេងទៀត គ្រឿងផ្ទុះ វត្ថុធាតុវិទ្យុសកម្ម វត្ថុធាតុគីមីដែលមានជាតិពុលអតិសុខុមប្រាណឧត្បាត ឬគ្រឿងដែលមានកម្រិតគ្រោះថ្នាក់ខ្ពស់ផ្សេងទៀត ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលបង្កដល់អ្នកដទៃ ដោយសារវត្ថុគ្រោះថ្នាក់ដែលខ្លួនមានកម្មសិទ្ធិ ឬគ្រប់គ្រង"។

## កថាខណ្ឌ២៖ ការរួចផុតពីការទទួលខុសត្រូវនៃអំពើអនីត្យានុកូល

ជាគោលការណ៍រាល់បញ្ហាទាំងអស់ដែលបានកើតឡើង ដែលបណ្តាលឲ្យមានព្យសនកម្មនោះ អ្នកប្រព្រឹត្តិត្រូវតែទទួលខុសត្រូវនូវទង្វើរបស់ខ្លួន ប៉ុន្តែក៏មានករណីដែលពួកគេអាចរួចផុតពីការទទួលខុសត្រូវនូវកំហុសដែលពួកគេបានធ្វើនោះដែរ ដែលវាជាការរួចផុតពីការទទួលខុសត្រូវទាក់ទងទៅនឹងទំនិញ និងការរួចផុតពីការទទួលខុសត្រូវទាក់ទងនឹងផលិតផលមានគ្រោះថ្នាក់ ។

### ១.ផលិតផលរបស់បុគ្គលជាផលិតករ

បុគ្គលជាអ្នកផលិតនូវទំនិញ ដែលអាចបង្កអោយមានព្យសនកម្មនោះក៏អាចរួតផុតពីការទទួលខុសត្រូវទៅលើសំណងនៃព្យសនកម្មដែលកើតពីទំនិញដែលខ្លួនបានផលិតផង ក្នុងករណីដែលផលិតករមិនអាចប្រមាណបាននូវព្យសនកម្មដែលអាចនឹងកើតឡើង តាមកម្រិតវិទ្យាសាស្ត្រនៃបច្ចេកទេស នៅសម័យនៃការផលិតទំនិញទាំងនោះ[15] មានន័យថា ទំនិញទាំងនោះមិនបានបង្ហាញឲ្យឃើញនូវព្យសនកម្មភ្លាមៗ ឬក៏គេមិនអាចដឹងពីព្យសនកម្មនោះបានថាវាប៉ះពាល់អ្វីខ្លះនៅសម័យដែលគេផលិត និងដាក់ឲ្យប្រើប្រាស់ឡើយ ។ ចំពោះចលនវត្ថុដែលមិនបានកែច្នៃ ដូចជាត្រីដែលស្ងួចបានដែលមានសារធាតុគីមី ឬមានវិការៈដែលបណ្តាលមកពីត្រីនោះក៏ផលិតករ(អ្នកស្ងួច)មិនទទួលខុសត្រូវចំពោះផលិតផលរបស់ខ្លួនឡើយ ។ ការខូតខាតដែលបណ្តាលមកពីវិការៈនៃអចលនវត្ថុនោះ អ្នកផលិតមិនមានភារៈកិច្ចក្នុងកាទទួលខុសត្រូវឡើយ ។[16]

[15] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ៧៥១។

[16] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី( ភ្នំពេញ៖ក្រសួងយុត្តិធម៌,២០១០), ៣, មាត្រា ៧៥១។

### ២.វត្ថុមានគ្រោះថ្នាក់

ជាគោលការណ៍កម្មសិទ្ធិករនៃវត្ថុ គឺត្រូវបានគេសន្មតថាជាឆ្នាំ ប៉ុន្តែក្នុងករណីនេះគ្រាន់តែជាសច្ចធាណ៍ធម្មតាតែប៉ុណ្ណោះ កម្មសិទ្ធិករអាចបង្ហាញថា អំពើដែលបង្កអោយមានការអន្តរាយនោះខ្លួនគ្មានកំហុសក្នុងការថែរក្សាទាល់តែសោះ ឬក៏បង្ហាញថាវត្ថុនោះត្រូវបានផ្ទេរទៅបុគ្គលផ្សេងទៀត។ ជាការលើកលែងទូទៅទាក់ទងទៅនឹងព្យសនកម្មដែលកើតមានទៅលើជនរងគ្រោះដោយសារតែវិការៈនៃទំនិញរបស់ម្ចាស់កម្មសិទ្ធដែលបណ្តាលមកពីករណីប្រធានសក្តិ ។ ម្ចាស់កម្មសិទ្ធិនៃទំនិញដែលមានគ្រោះថ្នាក់ខាងលើនោះ ក៏អាចរួចផុតពីការទទួលខុសត្រូវទៅលើព្យសនកម្មដែលកើតមានដោយសារទំនិញរបស់ខ្លួនដែល ក្នុងករណីដែលព្យសនកម្មបានកើតឡើងដោយសារតែទង្វើរបស់ជនរងគ្រោះខ្លួនឯង ឬជាទង្វើបង្កបស់តតិយជន ។[17]

ប្រសិនបើកម្មសិទ្ធិករបានបោះបង់ ការអាស្រ័យផលទៅលើវត្ថុដល់អ្នកកាន់កាប់ណាមួយហើយ (អ្នកជួល អ្នកខ្ចី អ្នកទទួលរក្សាទុក)។ គឺអ្នកទាំងនោះត្រូវទទួលបន្ទុកថាជាអ្នកថែរក្សា ហើយទទួលខុសត្រូវលើព្យសនកម្មដែលអាចកើតឡើងដោយអំពើរបស់វត្ថុនោះ ។

### កថាខណ្ឌ៣៖ ការគណនាសំណង

ជាទូទៅនៅពេលដែលកើតមាននូវព្យសនកម្ម តែងតែមាននូវការទទួលខុសត្រូវនូវសំណងទៅលើព្យសនកម្មជាប់មកជាមួយ ដែលវាជាគោលការណ៍មួយដែរច្បាប់បានបង្កើតឡើងសម្រាប់អនុវត្តចំពោះចារីដែលបានប្រព្រឹត្តិនូវ បទល្មើសដែលបង្កឲ្យមានការខូចខាតកើតឡើងទៅលើជនរងគ្រោះដោយផ្ទាល់ក្តី ដោយប្រយោលក្តី។ ចំពោះការគណនាសំណងនេះផងដែរ តុលាការបានធ្វើការគណនាសំណងដោយផ្អែកទៅលើ ការខូចខាតផ្នែកសម្ភារៈ ការខូចខាតផ្នែករូបរាងកាយ និងការខូចខាតផ្នែកផ្លូវចិត្តផងដែរ ។ ជាគោលការណ៍ សំណងនៃការខូចខាតត្រូវសងជាប្រាក់ក៏ប៉ុន្តែក្នុងករណីដែលមិនអាចទទួលការសង្គ្រោះត្រឹមត្រូវដោយសំណងជាប្រាក់ ជនរងគ្រោះអាចទាមទារឲ្យធ្វើបដិទាន ឬអាចទាមទារឲ្យហាមឃាត់មិនឲ្យធ្វើអំពើណាមួយបាន ។ ចំពោះការគណនាចំនួនទឹកប្រាក់នៃការខូចខាតលើទ្រព្យសម្បត្តិដោយសារអំពើអនីត្យានុកូល ពីភាពខុសគ្នារវាងភាគនៃទ្រព្យសម្បត្តិដែលត្រូវបានសន្មត់ថានឹងមានប្រសិនបើគ្មានអំពើអនីត្យានុកូល និងស្ថានភាពនៃទ្រព្យសម្បត្តិជាក់ស្តែង ក្រោយពេលដែលអំពើអនីត្យានុកូលបានកើតឡើង ត្រូវបានវាយតម្លៃដោយប្រើប្រាស់

[17] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី( ភ្នំពេញ៖ក្រសួងយុត្តិធម៌,២០១០), ៣, មាត្រា ៧៥២។

នូវស្ថិតិ និងឯកសារផ្សេងទៀត ។ ប៉ុន្តែចំពោះការគណនាចំនួនទឹកប្រាក់នៃការខូចខាតផ្នែកសតិអារម្មណ៍ដោយសារអំពើអនីត្យានុកូលវិញ ចំនួនទឹកប្រាក់នៃជម្ងឺចិត្ត ត្រូវបានវាយតម្លៃដោយគិតពិចារណានូវស្ថានភាពផ្សេងៗ ដូចជាកម្រិតនៃកំហុសចេតនា ឬអចេតនារបស់អ្នកប្រព្រឹត្ត អំពើបំពានប្រភេទ និងកម្រិតនៃការរងគ្រោះ អំពើរបស់អ្នកប្រព្រឹត្តិបង្កឱ្យមានការរងគ្រោះនោះ។

ម្យ៉ាងវិញទៀតក៏នូវមានការទាមទារសំណងនៃការខូចខាត ដោយសារតែអំពើដែលមានការបំពានទៅលើជីវិត ក្នុងករណីដែលជនរងគ្រោះទទួលមរណភាព ដោយអំពើអនីត្យានុកូល អ្នករងគ្រោះអាចទទួលសិទ្ធទាមទារសំណងចំពោះការខូចខាតលើទ្រព្យសម្បត្តិ និងការខូចខាតសតិអារម្មណ៍ដែលបានកើតឡើងចំពោះខ្លួន រហូតដល់មរណភាព ។ ចំពោះការខូចខាតលើទ្រព្យសម្បត្តិដែលបានកំណត់ក្នុងករណីដូចដែលបានរៀបរាប់ គេត្រូវរួមបញ្ចូលទាំងសោហ៊ុយព្យាបាល និងសោហ៊ុយចំណាយផ្សេងៗទៀតដែលជនរងគ្រោះបានបង់ ឬមានករណីយកិច្ចត្រូវបង់ ចាប់ពីក្រោយអំពើបង្កឱ្យមានការរងគ្រោះ រហូតដល់មរណភាព និងប្រាក់ចំណូលដែលជនរងគ្រោះមិនបានទទួល ចាប់ពីក្រោយអំពើបង្កឱ្យមានការរងគ្រោះ រហូតដល់ពេលទទួលមរណភាពជាអាទិ៍ ។[18] បើជនរងគ្រោះទទួលមរណភាព ដោយអំពើអនីត្យានុកូល សហព័ទ្ធ ញាតិនៅក្នុងថ្នាក់១ និងញាតិដែលរស់នៅជាមួយជនរងគ្រោះ អាចទាមទារសំណងនៃការខូចខាតសតិអារម្មណ៍ដែលបានកើតឡើង ដោយសារមរណភាពរបស់ជនរងគ្រោះនោះបាន ។

ការទាមទារសំណងនៃការខូចខាតដោយអំពើអនីត្យានុកូល ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ៣ឆ្នាំ បានកន្លងហួស បន្ទាប់ពីពេលដែលជនរងគ្រោះ ឬអ្នកតំណាងដែលច្បាប់បានកំណត់របស់ជនរងគ្រោះនោះ បានដឹងថាអាចទាមទារសំណងការខូចខាតចំពោះអ្នកប្រព្រឹត្តិអំពើបំពានបាន ឬបើអំឡុងពេល ១០ឆ្នាំ បានកន្លងហួសបន្ទាប់ពីអំពើអនីត្យានុកូលនោះត្រូវបានប្រព្រឹត្តិឡើង។ [19]

ដូចជាក្នុងករណីដែលថា ភាគី“**ក**” គឺជាឱសថការីម្នាក់ ។ ភាគី “**ក**” បានធ្វើការលក់ថ្នាំ ទៅអោយ ភាគី“**ខ**” ដោយថ្នាំនោះគឺជាថ្នាំដែលគ្មានគុណភាព ក្រោយពេលដែលលេបថ្នាំនោះរួច ភាគី “**ខ**” ក៏បានទទួលរងនូវគ្រោះថ្នាក់ ដោយរលាកក្រពះដែលបណ្តាលមកពីឥទ្ធិពលនៃថ្នាំនោះ ។ ដូច

---

[18] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី( ភ្នំពេញ៖ក្រសួងយុត្តិធម៌,២០១០), ៣, មាត្រា ៧៦០។
[19] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី( ភ្នំពេញ៖ក្រសួងយុត្តិធម៌,២០១០), ៣, មាត្រា ៧៦៥។

ដែលបានរៀបរាប់ខាងលើ យើងមើលឃើញថា អ្នកដែលត្រូវទទួលខុសត្រូវទៅលើ ព្យសនកម្ម ដែល ភាគី “**ខ**” ទទួលនោះ គឺភាគី “**ក**” ។ ដោយតុលាការនឹងធ្វើការសិក្សាទៅលើ ថាតើថ្នាំនោះបាន ខូចគុណភាពក្នុងដំណាក់កាលមួយណា ដោយជនរងគ្រោះអាចទាមទារនូវសំណងស៊ីវិល ដែល ជាសំណងបានមកពីការខូចខាតដែលបង្កមកពីថ្នាំពេទ្យគ្មានគុណភាពនោះ ។ អ្នកលក់ឱសថ ដែលគ្មានគុណភាព ឬឱសថដែលផុតកំណត់ប្រើប្រាស់ និងត្រូវពិន័យប្រាក់ពី ៥.០០០.០០០(ប្រាំ លាន)រៀល ដល់ ១០.០០០.០០០(ដប់លាន)រៀល។[20]

[20] ច្បាប់ស្តីពីការគ្រប់គ្រងឱសថ,លេខ/ជស/រកម/០៦៩៦/០២,២៨ ធ្នូ ២០០៧,មាត្រា ១០។

# ជំពូកទី២

# វិធានការទទួលខុសត្រូវតាមកិច្ចសន្យា

# ជំពូកទី២៖ វិធានការទទួលខុសត្រូវតាមកិច្ចសន្យា

តើអ្វីទៅជាការទទួលខុសត្រូវតាមកិច្ចសន្យា? លក្ខខណ្ឌអ្វីខ្លះដើម្បីឱ្យមានការទទួលខុសត្រូវតាមកិច្ចសន្យា? ដើម្បីឱ្យមានការទទួលខុសត្រូវតាមកិច្ចសន្យានោះ លុះត្រាតែបុគ្គលទាំងពីរមានចំណងគតិយុត្តជាមួយគ្នា។ ដោយចំណងគតិយុត្តនោះ គឺជាកាតព្វកិច្ចដែលកើតមកពីឆន្ទៈរបស់គូភាគី ដោយបានមកពីការព្រមព្រៀងគ្នារបស់គូភាគីក្នុងការបង្កើតកិច្ចសន្យា។ បុគ្គលទាំងពីរនោះត្រូវគោរពលក្ខខណ្ឌគ្រឹះនិងទម្រង់ក្នុងដំណាក់កាលបង្កើតកិច្ចសន្យា ។ ដោយលក្ខខណ្ឌគ្រឹះក្នុងកិច្ចសន្យាគូភាគីត្រូវមាន (១)ឆន្ទៈព្រមព្រៀងគ្នា (២)ជនដែលមានសមត្ថភាព និង(៣)កម្មវត្ថុពិតប្រាកដក្នុងកិច្ចសន្យា ។ ចំណែកឯលក្ខខណ្ឌទម្រង់ គូភាគីអាចធ្វើជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់។ នៅពេលដែលភាគីទាំងពីរបានព្រមព្រៀងគ្នាក្នុងការបង្កើតកិច្ចសន្យា នោះកិច្ចសន្យា និងមានសុពលភាពគូភាគីត្រូវមានសិទ្ធ និងករណីយកិច្ចក្នុងកិច្ចសន្យាដោយ គូភាគីត្រូវតែទទួលខុសត្រូវលើហានិភ័យដោយកើតឡើងពីសកម្មភាពរបស់ខ្លួន និងដោយសារតែការមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន។

## ផ្នែកទី១៖ ការទទួលខុសត្រូវលើវត្ថុមានវិការៈ

ក្នុងកិច្ចសន្យាលក់ទិញភាគីទាំងសងខាងមានកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមក ។ អ្នកលក់និងអ្នកទិញមានកាតព្វកិច្ច និងករណីយកិច្ចផ្សេងពីគ្នា ។ មិនថាអ្នកលក់ទេដែលមានសិទ្ធិ និងករណីយកិច្ច ចំពោះអ្នកទិញក៏មានសិទ្ធ និងករណីយកិច្ចដូចគ្នានទៅនឹងអ្នកលក់ដែរ ។

អ្នកលក់មានកាតព្វកិច្ចសំខាន់ទីមួយរបស់គាត់ គឺត្រូវប្រគល់ទំនិញ ឬផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិដែលគាត់បានព្រមព្រៀងលក់ទៅឱ្យអ្នកទិញ។[21] សិទ្ធិលើទ្រព្យសម្បត្តិ ឬទំនិញដែលត្រូវប្រគល់ទៅឱ្យអ្នកទិញនេះត្រូវតែមានបរិមាណ និងគុណភាពដូចនឹងអ្វីដែលបានព្រមព្រៀងគ្នា។

ម្យ៉ាងទៀតប្រសិនបើការប្រគល់ទំនិញ ឬការផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិ ត្រូវធ្វើនៅក្រោយការបង្កើតកិច្ចសន្យាទិញលក់ អ្នកលក់ មានករណីយកិច្ចថែរក្សាទំនិញ ឬទ្រព្យនោះឱ្យបានគង់វង់ល្អរហូតដល់ពេលប្រគល់ទៅឱ្យអ្នកទិញ។[22] ច្បាប់តម្រូវឱ្យអ្នកលក់ថែរក្សាទំនិញ ឬទ្រព្យសម្បត្តិ ដែលជាកម្មវត្ថុនៃការលក់នេះ ឱ្យបានហ្មត់ចត់ "ក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ គឺត្រូវថែរក្សាទំនិញរបស់អ្នក

[21] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រ៥៣១៖ ៣ ។

[22] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រ៥៥២៖ ១ ។

ទិញឲ្យដូចជាការថែរក្សាទ្រព្យសម្បត្តិរបស់ខ្លួនឯងដែរ ក្នុងនាមជាអ្នកគ្រប់គ្រងសុចរិត។ មិនមែនអាង តែបានចុះកិច្ចសន្យាលក់រួច ទុកទំនិញនោះចោល និងលែងរវីរវល់ខ្វះការថែទាំនាំឱ្យបាត់បង់ ឬខូច ខាតនោះទេ។[23] ក្នុងករណីដែលអ្នកលក់ធ្វើឱ្យបាត់បង់ ឬធ្វើឱ្យខូចខាតទំនិញ ដែលជាកម្មវត្ថុនៃការ លក់ ដោយសារតែមានការធ្វេសប្រហែស មិនបានគោរពករណីយកិច្ចថែរក្សាទំនិញ ដូចដែលមាន ចែងក្នុងកិច្ចសន្យាទេនោះ ។ អ្នកលក់មានករណីយកិច្ចទទួលខុសត្រូវចំពោះអ្នកទិញ ទៅតាមអ្វី ដែលបានចែងក្នុងកិច្ចសន្យា ឬត្រូវសងសំណងនៃការខូចខាតផ្សេងទៀត ទាក់ទងនឹងសំណងខូច ខាតក្នុងករណីមិនគោរពកាតព្វកិច្ចតាមកិច្ចសន្យា ។[24]

ជាទូទៅនៅពេលដែលអ្នកទិញទៅទិញទំនិញពីអ្នកលក់នោះ អ្នកទិញតែងតែចង់ដឹងថាវត្ថុ នោះមានវិការៈ ឬទេ? តើវត្ថុនោះមានជាប់បន្ទុកអ្វីផ្សេងដែរឬទេ? ជាដើម ។ ហេតុដូចនេះហើយអ្នក លក់ត្រូវធានាឱ្យបានថា ខ្លួនត្រូវពន្យល់នូវគ្រប់ខ្លឹមសារនានាដែលទាក់ទងនឹងទំនិញដែលអ្នកទិញ ចង់ទិញនោះ ។[25]

ករណីយកិច្ចសំខាន់មួយទៀតរបស់អ្នកលក់គឺ ករណីយកិច្ចផ្តល់ព័ត៌មានចំពោះអ្នកទិញ គឺជា ព័ត៌មានចាំបាច់ដែលជាប់ពាក់ព័ន្ធនឹងទំនិញដែលខ្លួនលក់នោះ ។ បើអ្នកលក់មិនបំពេញតាម ករណីយកិច្ចផ្តល់ព័ត៌មាននេះទេ ឬផ្តល់ព័ត៌មានមិនគ្រប់គ្រាន់ ឬមិនច្បាស់លាស់ អ្នកលក់ជាអ្នក ទទួលខុសត្រូវចំពោះការខូចខាតណាមួយដែលបានកើតឡើង ដោយសារការខកខានមិនបានផ្តល់ ព័ត៌មាននោះ ។ ម្យ៉ាងទៀត ប្រសិនបើអ្នកលក់ផ្តល់ព័ត៌មានមិនពិត ឬលាក់បាំងការពិតដោយ ចេតនា ហើយព័ត៌មានមិនពិត ឬព័ត៌មានដែលលាក់កំបាំងនេះ គឺជាចំណុចសំខាន់ដែលមានឥទ្ធិ ពលលើការសម្រេចចិត្តរបស់អ្នកទិញ ក្នុងករណីនេះអ្នកទិញអាចសុំលុបចោលកិច្ចសន្យានេះវិញ បាន ដោយលើកយកវិការៈនៃការឆបោករបស់អ្នកលក់មកធ្វើជាមូលហេតុ។

ករណីយកិច្ចមិនមែនកំណត់តែចំពោះអ្នកលក់តែប៉ុណ្ណោះទេ ពោលគឺអ្នកទិញក៏មានករណីយកិច្ច ផងដែរ គ្រាន់តែករណីយកិច្ចរបស់អ្នកទិញ មានផ្សេងពីករណីយកិច្ចរបស់អ្នកលក់តែប៉ុណ្ណោះ ។ ប្រសិនបើអ្នកទិញមានការយឺតយ៉ាវក្នុងការបំពេញករណីយកិច្ចទទួលទំនិញ អ្នកលក់អាចទាមទារ សំណង ប្រសិនបើការយឺតយ៉ាវនោះនាំឱ្យអ្នកលក់ទទួលរងនូវការខូចខាតអ្វីមួយ ថែមទាំងអាច ទាមទាររំលាយកិច្ចសន្យាទិញលក់នេះវិញបាន ។ ម្យ៉ាងទៀត ប្រសិនបើដល់ថ្ងៃកំណត់ទទួលទំនិញ ហើយអ្នកទិញមិនមកទទួលយកទំនិញទេនោះ អ្នកទិញត្រូវជាអ្នកទទួលបន្ទុកហានិភ័យនៃការ

[23] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ៥៣០,៥៥២ ។

[24] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ៣៨៥ ។

[25] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ៥២៩។

បាត់បង់ ឬខូចខាតដែលអាចកើតឡើងលើទំនិញនោះ ដោយសារតែវាផុតពីកាតព្វកិច្ចថែរក្សារបស់អ្នកលក់។[26]

### កថាខណ្ឌ១ ៖ ការទទួលខុសត្រូវក្នុងការធានាលើវត្ថុមានវិការៈ

ការទទួលខុសត្រូវក្នុងការធានា គឺជាប្រព័ន្ធមួយដែលផ្តល់ឱ្យភាគីនូវប្រតិបត្តិការជំនួញមួយដែលមានភាពយុត្តិធម៌ពីព្រោះកិច្ចសន្យាលក់ទិញ គឺជាការដោះដូរទ្រព្យសម្បត្តិ និងប្រាក់ដែលមានតម្លៃស្មើគ្នា។ ក្នុងករណីដែលភាគីអ្នកលក់បានលក់ទំនិញដែលផុតកំណត់ទៅឱ្យអ្នកទិញវានឹងបង្កើតឱ្យមានភាពអយុត្តិធម៌ បើទំនិញដែលភាគីអ្នកទិញបានទិញហើយ ប្រើប្រាស់មិនបានហើយមិនអាចដូរបាន វាធ្វើឱ្យខាតបង់ប្រយោជន៍របស់ភាគីអ្នកទិញ ។ ហេតុនេះហើយទើបក្រមរដ្ឋប្បវេណីបានចែងពីការទទួលខុសត្រូវក្នុងការធានា ដើម្បីកែតម្រូវវិសមភាពនេះ ។

#### ១.បញ្ញាត្តិទូទៅ

អ្នកលក់ត្រូវប្រគល់ទំនិញដែលជាកម្មវត្ថុនៃការទិញលក់ទៅឱ្យអ្នកទិញដោយគ្មានវិការៈ ។[27] កត្តាដែលនាំឱ្យទំនិញនោះមានវិការៈ គឺបណ្តាលមកពីវត្ថុនោះមានភាពមិនស្របនឹងចំនួន។ ករណីដែលអ្នកទិញបាន ទិញត្រីមួយគីឡូស្រាប់តែយកទៅថ្លឹងបានត្រឹមតែ៨ខាំជាដើម(ស៊ីភ្នែកជញ្ជីង) គុណភាពនៃទំនិញនិងខុសលក្ខណៈដែលបានសន្យាជាមួយអ្នកលក់ជាដើម។ លើសពីនេះប្រសិនបើទំនិញនោះខុសពីអ្វីដែលបាននិយាយគ្នា ទាំងចំនួន ទាំងគុណភាព និងទាំងលក្ខណៈទំនិញនោះមិនស្របទៅនឹងវិធីប្រើធម្មតានៃទំនិញប្រភេទដូចគ្នារួមទាំងការវិចខ្ចប់ខុសពីការវេចខ្ចប់ធម្មតាក៏ជាវិការៈដែរ។[28]

តាមការរៀបរាប់ខាងលើនេះ អ្នកទិញត្រូវទទួលបានការទទួលខុសត្រូវក្នុងការធានាពីអ្នកលក់ចំពោះទំនិញមានវិការៈ ម្យ៉ាងទៀតអ្នកទិញអាចទាមទារសំណងខូចខាតនោះបាន។[29]លក្ខខណ្ឌនៃការទទួលខុសត្រូវក្នុងការសងសំណងក្នុងការខូចខាត ដែលចែងពីការមិនអនុវត្តកាតព្វកិច្ច ដោយផ្អែកចាប់ពីមាត្រា៥៤០ ដល់មាត្រា៥៤៧នៃក្រមរដ្ឋប្បវេណី អ្នកទិញអាចទាមទារការអនុវត្តពេញលេញពីអ្នកលក់។ ក្នុងកំឡុងពេលធានាពីអ្នកលក់ ស្រាប់តែទំនិញនោះមានវិការៈ អ្នកលក់ក៏ត្រូវធានាអំពីវិការៈនោះផងដែរ។ ប៉ុន្តែប្រសិនបើអ្នកទិញបានដឹង ឬមិនបានដឹងដោយសារកំហុស

[26] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ៥៥៩ ។
[27] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ៥៣៩។
[28] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ៥៣៩ ។
[29] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ៣៩៨។

ធ្ងន់ធ្ងររបស់អ្នកទិញ នោះអ្នកលក់មិនមានករណីយកិច្ចធានាអំពីវិការៈនោះបានទេ ។[30] អ្នកទិញត្រូវពិនិត្យពិច័យនូវរាល់វិការៈនៃទំនិញ ដែលមានលក្ខណៈងាយស្រួលក្នុងការរក ដែលអាចមើលឃើញនឹងភ្នែក និងបានដឹងមុនថាកម្មវត្ថុទិញនោះមានវិការៈ។ ប៉ុន្តែបើសិន អ្នកទិញពុំបានពិនិត្យដោយខ្លួនឯងផ្ទាល់ ហើយឱ្យអ្នកផ្សេងពិនិត្យដែលមិនបានដឹងថាទំនិញនោះមានវិការៈ នោះអ្នកទិញមិនអាចរំលាយកិច្ចសន្យាបានទេ និងមិនអាចទាមទារឱ្យអ្នកលក់ទទួលខុសត្រូវក្នុងការធានាវិការៈនេះដែរ។

ភាគច្រើនការទទួលខុសត្រូវលើវិការៈ គឺកើតមានឡើងក្នុងករណីដែលគូរភាគីមិនបានដឹងពីអត្ថិភាពនៃវិការៈ ដែលកើតមានឡើងនៅពេលដែលប្រគល់វត្ថុ ។ ភាគី "ក" បានទិញអង្ករពី ភាគី "ខ" ១០គីឡូក្រាម ប៉ុន្តែបានខូចអស់ចំនួន ១គីឡូនៅពេលប្រគល់។ ក្នុងករណីនេះភាគី "ខ" ត្រូវទទួលខុសត្រូវក្នុងវិការៈកើតមានឡើង ទោះបីជាវិការៈនោះមិនមែនកើតមានឡើងដោយសារការឆ្ងេសប្រហែស របស់គាត់ក៏ដោយ ។[31] ករណីមួយទៀត អ្នកលក់បានប្រគល់មាន់ដែលមានផ្ទុកជម្ងឺឆ្លងទៅឱ្យអ្នកទិញ ហើយក្រោយពេលប្រគល់មាន់ មាន់នោះចេញជម្ងឺហើយបានឆ្លងទៅមាន់ផ្សេងទៀត មានន័យថាវិការៈដែលមានអត្ថិភាពនៅពេលប្រគល់បានចេញជាក់លាក់ ក្រោយពេលប្រគល់វត្ថុ។

## កថាខណ្ឌ២៖ ការទទួលខុសត្រូវក្នុងកិច្ចសន្យាដឹកជញ្ជូន

### ១.ការទទួលខុសត្រូវរបស់អ្នកដឹកជញ្ជូនទំនិញ

មិនមែនតែអ្នកលក់ និងអ្នកទិញទេដែលមានកាតព្វកិច្ច និងករណីយកិច្ចនោះទេ អ្នកដឹកជញ្ជូនក៏មានការទទួលខុសត្រូវនៅពេលដែលទំនិញមានវិការៈ។ អ្នកដឹកជញ្ជូនមានកាតព្វកិច្ចដឹកទំនិញដល់គោលដៅ និងទទួលខុសត្រូវលើទំនិញខូចខាតដែលបណ្តាលមកពីការដឹកជញ្ជូននោះ ។[32]

នៅពេលអ្នកដឹកជញ្ជូនបានប្រគល់ទំនិញដែលបានដឹកទៅឲ្យអ្នកដឹកជញ្ជូនផ្សេងទៀតនោះ ត្រូវចាត់ទុកថាភាគីអ្នកដឹកមុនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនទាំងស្រុង ដែលកាតព្វកិច្ចថែរក្សាទទួលខុសត្រូវនោះត្រូវធ្លាក់ទៅលើអ្នកដែលទទួលសិទ្ធដឹកបន្ត។ នៅពេលដែលមិនអាចរកអ្នកទទួលទំនិញឃើញ ឬមានការបដិសេធពីអ្នកទទួលដែលត្រូវទទួលទំនិញ ឬមានការធ្វេសប្រហែសក្នុងការទទួលទំនិញពីអ្នកទទួលនោះអ្នកដឹកជញ្ជូនត្រូវជូនដំណឹងទៅអ្នកផ្ញើស្នើសុំការណែនាំពីការ

---

[30]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ៥៤០ ។

[31]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ៥៤០។

[32] សេចក្តីព្រាងច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម, តុលា ២០០៩, មាត្រា១៣៨។

សុំរក្សាទុកទំនិញ។ បើអ្នកដឹកជញ្ជូនទំនិញមិនបានទទួលការណែនាំរយៈពេល៧ថ្ងៃ អ្នកដឹកជញ្ជូនត្រូវរក្សាទុកទំនិញ និងអ្នកដឹកជញ្ជូនមានសិទ្ធទទួលយកកម្រៃពីម្ចាស់ទំនិញ។ ក្នុងកិច្ចសន្យាការកំណត់ពេលតវ៉ាអំពីការខូចខាតទំនិញមិនឱ្យលើសពី រយៈពេល១៥ថ្ងៃគិតពីថ្ងៃទទួលទំនិញ។ ក្នុងករណីមានការដឹកជញ្ជូនបន្ត ឬការដឹកជញ្ជូនផ្សំគ្នា ភាគីកិច្ចសន្យាអាចទាមទារអ្នកជញ្ជូនដែលមានចុះកិច្ចសន្យា ឬអ្នកដឹកជញ្ជូនចុងក្រោយទទួលខុសត្រូវលើសកម្មភាពការដឹកជញ្ជូនរបស់ខ្លួន។

អញ្ញត្រកម្មៈ អ្នកដឹកជញ្ជូនមិនទទួលខុសត្រូវ ការខូចខាតដូចករណីដូចជា

- ការប្រែប្រួលតាមធម្មជាតិរបស់ទំនិញ ដូចជាការដឹកជញ្ជូនបន្លែ ត្រីសាច់ ជាដើម លើកលែងតែការខូចខាត នោះបណ្តាលមកពីកំហុសរបស់ខ្លួនដូចជាឃើតយ៉ាវ ការធ្វេសប្រហែស និងការខ្ជីខ្ជា។
- ប្រសិនបើមានភស្តុតាងបញ្ជាក់ថាការខូចខាត នោះបណ្តាលមកពីករណីប្រធានសក្តិ ទំនិញខូចស្រាប់លើកលែងតែមានខចែងក្នុងកិច្ចសន្យាដឹកជញ្ជូន។

### ២.ការទទួលខុសត្រូវរបស់អ្នកបញ្ជូន ឬអ្នកទទួល

អ្នកបញ្ជូនត្រូវអនុវត្តកាតព្វកិច្ចដូចដែលមានចែងក្នុងកិច្ចសន្យាលក់ទិញរបស់ខ្លួន និងមានកាតព្វកិច្ចផ្ទៀងផ្ទាត់ទំនិញដែលត្រូវបានដឹកជញ្ជូនជាមួយអ្នកដឹកជញ្ជូន ដើម្បីបញ្ជាក់ថាទំនិញនោះជាទំនិញស្របច្បាប់។ ក្នុងករណីដែលអ្នកបញ្ជូនដាក់ទំនិញដែលមានគ្រោះថ្នាក់ទៅឱ្យអ្នកដឹកជញ្ជូនដោយមិនបានប្រាប់ពីសភាពជាក់លាក់របស់ទំនិញ អ្នកបញ្ជូនត្រូវសងសំណងនៃការខូចខាតទៅអ្នកដឹកជញ្ជូន នូវការខូចខាតដែលអ្នកដឹកជញ្ជូនទទួលរង។ អ្នកបញ្ជូនត្រូវសងសំណាងនៃការខូចខាតទៅអ្នកដឹកជញ្ជូន ក្នុងករណីដែលទំនិញខូចគុណភាព ហើយម្ចាសទំនិញមិនបានប្រាប់ពីសភាពនៃទំនិញនោះ នាំឱ្យប៉ះពាល់ដល់មធ្យោបាយដឹកជញ្ជូន ឬតតិយជន ។[33] អ្នកដឹកជញ្ជូននៅតែទទួលខុសត្រូវ ចំពោះតតិយជនដែលរងគ្រោះដោយសារទំនិញដែលខូចគុណភាពនោះ ប៉ុន្តែបន្ទាប់ពីអ្នកដឹកជញ្ជូនបានសងការខូចខាតទៅតតិយជនរួច អ្នកដឹកជញ្ជូនអាចទាមទារសំណាងពីអ្នកបញ្ជូនវិញបាន។

[33] សេចក្តីព្រាងច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម, តុលា ២០០៩, មាត្រា១៧២។

## ផ្នែកទី២៖ វិធានការនៃការសងសំណង

ប្រសិនបើទំនិញនោះខុសពីអ្វីដែលបាននិយាយគ្នាទាំងចំនួន ទាំងគុណភាព និងទាំងលក្ខណៈនៃទំនិញនោះមិនស្របទៅនឹងវិធីប្រើធម្មតានៃទំនិញប្រភេទដូចគ្នារួមទាំង ការវេចខ្ចប់ខុសពីការវេចខ្ចប់ធម្មតាក៏ជាវិការៈដែរ។[34] ក្នុងករណីនេះ អ្នកទិញត្រូវទទួលបានការទទួលខុសត្រូវក្នុងការធានាពីអ្នកលក់ចំពោះទំនិញមានវិការៈ ម្យ៉ាងទៀតអ្នកទិញអាចទាមទារសំណងនៃខូចខាតនេះបាន។[35] លក្ខខណ្ឌនៃការទទួលខុសត្រូវក្នុងការសងសំណងក្នុងការខូចខាត ដែលចែងពីការមិនអនុវត្តកាតព្វកិច្ច។ ម្ចាស់បំណុលអាចទារសំណងការខូចខាតដែលកើតចេញមកពីការមិនអនុវត្តកាតព្វកិច្ច ឬប្រតិបត្តិតាមកិច្ចសន្យាបណ្ដាលឱ្យមានព្យសនកម្មដល់ជនរងគ្រោះ។

អ្នកទិញអាចទាមទារការអនុវត្តពេញលេញពីអ្នកលក់មានដូចជា៖

- ការប្រគល់នូវវត្ថុជំនួស
- ជួសជុសវិការៈ
- ការរំលាយកិច្ចសន្យា
- ការកាត់បន្ថយតម្លៃស្របតាមកិច្ចសន្យា។[36]

ការប្រគល់នូវវត្ថុជំនួស គឺនៅពេលដែលកម្មវត្ថុនៃកិច្ចសន្យាទិញមានវិការៈ អ្នកលក់ត្រូវមានកាតព្វកិច្ចក្នុងការប្រគល់វត្ថុជំនួស ដែលគ្មានវិការៈទៅឱ្យអ្នកទិញសុចរិត និងគ្មានកំហុសធ្ងន់ធ្ងរ។ ករណីដៃ ភាគី "ក" បានទិញផ្លែប៉ោម ២ គីឡូពីភាគី "ខ" ទៅដល់ផ្ទះពុះទៅស្អុយ១ គីឡូ ដូច្នេះភាគី "ខ" មានកាតព្វកិច្ចប្ដូរផ្លែប៉ោមថ្មីទៅឱ្យភាគី "ក"។ ប៉ុន្តែប្រសិនបើការប្រគល់វត្ថុជំនួសនោះ ទាមទារឱ្យមានការរៀបចំឱ្យមានវត្ថុដែលមានប្រភេទដូចគ្នាវានឹងបង្កើតនូវបន្ទុក និងលំបាកបើសិនវត្ថុនោះមិនអាចជំនួសបាន ដូចជារូបគំនូរដែលជាស្នាដៃវិចិត្រករហើយមានតែ ២ ឬ៣ផ្ទាំងក្នុងលោក វានិងពិបាកសងជំនួស។ ហេតុដូចនេះអ្នកលក់មានករណីយកិច្ចសងសំណងនៃការខូចខាតទៅឱ្យអ្នកទិញ។ អ្នកលក់មានករណីយកិច្ចជួសជុសលើវត្ថុមានវិការៈ ប៉ុន្តែបើវាពិបាកនិងជួសជុសអ្នកលក់អាចសងសំណងខូចខាតទៅអ្នកទិញ។ ការរំលាយកិច្ចសន្យាអាចធ្វើបាន ប្រសិនបើភាគីមិនអាចសម្រេចគោលបំណងនៃកិច្ចសន្យានោះបាន ដោយសារវត្ថុដែលត្រូវបានប្រគល់មានវិការៈ ភាគីអាចធ្វើការរំលាយកិច្ចសន្យាបាន ប្រសិនបើអ្នកទិញសុចរិត និងគ្មានកំហុស។ អ្នកទិញអាច

---

[34] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ៥៣៩ ។

[35] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ៣៩៨។

[36] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ៥៤០។

ទាមទារឱ្យអ្នកលក់បន្ថយថ្លៃទៅតាមសមាមាត្រនៃវត្ថុនៅពេលដែលវត្ថុវិការៈខុសនឹងវត្ថុដើម តាមរយៈគោលការណ៍នៃការទាមទារសំណងនៃការខូចខាត។

### កថាខណ្ឌ១៖ សំណងនៃការខូចខាត

សំណងនៃការខូចខាតនោះ គឺជាការខូចខាតដែលបណ្តាលមកពីការមិនអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យា។ បើកូនបំណុលមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ម្ចាស់បំណុលអាចទាមទារសំណងដែលកើតមានឡើង។[37]

#### ១.លក្ខខណ្ឌទូទៅ

ដោយសារតែកូនបំណុលមិនបានអនុវត្តកាតព្វកិច្ច ម្ចាស់បំណុលអាចទាមទារសំណងនៃការខូចខាតបានដោយសារការមិនអនុវត្តកាតព្វកិច្ច។ ករណីដែលកូនបំណុលប្រើតតិយជនឲ្យអនុវត្តកាតព្វកិច្ចជំនួស អ្នកជំនួសខកខាតមិនបានបំពេញកាតព្វកិច្ចកូនបំណុលត្រូវសងសំណងការខូចខាតដែលបានកើតឡើងនោះ។ ករណីដែលភាគី "**ក**" ជាម្ចាស់ហាងកែសម្ផស្សបានបញ្ជាឱ្យ ភាគី "**ខ**" ដឹកឡេទៅឱ្យអតិថិជនភាគី "**គ**" ប៉ុន្តែដោយសារតែភាគី "**ខ**" មិនដឹងក៏បានដាក់ឡេនោះក្រោមកម្តៅថ្ងៃពេញមួយថ្ងៃធ្វើឱ្យឡេនោះខូចនិងបាត់បង់ប្រសិទ្ធភាព។ ដូច្នេះភាគី "**ក**" ត្រូវសងសំណងខូចខាតទៅឲ្យភាគី "**គ**" ពីព្រោះភាគី "**ខ**" ជាអ្នកជំនួយរបស់ភាគី "**ក**"។ ប៉ុន្តែបើកូនបំណុលបង្ហាញថា ការមិនអនុវត្តកាតព្វកិច្ចមិនមែនដោយសារកំហុសរបស់ខ្លួន គាត់គ្មានកំហុសក្នុងការទទួលខុសត្រូវទេ។ ករណីដែលភាគី "**ក**" បានរស់នៅខេត្តបាត់ដំបងបានទិញថ្នាំពេទ្យមួយកេសពីភាគី "**ខ**" នៅភ្នំពេញហើយក៏បានឲ្យភាគី "**ខ**" យកថ្នាំពេទ្យមួយកេសនោះ យកទៅផ្ញើតាមក្រុមហ៊ុនមួយឲ្យដឹកទៅបាត់ដំបង ប៉ុន្តែក្រុមហ៊ុនបានខកខាតយកថ្នាំពេទ្យនោះទៅឱ្យភាគី "**ខ**" តាមថ្ងៃកំណត់ដូចនេះ ក្រុមហ៊ុននោះជាអ្នកមានកាតព្វកិច្ចក្នុងការទទួលខុសត្រូវក្នុងករណីដែលមានវិការៈកើតឡើង។ សេចក្តីព្រាងច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្មក៏បានចែងថា អ្នកដឹកជញ្ជូនមានកាតព្វកិច្ចដឹកទំនិញដល់គោលដៅ និងទទួលខុសត្រូវលើទំនិញខូចខាតដែលបណ្តាលមកពីការដឹកជញ្ជូននោះ។ នៅពេលកិច្ចសន្យាដឹកជញ្ជូនបានប្រគល់ដល់អ្នកដឹកជញ្ជូនផ្សេងទៀតនោះត្រូវចាត់ទុកថាភាគីនៃកិច្ចសន្យាត្រូវអនុវត្តកាតព្វកិច្ចទាំងស្រុង។ ក្នុងករណីមានការដឹកជញ្ជូនបន្ត ឬការដឹកជញ្ជូនផ្សំគ្នា ភាគីកិច្ចសន្យាអាចទាមទារអ្នកដឹកជញ្ជូនដែលមានចុះកិច្ចសន្យា ឬអ្នកដឹកជញ្ជូនចុងក្រោយទទួលខុសត្រូវលើសកម្មភាពការដឹកជញ្ជូនរបស់ខ្លួន។

---

[37]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ៣៩៨ ។

ម្ចាស់បំណុល អាចទាមទារសំណងនៃផលប្រយោជន៍ដែលទទួលបានពីកិច្ចសន្យារហូតមកដល់ពេលនេះរាល់ការចំណាយលើបន្ទុកផ្សេង ដែលបង្កើតឡើងដោយសារមិនអនុវត្តកាតព្វកិច្ច។ ម្ចាស់បំណុលក៏អាចទាមទារសំណងខាងផ្លូវចិត្ត ទៅតុលាការបង្គាប់ឲ្យកូនបំណុលជួសជុសបានដែរ។

### ២.ទំហំនៃសំណងនៃការខូចខាត

សំណងនៃការខូចខាតមានពីរប្រភេទ គឺការខូចខាតធម្មតា និងការខូចខាតពិសេស។[38]

ការខូចខាតធម្មតា គឺសំដៅដល់ការខូចខាត ដោយសារការមិនអនុវត្តកាតព្វកិច្ច។ ដូចច្នេះកូនបំណុលត្រូវជួសជុសទៅតាមទំហំនៃព្យសនកម្មដូចជា ការខូចបាត់បង់របស់ម្ចាស់បំណុលកើតពីការមិនអនុវត្តកាតព្វកិច្ច។ ការខូចខាតពិសេស គឺការខូចខាតដែលកើតឡើងចំពោះម្ចាស់បំណុលដោយសារកាលៈទេសៈពិសេស បើគូភាគីនៃកិច្ចសន្យាអាចព្យាករនៃការខូចខាតអាចកើតមានឡើងនៅពេលដែលធ្វើកិច្ចសន្យា ហើយភាគីទាំងសងខាងអាចព្យាករពីការកើតឡើងនៃការខូចខាតពិសេស។ ប៉ុន្តែបើមិនអនុវត្តតាមកាតព្វកិច្ច ឬមានការខូចខាតផ្នែកខ្លះម្ចាស់បំណុលជាអ្នកបង្កឡើងតុលាការអាចបន្ថយចំនួននៃសំណង ការខូចខាតនោះបាន។ តុលាការមិនអាចបន្ថែម ឬបន្ថយចំនួននៃសំណងបានទេ បើគូភាគីបានធ្វើការសន្យាពិសេស លុះត្រាតែចំនួនទឹកប្រាក់ដែលបានសន្យាច្រើន ឬតិចធៀបទៅព្យសនកម្ម។

### ៣.អាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយកិច្ចសន្យា

នៅពេលដែលការមិនអនុវត្តកាតព្វកិច្ចណាមួយកើតមានឡើង ម្ចាស់បំណុលអាចអនុវត្តវិធីសង្គ្រោះជាច្រើនដូចជា ការទាមទារឲ្យអនុវត្តកាតព្វកិច្ចដោយបង្ខំ សំណងនៃការខូចខាត និងការរំលាយនៃកិច្ចសន្យា។ វិធីសង្គ្រោះនីមួយៗដែលបំពានកិច្ចសន្យា សុទ្ធតែមានច្បាប់កំណត់អំឡុងពេលនៃការរំលត់អាជ្ញាយុកាល។ អាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយកិច្ចសន្យាដោយសារតែកូនបំណុលមិនអនុវត្តកាតព្វកិច្ច ម្ចាស់បំណុលមានសិទ្ធិទាមទារបដិទាន ក្នុងអំឡុងពេល១ឆ្នាំក្រោយកូនបំណុលមិនអនុវត្តកាតព្វកិច្ច។

ចំណុចនៃការគណនាអំឡុងពេល

- ពេលដែលកូនបំណុលមិនបានអនុវត្តកាតព្វកិច្ច
- នៅពេលអលទ្ធភាពក្នុងការអនុវត្ត នៅពេលយឺតយ៉ាវក្នុងការអនុវត្ត

[38] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ៤០១។

អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យសងការខូចខាត ត្រូវអនុវត្តតាមគោលការណ៍ទូទៅនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ហើយអំឡុងពេលនៃអាជ្ញាយុកាលរំលត់គឺ ៥ឆ្នាំ គិតចាប់ពីពេលដែលអនុវត្តសិទ្ធិនោះ។[39] ការទាមទារសំណងនៃការខូចខាតដោយសារការមិនអនុវត្តកាតព្វកិច្ច អំឡុងពេលអាជ្ញាយុកាលរំលត់ ត្រូវចាប់ផ្តើមគិតនៅពេលដែលការខូចខាតនោះកើតឡើង មិនមែននៅពេលដែលការមិនអនុវត្តកាតព្វកិច្ចនោះកើតឡើងទេ។

## ផ្នែកទី៣៖ នីតិវិធីក្នុងការប្តឹងទាមទារ

ជាទូទៅនៅពេលដែលមានវិវាទកើតឡើងដោយសារតែការរំលោភបំពានកិច្ចសន្យា ឬអំពើអនីត្យានុកូល ភាគីទាំងសងខាងតែតែងរកមធ្យោបាយដើម្បីដោះស្រាយវិវាទទាមទារសំណង និងព្យសនកម្ម។ ក្នុងករណីខ្លះ ភាគីទាំងសងខាងអាចប្រើវិធីសាស្ត្រដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ប៉ុន្តែនៅពេលដែលមិនអាចចរចា ឬសម្របសម្រួលគ្នាបានទេ ភាគីអាចជ្រើសរើសមធ្យោបាយមួយទៀតគឺ ការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ ។ នៅពេលដែលដើមបណ្តឹងចង់ប្តឹងទាមទារសំណង ដើម្បីទាមទារឲ្យតុលាការចេញសាលក្រម ឬសាលដីកាតាមការទាមទាររបស់ខ្លួន តើដើមបណ្តឹងត្រូវប្តឹងទៅតុលាការមួយណា? តើតុលាការមួយណាដែលមានសមត្ថកិច្ចទទួលពាក្យបណ្តឹង?

### កថាខណ្ឌ១៖ សមត្ថកិច្ចតុលាការ

សមត្ថកិច្ចតុលាការបែងចែកជា សមត្ថកិច្ចតាមភារកិច្ច និងសមត្ថកិច្ចតាមដែនដី។[40] សមត្ថកិច្ចតាមភារកិច្ច គឺជាការកំណត់នូវការទទួលបន្ទុកតាមមុខងារនៃសិទ្ធជម្រះក្តីនៃតុលាការប្រភេទនីមួយៗដោយសិទ្ធជម្រះក្តីរបស់តុលាការជាន់ខ្ពស់ និងជាន់ទាប។ នៅពេលដែលមានវិវាទកើតឡើង ដើមចោទត្រូវដាក់ពាក្យបណ្តឹងទៅតុលាខេត្ត ក្រុង។

សមត្ថកិច្ចតាមដែនដី គឺកំណត់ថានៅពេលមានរឿងក្តីមួយ និងវិវាទកើតឡើង តើរឿងក្តីមានទំនាក់ទំនងជិតស្និទ្ធនៅទីកន្លែងណាមួយ នឹងសមត្ថកិច្ចរបស់តុលាការណា ? ដោយពាក្យបណ្តឹងនោះអាចដាក់ទៅសាលដំបូងដែលមានសមត្ថកិច្ចនៅទីកន្លែងកើតហេតុ ដូចជាលំនៅឋានចុងចម្លើយប្រសិនបើចុងចម្លើយជារូបវន្តបុគ្គល ឬអាចត្រូវបានដាក់ទៅសាលដំបូងដែលមានសមត្ថកិច្ច

[39] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ៤៨០ ។

[40] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី (ភ្នំពេញ,ក្រសួងយុត្តិធម៌ ២០១១), ១៖១៤។

នៅទីកន្លែង ដូចជាទីតាំងនៃទីស្នាក់ ឬទីកន្លែងអាជីវកម្មជាចម្បងជាអាទិ៍។[41] ប្រសិនបើចុងចម្លើយជានីតិបុគ្គលកម្ពុជា ឬអាចត្រូវបានដាក់ទៅសាលដំបូងដែលមានសមត្ថកិច្ចនៅដូចជាទីតាំងនៃទីស្នាក់ការ ឬទីកន្លែងអាជីវកម្មជាចម្បងក្នុងប្រទេសកម្ពុជា ប្រសិនបើចុងចម្លើយជានីតិបុគ្គលបរទេស ដោយពុំគិតពីលក្ខខណ្ឌខ្លឹមសាររឿងក្តីឡើយ។ ជនដែលមានគោលបំណងដាក់ពាក្យបណ្តឹង អាចជ្រើសរើសតុលាការណាមួយពីក្នុងចំណោមតុលាការទាំងនោះដោយសេរីបាន ដោយគិតដល់ទំនាក់ទំនងរវាងទីកន្លែង និងសកម្មភាពជំនួញ ឬអំពើអនីត្យានុកូលរបស់ចុងចម្លើយ ដើម្បីផ្តល់នូវផលប្រយោជន៍ក្នុងការឆ្លើយតបរបស់ចុងចម្លើយ ឬសម្រួលក្នុងការវិនិច្ឆ័យបណ្តឹង តាមរយៈចំណាងទៅទីកន្លែងនៃភស្តុតាង។[42]

### កថាខណ្ឌ២៖ ការគណនាសំណងនៃការខូចខាត

ដើម្បីទាមទារសំណងនៃការខូចខាត ឬឲ្យកូនបំណុលទទួលខុសត្រូវនូវការសង លុះត្រាកូនបំណុលមិនអនុវត្តកាតព្វកិច្ច មានកំហុសក្នុងការអនុវត្តកាតព្វកិច្ច និងការខូចខាត។ ហើយដើម្បីគណនាសំណងនៃការខូចខាត ត្រូវវែកញែកជាមុន អំពីការខូចខាតទាំងអស់ដែលជាបន្ទុករបស់ម្ចាស់បំណុល និងសំណងការខូចខាតដែលម្ចាស់បំណុលអាចទាមទារបាន។ ត្រូវតែកំណត់ទំនាក់ទំនងហេតុផល ដើម្បីឲ្យការសងសំណងនៃការខូចខាតក្នុងកម្រិតសមហេតុផលមួយ។

#### ១.សំណងនៃការខូចខាតផ្នែកសម្ភារៈ

##### ១.១.ការខូចខាតទាំងអស់ដែលជាបន្ទុករបស់ម្ចាស់បំណុល

ម្ចាស់បំណុលអាចទាមទារសំណងនៃការខូចខាត គឺទាមទារផលប្រយោជន៍ពីការអនុវត្តកាតព្វកិច្ចដែលខ្លួនត្រូវទទួលបានតាមកិច្ចសន្យានោះ។[43] សំណងដែលម្ចាស់បំណុលអាចទាមទារបានមានដូចជា ៖

- ផលប្រយោជន៍ពីការអនុវត្ត ដែលបានស្មានទុកភាគីម្ខាងទទួលបានផលប្រយោជន៍ក្នុងករណីបើភាគីម្ខាងទៀត អនុវត្តកាតព្វកិច្ច។

---

[41] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខនស/រកម/០៧០៦/០២១,៦០៦ កក្កដា ២០០៦, មាត្រា៨ (ពីពេលនោះទៅហៅថា ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦) ។

[42] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ៩។

[43] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ៤០០ ។

- សោយហ៊ុយចំណាយដែលគ្មានប្រយោជន៍ពីការចំណាយផ្សេងៗដែលជាបន្ទុករបស់ម្ចាស់បំណុលទាក់ទងនឹង ការបង្កើតកិច្ចសន្យា។
- បន្ទុកដែលកើន ដោយសារតែការចំណាយផ្សេងៗទៀតដែលម្ចាស់បំណុលបានចេញដោយសារការមិនអនុវត្តកាតព្វកិច្ចរបស់ម្ចាស់បំណុល។

### ១.២.សំណងនៃការខូចខាតដែលម្ចាស់បំណុលអាចទាមទារបាន

ច្បាប់ក៏បានកំណត់អំពីសំណងនៃការទាមទារការខូចខាត ត្រូវមានកម្រិតហើយសមហេតុផលដោយម្ចាស់បំណុលមិនអាចទារទាមសំណងនៃការខូចខាតបានតាមចិត្តឱ្យកូនបំណុល សងដោយគ្មានហេតុផលនិងហួសកម្រិតនោះទេ។ ក្រមរដ្ឋប្បវេណី មាត្រា៤០១ ក៏បានកំណត់អំពីទំហំនៃការសងសំណងនៃការខូចខាតដូចជា ៖

- សំណងនៃការខូចខាតធម្មតា
- ការខូចខាតពិសេស
- ផលប្រយោជន៍ក្រៅពីសំណងនៃការខូចខាត។

### ១.៣.ការគណនាផលប្រយោជន៍

ម្ចាស់បំណុល អាចទាមទារសំណងនៃការខូចខាតដែលជាផលប្រយោជន៍ ដែលបាត់បង់ដោយសារការមិនអនុវត្តកាតព្វកិច្ចរបស់កូនបំណុល។[44] ផលប្រយោជន៍ដែលម្ចាស់បំណុលបាត់បង់នោះគឺ ការបាត់បង់តម្លៃនៃកម្មវត្ថុ និងតម្លៃនៃការប្រើប្រាស់កម្មវត្ថុ។

#### ១.៣.១.ការគណនាតម្លៃនៃកម្មវត្ថុដែលបាត់បង់

(១) ការគណនាសំណងនៃការខូចខាតជាក់ស្តែងក្នុងករណីកម្មវត្ថុបាត់បង់រូបមន្តនៃគណនា ៖

*តម្លៃទីផ្សារ-តម្លៃក្នុងកិច្ចសន្យា=ចំនួននៃការសងសំណង*

(២) ក្នុងករណី ម្ចាស់បំណុលមានគោលបំណងលក់នៅកម្មវត្ថុបន្ត រូបមន្តនៃការគណនា ៖

*តម្លៃនៃការលក់បន្ត-តម្លៃក្នុងកិច្ចសន្យា=ចំនួននៃការខូចខាត*

(៣) ក្នុងករណីយម្ចាស់បំណុលទិញវត្ថុជំនួសពីតតិយជន រូបមន្តនៃគណនា ៖

*តម្លៃទិញវត្ថុជំនួសនៃកម្មវត្ថុ-តម្លៃក្នុងកិច្ចសន្យា=ចំនួននៃការខូចខាត។*[45]

[44] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ៤០០ ។

### ១.៣.២.ការគណនាតម្លៃនៃការប្រើប្រាស់ដែលបានបាត់បង់

ក្នុងករណីម្ចាស់បំណុលមានបំណងប្រើប្រាស់កម្មវត្ថុសម្រាប់រកផលប្រយោជន៍ ការគណនាគឺប្រាក់ចំណូលដែលបាត់បង់។ បើម្ចាស់បំណុលបានចំណាយសោហ៊ុយជំនួសការប្រើប្រាស់កម្មវត្ថុ ការគណនាចំនួនសងគឺ ចំនួនសោហ៊ុយសម្រាប់ប្រើប្រាស់។

### ២.ការខូចខាតនៃផ្លូវចិត្ត

ក្រៅពីសំណងនៃការខូចខាតសម្ភារៈ ក្រមរដ្ឋប្បវេណីកម្ពុជា ការបានចែងអំពីសំណងនៃការខូចខាតខាងផ្លូវចិត្ត ក្នុងករណីបំពានកិច្ចសន្យា។ សំណងនៃការខូចខាតខាងផ្លូវចិត្ត គឺជាការខូចខាតទាំងឡាយណា ដែលប៉ះពាល់ដល់សិទ្ធិក្រៅបេតិកភណ្ឌរបស់បុគ្គល ដូចជា កិត្តិយស ឈ្មោះ ជីវភាពឯកជន មនោសញ្ចេតនា ដូចជាទុកព្រួយដែលបណ្តាលឱ្យបាត់បង់អ្វីជាទីស្រលាញ់ ធ្វើឱ្យប៉ះពាល់ដល់ផ្លូវចិត្ត។ ម្ចាស់បំណុលអាចទាមទារសំណងនៃការខូចខាតផ្លូវចិត្ត ដោយផ្អែកលើការបង្គាប់តុលាការ។

ក្នុងករណីដែលភាគី "ក" បានទិញឡេលាបខ្លួនក្នុងគោលបំណងលាបទៅឱ្យសមុនថ្ងៃរៀបការរបស់ខ្លួនពី ភាគី "ខ" ហើយភាគី "ក" ក៏បានធានាថា និងស ផ្ទុយទៅវិញ ក្រោយពីភាគី "ក" លាបឡេនោះ ហើយមិនបានស្បែកស បែរជាប្រតិកម្មទៅវិញ ដោយសារតែដាក់ឡេមិនត្រូវតាមអ្វីដែលអ្នកទិញបានចុះនៅក្នុងកិច្ចសន្យា។ ក្នុងករណីនេះ ក្រៅពីសំណងនៃការខូចខាត ដែលបណ្តាលមកពីការមិនអនុវត្តកាតព្វកិច្ចរបស់ភាគី "ខ" នោះភាគី "ក" ក៏អាចទាមទារសំណងជម្ងឺចិត្តបានដែល។

ការទាមទារសំណងនៃការខូចខាតខាងផ្លូវចិត្ត ក៏មិនខុសពីការទាមទារនៃការខូចខាតសម្ភារៈនោះទេ។ ការខូតខាតខាងផ្លូវចិត្តនេះវាពុំបានមានការកំណត់ច្បាស់ពីចំនួនសងនោះទេពីព្រោះការខូចខាតមិនអាចប៉ាន់ស្មានបាន ឬកំណត់បាននោះទេ ប៉ុន្តែគំនិតទូទៅ វាត្រូវបានកំណត់ដោយចៅក្រម ដោយធ្វើការពិចារណាទៅលើស្ថានភាពជាក់ស្តែង កម្រិត ឬប្រភេទនៃការខូចខាតផ្លូវចិត្ត។

[45] ក្រសួងយុត្តិធម៌និងទីភ្នាក់ងារសហប្រតិបត្តិការណ៍អន្តរជាតិនៃជប៉ុន,"មេរៀនស្តីពីក្រមរដ្ឋប្បវេណីនិងក្រមនីតិវិធីរដ្ឋប្បវេណី,"(ភ្នំពេញ,វិច្ឆិកា ២០១៦), ២៖២០៧។

## កថាខណ្ឌ៣៖ ការចាប់បង្ខំ និង អនុភាព

ក្នុងករណីដែលកូនបំណុលដែលមិនបានអនុវត្តកាតព្វកិច្ច ដែលបណ្តាលមកពីមូលហេតុផ្សេងៗ ដូចជា ៖

១. ការយឺតយាវក្នុងការអនុវត្ត

២. អលទ្ធភាពនៃការអនុវត្ត

៣. ការអនុវត្តមិនពេញលេញ

៤. ករណីផ្សេងទៀត ដែលមានការអនុវត្តតាមខ្លឹមសារអនុវត្តកាតព្វកិច្ច។

ម្ចាស់បំណុលអាចចាប់បង្ខំឱ្យកូនបំណុលអនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយបង្ខំតាម នីតិវិធីនៃច្បាប់បាន។ ការឱ្យអនុវត្តកាតព្វកិច្ចដោយបង្ខំ គឺជាការបង្ខំកូនបំណុលឱ្យអនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយបង្ខំដោយនីតិវិធីរបស់តុលាការ។[46]

### ១.ប្រភេទនៃការអនុវត្តដោយបង្ខំ

ប្រសិនបើកូនបំណុលមិនអនុវត្តកាតព្វកិច្ចដោយស្ម័គ្រចិត្ត នោះម្ចាស់បំណុលអាចបង្ខំឱ្យកូនបំណុលអនុវត្តកាតព្វកិច្ចទៅតាមនីតិវិធីអនុវត្តដោយបង្ខំ។ ភាគីដែលដាក់ពាក្យសុំហៅថាម្ចាស់បំណុលនៃការអនុវត្ត ឯភាគីម្ខាងទៀតត្រូវហៅថា កូនបំណុលនៃការអនុវត្ត។ ការដាក់ពាក្យសុំឱ្យអនុវត្តបង្ខំត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និង មានបញ្ជាក់ចំណុចដូចក្នុងក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា៣៤៩កថាខណ្ឌ២។ ហើយនីតិវិធីអនុវត្តដោយបង្ខំមាន ០៣ប្រភេទ គឺ ការអនុវត្តដោយផ្ទាល់ ការអនុវត្តដោយជំនួស និងការអនុវត្តដោយប្រយោល។

### ១.១.ការអនុវត្តដោយផ្ទាល់

ភាគីដែលឈ្នះក្តីដោយសាលក្រម អាចយកសាលក្រមដែលស្ថាពរទៅឱ្យកូនបំណុលអនុវត្តបាន។ នេះគឺជាវិធីធ្វើឱ្យសម្រេចនូវកម្មវត្ថុនៃការអនុវត្តកាតព្វកិច្ចដោយផ្ទាល់ ដោយស្ថាប័នអនុវត្តដែលមានភាពសមរម្យចំពោះការអនុវត្តកាតព្វកិច្ចដូចជា ការបង់ប្រាក់ និង ការប្រគល់វត្ថុ។ ដោយ

[46] ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទថៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ,*សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី*,កែសម្រួលលើការបោះពុម្ពលើកទី១(ភ្នំពេញ៖ មេសា ឆ្នាំ២០១៣(,១៖១៦១-១៦២។

សារតែវិធីនៃការអនុវត្តនេះមិនតម្រូវឱ្យមានការចូលរួមសហការពីសំណាក់កូនបំណុលដោយសកម្មទេ ដូច្នេះវាមិនមានភាពចាំបាច់ក្នុងការដាក់សម្ពាធទៅលើរូបរាយកាយ និងឆន្ទៈសេរីរបស់កូនបំណុល។

### ១.២.ការអនុវត្តជំនួស

នៅពេលដែលមានសេចក្តីសម្រេចតុលាការចូលជាស្ថាពរហើយ នោះម្ចាស់បំណុលអាចសម្រេចនូវសិទ្ធិទាមទាររបស់ខ្លួនដែលត្រូវធ្វើឡើងដោយខ្លួនគាត់ផ្ទាល់ ឬ តតិយជនឱ្យធ្វើជំនួសក្នុងនាមជាកូនបំណុល និង ដើម្បីប្រមូលសោហ៊ុយពីកូនបំណុល ។[47] វិធីនេះមានលក្ខណៈសមរម្យចំពោះការអនុវត្តកាតព្វកិច្ចដែលមិនសមរម្យ សម្រាប់ស្ថាប័នអនុវត្តក្នុងការអនុវត្តដោយផ្ទាល់ ប៉ុន្តែមានលក្ខណៈថាទោះបីជាកូនបំណុលផ្ទាល់ មិនបានធ្វើឱ្យសម្រេចនូវកម្មវត្ថុនៃកាតព្វកិច្ច ក៏ការដែលអាចធ្វើឱ្យសម្រេចនូវអានុភាពដូចគ្នា គឺមានលក្ខណៈគ្រប់គ្រាន់ម្ចាស់បំណុលដែរ ដូចជាកាតព្វកិច្ចធ្វើសកម្មភាពជំនួសជាដើម។

### ១.៣.វិធានបង្ខំដោយប្រយោល

វីធីបង្ខំដោយប្រយោល គឺជាវិធីដាក់សម្ពាធខាងផ្លូវចិត្តសាស្ត្រទៅលើកូនបំណុល ដើម្បីបង្ខំឱ្យអនុវត្តកាតព្វកិច្ច ។ ចំពោះវិធានការនេះ មធ្យោបាយបង្គាប់ឱ្យបង់សំណងនៃការខូចខាត ការដាក់ទណ្ឌកម្មពី សំណាក់រដ្ឋាភិបាល ការដាក់ទណ្ឌកម្ម ឬ ការដាក់ពន្ធធនាគារ ជាអាទ៍ ត្រូវបានយកមកអនុវត្ត។ ចំពោះការអនុវត្តដោយបង្ខំទៅលើ រូបរាងកាយ និងឆន្ទៈសេរីរបស់កូនបំណុល គឺមានលក្ខណៈខ្លាំងជាងការអនុវត្តដោយផ្ទាល់។

[47] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខនស/រកម/០៧០៦/០២១,៦០៦ កក្កដា ២០០៦, មាត្រា៥២៧។

# ជំពូកទី៣

# ការទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌ
# នៅលើទំនិញដែលខូចគុណភាព

# ជំពូកទី៣៖
# ការទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌទៅលើទំនិញដែលខូចគុណភាព

## ផ្នែកទី១៖ ការបង្ក្រាបការក្លែងបន្លំ

កន្លងមករាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់ចេញនូវអនុក្រឹត្យ និងលិខិតបទដ្ឋានមួយចំនួនដែលពាក់ព័ន្ធនឹងការគ្រប់គ្រង សុវត្ថិភាព លើផលិតផលទំនិញ ជាពិសេសផលិតផលចំណីអាហារដែលនាំចូលពីបរទេស និងផលិតផលក្នុងស្រុកមួយចំនួន ដែលប្រើសារធាតុគីមី ដើម្បីក្លែងបន្លំគុណភាព។ មិនតែប៉ុណ្ណោះរាជរដ្ឋាភិបាលក៏មិនភ្លេចក្នុងការធានាការពារនូវគ្រប់ការនាំចូល និងការផលិតនូវផលិតផលឱសថដែលគ្មានគុណភាពផងដែល។

### កថាខណ្ឌ១៖ គោលបំណង

ដើម្បីធានាឲ្យបាននូវផលិតផលដែលមានគុណភាព និងគ្មានជាតិគីមីរួមទាំងដើម្បីការពារនូវកម្មសិទ្ធិបញ្ញាដល់ម្ចាស់នៃផលិតផលនោះផងដែរ រដ្ឋាភិបាលបានហាមឃាត់ជាដាច់ខាតនូវការក្លែងផលិតផលទំនិញដែលជាកម្មវត្ថុធ្វើពាណិជ្ជកម្ម ឬទុកសំរាប់ធ្វើពាណិជ្ជកម្ម ដោយធ្វើការកែច្នៃផលិតផលទំនិញតាមរបៀបណាមួយ ដោយធ្វើការបញ្ចូលបន្ថែមនូវសារធាតុដែលមានជាតិគីមី ឬសារធាតុលាយណាមួយ ដែរមិនសុទ្ធត្រឹមត្រូវតាមរូបមន្តដែលម្ចាស់ផលិតផលទំនិញពិតប្រាកដបានកំណត់ ការដកចេញនូវសារធាតុសុទ្ធរបស់ផលិតផល ទំនិញ ឬការប្តូរជំនួសនៃភាគណាមួយ ឬភាគទាំងមូលនៃផលិតផលទំនិញ ដែលប្រើធាតុសុទ្ធដោយជំនួសមកវិញនូវវត្ថុធាតុដែលខ្វះបរិមាណត្រឹមត្រូវ ឬក៏ជាវត្ថុដែលមានសារធាតុគីមី ដែលបំផ្លាញដល់សុខភាពរបស់មនុស្ស ដោយពុំត្រូវអនុញ្ញាតអោយធ្វើដោយបទប្បញ្ញត្តិនៃច្បាប់។ រដ្ឋាភិបាលក៏បានធ្វើការហាមឃាត់ចំពោះពាណិជ្ជករដែលបានធ្វើពាណិជ្ជកម្មនៃផលិតផលទំនិញណាមួយដោយដឹងថា ផលិតផលទំនិញនោះជាផលិតផលទំនិញក្លែងក្លាយ និងគ្មានគុណភាព ឬផ្ទុកនូវសារធាតុគីមីដែលត្រូវហាមឃាត់ជាដាច់ខាត[48]។

[48]ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញនិងសេវា,លេខ/រកម/០៦០០/០០១,២១ មិថុនា ២០០០, មាត្រា ១៧(ពីពេលនេះទៅហៅថា ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញនិងសេវា ឆ្នាំ២០០០)។

ធ្វើការហាមឃាត់ចំពោះផលិតផលម្ហូបអាហារ ដែលមានសភាពប្រែប្រួលខូចគុណភាពនៅពេលដែលទុកដាក់យូ ឬធ្វើការវិចខ្ចប់ ឬមានជាតិពុល ឬផលិតផលនោះមិនស្របនឹងលក្ខណៈវិនិច្ឆ័យគុណភាពផ្នែកអតិសុខុមជីវសាស្ត្រ ឬគ្មានអនាម័យត្រឹមត្រូវដែលត្រូវបានកំណត់តាមបទប្បញ្ញត្តិនៃក្រសួងនានាដែលពាក់ព័ន្ធ[49] ដូចជាក្រសួងពាណិជ្ជកម្ម ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាដើម។

ដោយឡែករាជរដ្ឋាភិបាលក៏បានហាមឃាត់ជាដាច់ខាតដោយមិនអនុញ្ញាតអោយ ភាគីចុះកិច្ចសន្យា រឺអ្នកមិនបានចុះកិច្ចសន្យាក្តី រួមទាំងការចុះកិច្ចសន្យាតាមតតិយជនក្តី ត្រូវបានហាមឃាត់ការក្លែងបន្លំ ឬការប៉ុនប៉ងក្លែងបន្លំតាមមធ្យោបាយ ឬវិធីណាក៏ដោយលើផលិតផល ទំនិញនិងសេវាចំពោះ៖

- អត្តសញ្ញាណ យថាប្រភេទ ប្រភេទ ប្រភព គុណភាពខាងរូបធាតុ ឬខាងទ្រទ្រង់រាងកាយ ធាតុផ្សំបរិមាណ
- កិច្ចត្រួតពិនិត្យដែលបានធ្វើ វិធីប្រើ សម្បទានចំពោះការប្រើប្រាស់គ្រោះថ្នាក់ភ្ជាប់នឹងការប្រើប្រាស់ ការប្រុងប្រយ័ត្នដែលត្រូវប្រកាន់យកនៃគ្រប់ផលិតផលទំនិញ
- វិធី និងកាលបរិច្ឆេទនៃការផលិត និងការប្រើប្រាស់ ឬនៃការបរិភោគរាល់បណ្តាលផលិតផលទំនិញ[50]។
- ហាមឃាត់ការធ្វើពាណិជ្ជកម្មនូវបណ្តាលផលិតផល និងឧបករណ៍ដែលសំដៅយកមកបំពេញកិច្ចបន្លំ ឬក្លែងមុខទំនិញទាំងឡាយ [51]។

### កថាខណ្ឌ២៖ មូលហេតុ

ដោយសារតែសព្វថ្ងៃប្រទេសកម្ពុជាមានការរីកចម្រើនខ្លាំងនាំឲ្យប្រជាពលរដ្ឋមានជីវភាពល្អប្រសើរ រួមទាំងមានកំណើនប្រជាជនច្រើន ដែលជាហេតុនាំឲ្យមានតម្រូវការកាន់តែច្រើនសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។ ទាំងអស់នេះជាមូលហេតុនៃការកើតឡើងនូវច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និងសេវា, ច្បាប់ស្តីពីការគ្រប់គ្រងឱសថ រួមទាំងច្បាប់មួយចំនួនទៀតដែលទាក់ទងទៅនឹងផលិតផលចំណីអាហារ និងទំនិញ។

---

[49] ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញនិងសេវាឆ្នាំ២០០០, មាត្រា ១៨។

[50] ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញនិងសេវាឆ្នាំ២០០០, មាត្រា ១៦។

[51] ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញនិងសេវាឆ្នាំ២០០០, មាត្រា ២០ ។

ក្នុងសង្គមបច្ចុប្បន្ន ក៏មានបញ្ហាជាច្រើនបានកើតឡើងដោយសារតែការក្លែងបន្លំទំនិញដែលគ្មានគុណភាព និងមានលាយនូវសារធាតុគីមីហួសកម្រិតសុវត្ថិភាព។

ដូចជាករណី ការបង្ក្រាបទីតាំងលក់ទឹកដោះគោម៉ាក MeiJi នៅខណ្ឌពោធិ៍សែនជ័យ ដែលជាការលក់នូវផលិតផលក្លែងក្លាយ។[52] នេះជាបញ្ហាជាក់ស្តែងមួយដែលបានកើតឡើងក្នុងសង្គម ដែលបណ្តាលអោយរាជរដ្ឋាភិបាល បង្កើតយន្តការក្នុងការបង្ក្រានូវរាល់បញ្ហាដែលទាក់ទងទៅនឹងទំនិញក្លែងក្លាយ ទំនិញគ្មានគុណភាព និងទំនិញដែលហួសពេលប្រើប្រាស់ឡើង។

### កថាខណ្ឌ៣៖ យន្តការក្នុងការបង្ក្រាប

ដើម្បីទប់ស្កាត់នូវការនាំចូលនូវផលិតផលខូចគុណភាព ឬគ្មានគុណភាពរាជរដ្ឋាភិបាលបានបង្កើតនូវច្បាប់ស្តីពីការគ្រប់គ្រងគុណភាពសុវត្ថិភាព លើផលិតផល ទំនិញនិងសេវាឡើងនៅថ្ងៃទី២១ខែមិថុនាឆ្នាំ២០០០។ ដែលបានសំដៅទៅលើផលិតកម្មសហគ្គាករណ៍ពាណិជ្ជកម្មនៃផលិតផលទំនិញដែលអាចបង្កអោយមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬអាចបង្កអោយមានគ្រោះថ្នាក់បន្ទាន់ ចំពោះសុខភាព ឬសុវត្ថិភាពដល់អ្នកប្រើ ដែរវាបានធ្វើអោយរដ្ឋាភិបាលមានការព្រួយបារម្ភយ៉ាងខ្លាំងហើយក៏បានបង្កើតនូវគណៈកម្មាការមួយឡើងដើម្បីទប់ស្កាត់នូវបញ្ហាទាំងអស់នេះ ហើយក្រសួងស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធអាចចាត់វិធានការទៅលើអ្នកផលិត ឬ ពាណិជ្ជករ ដែរធ្វើផ្ទុយនឹងច្បាប់ដូចជា ៖

- បញ្ឈប់ជាស្ថាពរ ឬរយៈពេលដែលកំណត់មួយសម្រាប់ ពាណិជ្ជករ ដែរបាននាំចូលនូវផលិតផលដែលមិនត្រឹមត្រូវតាមច្បាប់ ឬ ខុសនឹងបទប្បញ្ញាត្តិ
- បិទទ្វារគ្រឹះស្ថានផលិតជាបណ្តោះអាសន្ន ឬ ជាស្ថាពរ
- ក្នុងករណីចាំបាច់បន្ទាន់អាចធ្វើការឃាត់ទុកនៅនឹងកន្លែងរឹបអូស ឬបំផ្លាញចោលនូវផលិតផលទំនិញទាំងនោះបាន។

មន្ត្រីជំនាញក៏អាចធ្វើការបំផ្លាញចោល នូវផលិតផលណាដែរខូចគុណភាពដែលកម្លាំងមានសមត្ថកិច្ចបានរកឃើញថា ជាផលិតផលខូចគុណភាព ឬក៏គ្មានគុណភាពតាមបទដ្ឋានជាក់លាក់។ ប៉ុន្តែលុះត្រាតែមានការព្រមព្រៀងគ្នាជាមុន ដោយធ្វើឡើងជាលាយលក្ខណ៍អក្សររវាងអាជ្ញាធរមានសមត្ថកិច្ច និងម្ចាស់ផលិតផលទំនិញកើតហេតុនោះដោយវាជាការទុកពេលអោយម្ចាស់ផលិតផលនោះធ្វើការតវ៉ា ឬបញ្ជាក់ថាផលិតផលរបស់ខ្លួនខូចគុណភាពពិតមែន ឬក៏យ៉ាងណាភាគីម្ចាស់

[52] លាប សម្រិត, "ការបង្ក្រាបទីតាំងលក់ទឹកដោះគោម៉ាក Meiji នៅខណ្ឌពោធិ៍សែនជ័យ," (ភ្នំពេញ, ៤ កក្កដា ២០១៨) អាចរកបាននៅ http://chnchannel.com/chnnewws/146966 (ថតចម្លង ថ្ងៃទី ១០ កក្កដា ២០១៨)។

ផលិតផលទំនិញកើតហេតុ អាចប្តឹងទៅតុលាការខេត្តក្រុងក្នុងរយៈពេលដែលមានកំណត់ក្នុងវិធានការ ។ ផលិតកម្មសហគ្រាសកណ៍ពាណិជ្ជកម្មព្រមទាំងគ្រឹះស្ថាននានាដែលត្រូវបានបញ្ឈប់ ឬបិទទ្វារជាបណ្តោះអាសន្ន ដោយសារតែរកឃើញថាបានរក្សាទុក ចែកចាញ ឬ ផលិតនូវ ផលិតផលដែលគ្មានគុណភាពឬខូចគុណភាពទាំងនោះ អាចដំណើរការឡើងវិញបាន លុះត្រាតែមានការអនុញ្ញាតពីក្រសួងមានសមត្ថកិច្ច[53]។

រាជរដ្ឋាភិបាល បានធ្វើការផ្សព្វផ្សាយដើម្បីអោយប្រជាពលរដ្ឋមានការយល់ដឹងជ្រួតជ្រាបអំពីផលប៉ះពាល់ដល់សុខភាពអ្នកប្រើប្រាស់ ព្រមទាំងបានដឹកនាំកម្លាំងមានសមត្ថកិច្ចធ្វើការត្រួតពិនិត្យរកឃើញ និងបានធ្វើការកំទេចចោលនូវផលិតផលដែលខូចគុណភាព និងផលិតផលមួយចំនួនដែលប្រើប្រាស់សារធាតុគីមីហួសកំរិត។

> "ដូចជាករណី នំស្លឹកស្រស់ និងនំស្រួយ ដែលបានដាក់លក់នៅផ្សារអូរឫស្សី ចំនួនដល់ទៅ ៨៦គីឡូក្រាម ត្រូវបានសមត្ថកិច្ចកំទេចចោល បន្ទាប់ពីធ្វើតេស្តរកឃើញថាមាន សារធាតុគីមីហាមឃាត់ ដែលសង្ស័យមានហានិភ័យខ្ពស់។ នេះបើយោងតាមគណនីហ្វេសបុករបស់លោក គង់ វុទ្ធី បានឲ្យដឹងថា៖ នៅថ្ងៃ ចន្ទ ១៣ រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័កពស ២៥៦២ ត្រូវនឹងថ្ងៃទី១១ ខែ មិថុនា ឆ្នាំ២០១៨ បានអោយដឹងថា សកម្មភាពមន្ត្រីកាំកុងត្រូលផែស្វួតទីក្រុងភ្នំពេញ និងមន្ត្រីកុងត្រូលរាជធានីភ្នំពេញ សហការជាមួយមន្ត្រីមន្ទីរពាណិជ្ជកម្ម និងគណៈកម្មការផ្សារអូរឫស្សីខណ្ឌ៧មករា បានធ្វើការចុះត្រួតពិនិត្យទំនិញស្រាវជ្រាវរកនូវផលិតផលដែលមានផ្ទុកនូវសាធាតុគីមី និងទំនិញដែលខូចគុណភាព ដែលវាជាគោលការណ៍ទប់ស្កាត់នូវទំនិញខូចគុណភាព ដែល ជនខិលខូចមួយចំនួនលួច បញ្ចេញមកលក់ ចែកចាយ លើទីផ្សារ ពីសំណាក់រាជរដ្ឋាភិបាល។
>
> មន្ត្រីជំនាញបានធ្វើតេស្តបឋម រកសារធាតុគីមីហាមឃាត់ទៅលើទំនិញដែលសង្ស័យមានហានិភ័យខ្ពស់ដូចជា អំបិលអីយ៉ូដ សរសៃមីលឿង ប្រហិតសាច់គោ ជ្រក់ស្ពៃ ជ្រក់ត្រសក់ មឹក បង្គារ ត្រីងៀត ត្រីបង្ហើម សាច់ក្រក បាញ់កាញ់ លតគុយទាវសរសៃធំ គុយទាវសរសៃតូច គ្រឿងសមុទ្រនំស្លឹកស្រស់ នំស្រួយ។
>
> ជាលទ្ធផលមន្ត្រីដែលបានចុះទៅត្រួតពិនិត្យនោះបានរកឃើញថាមានសារធាតុគីមីហាមឃាត់បូរ៉ាក់ នៅក្នុង នំស្លឹកស្រស់ និងនំស្រួយបន្ទាប់មកក៏បានធ្វើការដក

[53] ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញនិងសេវាឆ្នាំ២០០០, មាត្រា ២២។

ហូតបានសរុប ៨៦ គីឡូក្រាម រួចក៏បានកំទេចចោលនៅនិងកន្លែង រួមទាំងអញ្ជើញអាជីវករចំនួន ០៦នាក់ និងម្ចាស់សិប្បកម្មចំនួន ០២នាក់ដើម្បីមកធ្វើកិច្ចសន្យាបញ្ឈប់ការទទួលលក់និងផ្អាកការផលិតជាបណ្ដោះអាសន្ន រហូតដល់ធ្វើការកែប្រែគុណភាពហើយ។”[54]

ដូចបានឃើញនូវករណីដែលបានលើកឡើងខាងលើស្រាប់ បានបញ្ជាក់យ៉ាងច្បាស់ពីការអនុវត្តនូវភារៈកិច្ចរបស់មន្ត្រីកាំកុងត្រូលក្រោយពីទទួលការអនុញ្ញាតពីសំណាក់រាជរដ្ឋាភិបាល។ មន្ត្រីជំនាញក៏បានអនុវត្តទៅតាមភារៈកិច្ចរបស់ខ្លួនទៅតាមច្បាប់ដែលបានចែង និងអនុញ្ញាតដោយបានធ្វើការកំទេចចោល និងបានធ្វើការផ្អាកការផលិតជាបណ្ដោះអាសន្នផងដែលទៅលើរោងឧស្សាហកម្មដែលប្រព្រឹត្តិល្មើសនឹងច្បាប់។

## ផ្នែកទី២៖ នីតិវិធីនៃការត្រួតពិនិត្យគុណភាព លើផលិតផលទំនិញ

ក្រសួងពាណិជ្ជកម្ម និងក្រសួងពាក់ព័ន្ធមានសមត្ថកិច្ចក្នុងការធ្វើការបង្ក្រាបការធ្វើពាណិជ្ជកម្មដែលខុសទៅនឹងច្បាប់ដូចជាការផលិតនូវផលិតផលក្លែងក្លាយ ការក្លែងបន្លំដោយអនុវត្តតាមច្បាប់ស្ដីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវា ដែរបានចុះនៅថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០០០។ ក្រសួងទាំងអស់ដែលមានសមត្ថកិច្ចពាក់ព័ន្ធត្រូវរៀបចំអង្គភាពជំនាញដើម្បីទទួលបន្ទុកក្នុងការបង្ក្រាបការក្លែងបន្លំ និងធ្វើការត្រួតពិនិត្យទៅលើផលិតផលទំនិញដែលនឹងត្រូវធ្វើចរាចរណ៍ នាំចេញ និងនាំចូលនៅក្រៅនិងក្នុងប្រទេសឲ្យបានខ្ជាប់ខ្ជួន។

### កថាខណ្ឌ១៖ ការត្រួតពិនិត្យនៅលើទំនិញ

រាល់ការធ្វើសកម្មភាពពិនិត្យស្រាវជ្រាវអំពីគុណភាព សុវត្ថិភាពលើផលិតផលទំនិញ ព្រមទាំងពិនិត្យកំណត់ហេតុបទល្មើសដែបានកើតឡើងទាក់ទង និងផលិតផលដែលគ្មានគុណភាពពិតប្រាកដ ឬចាត់វិធានការប្រាតិភោគជាសមត្ថកិច្ចរបស់ភ្នាក់ងារត្រួតពិនិត្យរបស់ក្រសួងពាណិជ្ជកម្មដោយសហការជាមួយក្រសួងដែរមានសមត្ថកិច្ចជំនាញពាក់ព័ន្ធនឹងបញ្ហាទាំងអស់នេះផងដែរ។

ក្នុងករណីដែលមានការសង្ស័យថាទំនិញមួយមានផ្ទុកនូវសារធាតុគីមី ឬក៏សង្ស័យថាទំនិញនោះបានខូចគុណភាព និងផុតកំណត់សម្រាប់ប្រើប្រាស់នោះ មន្ត្រីជំនាញនឹងធ្វើការដក់ហូតនូវ

[54] ខ្មែរណូត, “នំស្លឹកស្រស់ និងនំស្រួយ នៅផ្សារអូឫស្សីចំនួន ៨៦គីឡូក្រាមត្រូវបានសមត្ថកិច្ចកំទេសចោល បន្ទាប់ពីធ្វើតេស្តរកឃើញ សារធាតុគីមីហាមឃាត់,” (ភ្នំពេញ, ១១ មិថុនា ២០១៨), អាចរកបាននៅ https://komsan.khmernotes.com/news/92637 (ថងចម្លងថ្ងៃទី ១០ កក្កដា ២០១៨) ។

ទំនិញដែលមានការសង្ស័យនោះ ដោយការដកហូតទំនិញដែលសង្ស័យត្រូវយកមកពិនិត្យពីគុណភាពនោះ គេត្រូវធ្វើការដកយកគំរូទំនិញទាំងនោះជា ៣ផ្នែក ដើម្បីយកមកធ្វើការពិនិត្យ។ លើកលែងតែផលិតផលទំនិញណាមួយដែលមិនអាចជាកម្មវត្ថុនៃការយកគំរូទំនិញជាបីបាន ដោយហេតុផលនៃចរិតលក្ខណៈ ឬតម្លៃរបស់វានោះ ការដកយកគំរូទំនិញត្រូវធ្វើឡើងជាគំរូទំនិញតែមួយគត់ទៅលើផលិតផលទាំងមូល ឬមួយផ្នែក[55] ហើយនីតិវិធីនៃការដកហូតគំរូទំនិញនោះជាសមត្ថកិច្ចរបស់មន្ត្រីជំនាញ ដែលតម្រូវអោយគំរូទំនិញដែលដកហូតមកទាំងបីមានលក្ខណៈដូចគ្នា និងមានចរិតបង្ហាញលក្ខណៈតំណាងអោយឡូត៍ទំនិញដែលត្រូវត្រួតពិនិត្យ ដែលគំរូទំនិញទាំងបីត្រូវដកមកពីឡូត៍ទំនិញតែមួយដូចៗគ្នា។

បន្ទាប់ពីដកហូតមករួចហើយនោះ គំរូទំនិញទាំងនោះត្រូវរក្សាទុកដោយបិទបោះត្រា មិនតែប៉ុណ្ណោះចំពោះការបិទបោះត្រាត្រូវមានភ្ជាប់នូវផ្លាកបញ្ជាក់ដែលមានកំណត់ជាអាទិ៍ ដូចជា៖

- ឈ្មោះទំនិញដែលត្រូវហៅនៅពេលកាន់កាប់ក្នុងបំណងសំរាប់លក់ ពេលដាក់លក់ ឬបានលក់ហើយ
- កាលបរិច្ឆេទ ម៉ោងនិងទីកន្លែងនៃការយកគំរូទំនិញ
- អត្តសញ្ញាណ និងអាស័យដ្ឋានរបស់បុគ្គលដែលការយកគំរូទំនិញត្រូវបានធ្វើនៅកន្លែងរបស់គេ
- លេខរៀងផ្តល់សំរាប់ប្រតិបត្តិការនេះដោយអ្នកយកគំរូទំនិញ
- លេខចុះបញ្ជីនៃការយកគំរូទំនិញ ផ្តល់ដោយស្ថាប័នសាធារណៈដែលអ្នកយកគំរូទំនិញបំពេញការងារ ព្រមទាំងការបញ្ជាក់យ៉ាងច្បាស់លាស់ចំពោះស្ថាប័ននោះ
- កំណត់សំគាត់អត្ថប្រយោជន៍ទាំងឡាយ ដែលអាចអោយមន្ទីរពិសោធន៍បានដឹងនូវគោលដៅស្រាវជ្រាវ ដោយមានឯកសារជាក់លាក់ភ្ជាប់មកជាមួយនឹងផ្លាកសញ្ញាបញ្ជាក់
- ហត្ថលេខានៃអ្នកយកគំរូទំនិញ និងហត្ថលេខារបស់អ្នកកាន់កាប់ផលិតផលទំនិញដែលយកគំរូ។[56]

ក្នុងចំណោមគំរូទំនិញទាំងបីដែលដកហូតបានមកនោះ ក្នុងនោះមួយផ្នែកត្រូវបាន ទុកសម្រាប់ភ្នាក់ងារមានសមត្ថកិច្ចបញ្ជូនទៅមន្ទីរពិសោធន៍ដែរទទួលបន្ទុកធ្វើការវិភាគ ចំណែកឯគំរូពីរផ្សេង

---

[55] ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញនិងសេវាឆ្នាំ២០០០, មាត្រា ៤០។

[56] ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញនិងសេវាឆ្នាំ២០០០, មាត្រា៣៧។

ទៀតទុកសម្រាប់ប្រើប្រាស់ក្នុងរយៈកាលនៃប្រតិបត្តិការជាយថាហេតុនៃការវិភាគតបវិញ[57]។ ក្នុងចំណោមគំរូទំនិញទាំងបីដែលបានដកយកមករក្សាទុក ក្នុងការធ្វើពិសោធន៍នោះត្រូវប្រគល់គំរូទំនិញមួយក្នុងចំណោមបីទៅអោយម្ចាស់ផលិតផលដែលជាអ្នកមានសិទ្ធិរក្សាទុក និងថែក្សារគំរូទំនិញនោះ។

ភ្នាក់ងារត្រួតពិនិត្យ ត្រូវណែនាំអំពីរបៀបរបបនៃការរក្សាទុកគំរូទំនិញដល់អ្នកទាំងនោះដែលវាជាវិធានដែលសំដៅអោយបាននូវការធានាថាគំរូទំនិញ ដែលម្ចាស់ទំនិញបានរក្សាទុកនោះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីអោយការវិភាគនៅពេលក្រោយអាចធ្វើទៅបានត្រឹមត្រូវ។ ប៉ុន្តែក្នុងករណីដែលសាមីខ្លួនមិនយល់ព្រមទទួលរក្សាទុកនូវគំរូទំនិញមួយផ្នែក ដែលមន្ត្រីជំនាញបានផ្តល់អោយគេរក្សាទុកទេនោះ មន្ត្រីជំនាញត្រូវធ្វើកំណត់ហេតុដែលបញ្ជាក់អំពីហេតុការណ៍ដែលសាមីខ្លួនមិនព្រមទទួលរក្សាទុកនេះ។ ហើយគំរូទំនិញមួយផ្នែកនេះត្រូវបញ្ជូនទៅរក្សាទុកជាមួយគំរូទំនិញពីរផ្សេងទៀតដោយភ្នាក់ងារត្រួតពិនិត្យ។

នៅក្នុងករណីលទ្ធផលនៃការពិសោធន៍បង្ហាញនូវលក្ខណៈពុំស្របទៅ នឹងចរិកលក្ខណៈដែលកំណត់ដោយច្បាប់ ហើយក្រោយពីការយកគំរូ ឬការធ្វើអង្កេតចាំបាច់បន្ថែមដទៃទៀត ស្ថាប័នដែលបានអនុវត្តការត្រួតពិនិត្យ ត្រូវផ្តល់ដំណឹងដល់ជនជាប់សង្ស័យក្នុងបទល្មើសអំពីការទទួលខុសត្រូវចំពោះមុខច្បាប់ តាមផ្លូវតុលាការដោយមានបញ្ជាក់ហេតុផលដល់សាមីជន ។ ក្នុងករណីសាមីជនមិនសុខចិត្ត គេមានសិទ្ធអាចយកគំរូមួយផ្នែកទៀតមកធ្វើការពិសោធន៍វិភាគតបវិញ។ ដោយគេត្រូវជ្រើសរើសអ្នកឯកទេសរបស់ខ្លួនក្នុងរយៈពេល១៥ថ្ងៃ នៃថ្ងៃធ្វើការ។ បើសាមីជនមិនបានធ្វើការសុំសិទ្ធក្នុងរយៈពេលកំណត់ខាងលើនេះទេ លទ្ធផលនៃការវិភាគ មិនអាចត្រូវជជែកតវ៉ាបានឡើយ លើកលែងតែមានករណីប្រធានស័ក្តិ ដែលប៉ះពាល់ដល់ការឆ្លើយតប។[58]

ចំពោះការឃាត់ទុកបណ្តោះអាសន្ន គឺជាវិធានការសំដៅហាមឃាត់ជាបណ្តោះអាសន្នរាល់ការចាត់ចែងពីសំណាក់អ្នកកាន់កាប់នូវផលិតផលទំនិញ ដែលពាក់ព័ន្ធដោយអនុវត្តទៅលើឡូត៍ផលិតផលទំនិញដែលមានមន្ទិលសង្ស័យ, ឡូត៍ផលិតផលទំនិញដែលបានទទួលស្គាល់តាមការពិនិត្យកត់ត្រាផ្ទាល់ថាពុំសមស្របនឹងចរិតលក្ខណៈដែលកំណត់ដោយច្បាប់ ឬឡូត៍ផលិតផលទំនិញដែលការប្រើប្រាស់ធម្មតាអាចធ្វើអោយប៉ះពាល់ដល់សុវត្ថិភាព ឬសុខភាពនៃអ្នកប្រើ, ឧបករណ៍សម្រាប់បំរើការក្លែងបន្លំទាំងឡាយ ។ ប៉ុន្តែចំពោះការឃាត់ទុកនេះមិនអាចលើសពីរយៈពេល១៥ថ្ងៃទេ រាល់ការឃាត់ទុក គឺជាការទុកពេលវេលាសម្រាប់ចាត់ចែងអោយមានលក្ខណៈសមស្រប ដែល

[57] ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញនិងសេវាឆ្នាំ២០០០, មាត្រា៣៥។

[58] ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញនិងសេវាឆ្នាំ២០០០, មាត្រា៤៧។

វាជាវិធានការតម្រូវអោយអ្នកកាន់កាប់ ឬម្ចាស់ផលិតផល ទំនិញ ដើម្បីបញ្ចប់នូវមូលហេតុដែលបង្ក អោយមានលក្ខណៈពុំសមស្រប ដោយការបញ្ចប់នូវមូលហេតុមិនសមស្របនេះរួមមានទាំងកិច្ច ដំណើការអោយមានការប្រែប្រួលផលិតផល ទំនិញ ជាពិសេសការផ្លូវលេខចំណាត់ថ្នាក់ផលិតផល ទំនិញ ប្រសិនបើមានចំណាត់ថ្នាក់ច្រើន ហើយបើសិនជាឃើញថា ផលិតផលនោះអាចចាត់ថ្នាក់មកក្នុងប្រភេទផ្សេងដែលចំណាត់ថ្នាក់នោះ ផលិតផលទំនិញនឹងអាចយកមកលក់ដូរស្រប ច្បាប់បាន ឬក៏ភ្នាក់ងារត្រួតពិនិត្យអាច ឬអោយគេធ្វើក្រោមការត្រួតពិនិត្យរបស់ខ្លួននូវការកំទេចចោល ឬក៏គេអាចធ្វើការបំប្លែងភាពដើមនៃផលិតផលរឹបអូស ពេលណាដែលផលិតផលនោះពុំអាចប្រើប្រាស់ស្របច្បាប់ និងប្រកបដោយផលប្រយោជន៍សេដ្ឋកិច្ចណាមួយបាន “ការបំប្លែង ឬ ការប្តូរទិសដៅផលិតផលទំនិញ គឺជាការបញ្ជូនផលិតផលទាំងនោះទៅកាន់សហគ្រាសដែលនឹងអាចប្រើប្រាស់ផលិតផលទាំងនោះដោយផ្ទាល់ឬអាចធ្វើការកែច្នៃអោយបានសមស្របតាមច្បាប់វិញ ក្រោមបន្ទុកចំណាយរបស់ម្ចាស់ផលិតផល”[59]។

> “ដូចជាក្នុងករណី មន្រ្តីកាំកុងត្រូលបានធ្វើការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងគុណភាពសុវត្ថិ ភាពចំណីអាហារ និងផលិតផលទំនិញ និងសេវានៅលើទីផ្សារ។ ក្នុងនោះមន្រ្តីសមត្ថកិច្ចសាខាកាំកុងត្រូលខេត្តកំពត-កែប បានសហការជាមួយមន្រ្តីមន្ទីរពាណិជ្ជកម្ម នៃខេត្តទាំងពីរកំពត-កែប និងគណ:កម្មការផ្សារ បានចុះអនុវត្តតាមទីផ្សារគោលដៅក្នុងខេត្តទាំងពីរ ដើម្បីត្រួតពិនិត្យ ស្វែងរកនិងដកហូតនូវផលិតផលទំនិញទាំងឡាយណា ដែលមានលក្ខណៈ ខូចគុណភាព និងហួសថ្ងៃខែឆ្នាំកំណត់នៃការប្រើប្រាស់ ព្រមទាំងបានធ្វើតេស្តបឋម ដើម្បីស្វែងរកសារធាតុគីមីដែលច្បាប់ហាមឃាត់ ទៅលើទឹកត្រាំបង្គា មឹក និងត្រីងៀតផងដែរ។ជាលទ្ធផលសមត្ថកិច្ចដែលបានចុះនៅក្នុងផ្សារសាមគ្គី ក្រុងកំពតបានធ្វើតេស្តបឋម ទៅលើត្រីប្រឡាក់អំបិលហើយក៏មានការសង្ស័យថាមានសារធាតុបូរ៉ាក់នៅលើត្រីងៀតដែលបន្ទាប់មកមន្រ្តីជំនាញក៏យកគំរូទំនិញ ដែរជាបំណែកនៃត្រីងៀតដែលមានការសង្ស័យនោះបញ្ជូនដើម្បីធ្វើការពិសោធន៍បន្ថែមរកភាពជាក់លាក់នៅអគ្គនាយកដ្ឋានកាំកុងត្រូលបន្តទៀត។
>
> មិនតែប៉ុន្នោះសមត្ថកិច្ចក៏បានចុះអនុវត្តភារៈកិច្ចនៅ ផ្សារកំពង់ត្រាចខេត្តកំពត និងផ្សារ ដំណាក់ចង្អើរ ផ្សារពងទឹក និងផ្សារកែបខេត្តកែប និងតាមផ្សារម៉ាត និងតាមផ្ទះអាជីវករក្នុងខេត្តទាំងពីរខាងលើផងដែរ។ ក្នុងនោះមន្រ្តីជំនាញបានប្រទះឃើញមានការសង្ស័យក៏បានដកហូតនូវផលិតផលមួយចំនួនដូចជា ភេសជ្ជៈ គ្រឿងឧបភោគបរិភោគ នំចំណី សរុបមានចំនួន៣៥មុខ ដែលក្នុងនោះផងដែល

[59] ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញនិងសេវាឆ្នាំ២០០០, មាត្រា៥៥។

បើគិតទៅមាន ផលិតផលដែលគិតជាដបស្មើនឹង២១៨ដប ផលិតផលដែលគិតជាកំប៉ុងស្មើ៨៧កំប៉ុង ផលិតផលដែលក្នុងកញ្ចប់ស្មើ១៥២កញ្ចប់ ផលិតផលដែលមាននៅក្នុងប្រអប់ស្មើ១៤៩ប្រអប់ដែរស្មើរនិង ១០ដុំ និងរួមទាំងផលិតផលដែលគេទុកដាក់នៅក្នុង កែវបានចំនួន ០២កែវ។"[60]

## កថាខណ្ឌ២៖ តួនាទីរបស់ភ្នាក់ងារត្រួតពិនិត្យទំនិញ

ចំពោះការអនុវត្តនៅពេលដែលមានការសង្ស័យ ឬទទួលបាននូវបណ្តឹងនោះ ភ្នាក់ងារត្រួតពិនិត្យដែលមានសមត្ថកិច្ច អាចចូលទៅពិនិត្យក្នុងទីកន្លែងផលិតកម្ម សហគ្រាសករណ៍ ពាណិជ្ជកម្ម អាជីវកម្ម និងសេវាកម្មព្រមទាំងចូលពិនិត្យក្នុងមធ្យោបាយដឹកជញ្ជូនទំនិញ ឃ្លាំងស្តុកទំនិញ ការិយាល័យ និងកន្លែងផ្សេងៗទៀតដែលពាក់ព័ន្ធបាន។[61] ប៉ុន្តែប្រសិនបើទីកន្លែងប៉ុន្មានខាងលើត្រូវបានប្រើប្រាស់ជាកន្លែងនៅស្នាក់របស់ផលិតករ ពាណិជ្ជករ ឬកម្មករផងនោះ ភ្នាក់ងារអាចចូលទៅត្រួតពិនិត្យបាន តែក្នុងពេលកំពុងមានការធ្វើសកម្មភាពផលិតនូវទំនិញតែប៉ុណ្ណោះ។ ក្នុងករណីក្រៅពីពេលធ្វើសកម្មភាពផលិតទំនិញនោះ ភ្នាក់ងារត្រួតពិនិត្យដែលមានសមត្ថកិច្ច ត្រូវតែមានការអនុញ្ញាតពីព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង និងវត្តមាននៃអាជ្ញាធរឃុំ-សង្កាត់នៃទីកន្លែងដែលនឹងត្រូវធ្វើការត្រួតពិនិត្យទាំងនោះផងដែរ។[62]

ភ្នាក់ងារត្រួតពិនិត្យដែរមានសមត្ថកិច្ចត្រូវពិនិត្យបញ្ជាក់អង្កេត ធ្វើកំណត់ហេតុ និងធ្វើសវនកម្មនៃបញ្ហាដែលពាក់ព័ន្ធដែលបានរកឃើញ។[63] កំណត់ហេតុដែលភ្នាក់ងារជំនាញបានធ្វើនេះមានតំលៃជាបន្ទាល រហូតដល់មានការបង្ហាញភស្តុតាងផ្ទុយពីកំណត់ហេតុចាស់ដែលភ្នាក់ងារបានរកឃើញថ្មីទៀត។ បុគ្គលដែរជាប់អង្កេតនូវក្នុងការសង្ស័យ ឬពាក់ព័ន្ធត្រូវបង្កលក្ខណៈងាយស្រួល និងផ្តល់លទ្ធភាពសំរាប់កិច្ចប្រតិបត្តិការក្នុងការត្រួតពិនិត្យជូនដល់ភ្នាក់ងារជំនាញដែលចុះធ្វើការត្រួតពិនិត្យ។ ភ្នាក់ងារត្រួតពិនិត្យអាចស្នើសុំនូវកំលាំងជំនួយ ដើម្បីការពារនិងធ្វើអន្តរាគមន៍នៅពេលដែរពួកគេត្រូវការជាចាំបាច់បានគ្រប់ពេលវេលា។[64]

ភ្នាក់ងារអាចសាកសួរធ្វើការចំលង ឬដកហូតឯកសារដែលពាក់ព័ន្ធនឹងការអង្កេតបាន។ ក្នុងករណី ដកហូតតម្រូវអោយភ្នាក់ងារដែលដកហូតនោះ ធ្វើនូវកំណត់ហេតុជាផ្លូវការមួយដែលត្រូវ

---

[60] "សាខាកាំកុងត្រូលកំពត-កែប ចុះត្រួតពិនិត្យទំនិញក្នុងផ្សារ ដើម្បីលើកកម្ពស់ការគ្រប់គ្រងគុណភាពសុវត្ថិភាពផលិតផលទំនិញ," ក្រសួងព័ត៌មាន,១៤ កញ្ញា ២០១៦ លេខ៥៨០, អាចរកបាននៅ https://www.pdikampot.info/news/81-news_13-09-16_01.html (ចម្លងថ្ងៃទី ១៥ កក្កដា ២០១៨) ។

[61] ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញនិងសេវាឆ្នាំ២០០០, មាត្រា២៩៖១។

[62] ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញនិងសេវាឆ្នាំ២០០០, មាត្រា២៩៖២។

[63] ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញនិងសេវាឆ្នាំ២០០០, មាត្រា២៨៖១។

[64] ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញនិងសេវាឆ្នាំ២០០០, មាត្រា២៨៖៣។

គាត់តែងភ្លាមៗ នៅពេលដែលធ្វើការដកហូត ឬថតចម្លងនូវឯកសារដែលពាក់ព័ន្ធទាំងនោះតាមនីតិវិធី។[65] ឯកសារដកហូតបានទាំងអស់នេះ ត្រូវបិទបោះត្រាបញ្ជាក់ពីភ្នាក់ងារត្រួតពិនិត្យដើម្បីធានាសុវត្ថិភាព ពីការលួចធ្វើការផ្លាស់ប្តូរនូវឯកសារ ឬវត្ថុដែលមានពាក់ព័ន្ធពីជនខិលខូចមួយចំនួន និងដើម្បីធានានូវទំនុកចិត្តជូនដល់ម្ចាស់ឯកសារ ឬវត្ថុដែលពាក់ព័ន្ធទាំងនោះ។[66]

បើឯកសារដកហូតមានសារៈសំខាន់ចាំបាច់សំរាប់ការបន្តសកម្មភាពផលិត ឬប្រកបរបរអាជីវកម្ម ឬសកម្មភាពណាមួយរបស់សហគ្រាសនោះ ភ្នាក់ងារត្រួតពិនិត្យត្រូវផ្តល់ជូនច្បាប់ចំលងទៅអោយសាមីខ្លួនទៅតាមសំណើដែលសាមីខ្លួនបានធ្វើការស្នើរសុំ ប៉ុន្តែចំពោះការចំណាយលើការថតចម្លងត្រូវស្ថិតក្នុងបន្ទុករបស់សាមីខ្លួន។[67]

ភ្នាក់ងារត្រួតពិនិត្យត្រូវចេញបង្កាន់ដៃសំគាល់នូវការដកហូត និងផ្តល់នូវកំណត់ហេតុជូនដល់បុគ្គលដែលជាម្ចាស់ដែលត្រូវភ្នាក់ងារត្រួតពិនិត្យដកហូតនូវឯកសារ ឬវត្ថុរបស់ខ្លួន។ រាល់កំណត់ហេតុទាំងឡាយណា ដែលគាត់តែងឡើងដោយពុំគោរពតាមគោលការណ៍ដែលមានចែងខាងលើនេះត្រូវចាត់ទុកជាមោឃៈ។[68] រាល់ឯកសារដែរត្រូវបានដកហូតទាំងនោះនឹងត្រូវភ្ជាប់ជាមួយនឹងកំណត់ហេតុរួមទាំង ព្រឹត្តប័ត្រវិភាគព្រមទាំងរបាយការណ៍កោសល្យវិច័យនិងសំអាងដទៃទៀត បើមានបទល្មើសត្រូវបញ្ជូនទៅតុលាការ ឬក៏ប្រគល់អោយទៅសាមីខ្លួនវិញប្រសិនបើពុំមានហេតុការណ៍គួរអោយស្តីបន្ទោសណាមួយ ត្រូវធ្វើចំពោះខ្លួនគេទេនោះ។ ភ្នាក់ងារត្រួតពិនិត្យក៏ត្រូវធ្វើកំណត់ហេតុនៃការប្រគល់ត្រឡប់វិញ ដែលត្រូវតែលើកឡើងតាមទំរង់ដូចគ្នាទៅនឹងទំរងនៃកំណត់ហេតុដកហូតដែរ។[69]

ភ្នាក់ងារត្រួតពិនិត្យដែលមានសមត្ថកិច្ច ក៏អាចប្រមូលឯកសារពីការបំភ្លឺរបស់សាក្សីផងដែរ ដោយពួកគេអាចប្រមូលនូវឯកសារ និងធ្វើនូវកំណត់ហេតុនៃសេចក្តីអះអាងហេតុការណ៍នានាពីបុគ្គលដែលអាចផ្តល់បាននូវព័ត៌មានដែលមានប្រយោជន៍ដល់ការអង្កេតរបស់គេ[70]។

ភ្នាក់ងារត្រួតពិនិត្យនេះបំពេញតួនាទីភារកិច្ចត្រួតពិនិត្យផលិតផល ទំនិញដោយការពិនិត្យដោយការប្រើឧបករណ៍វង្វាស់វង្វាល់សាមញ្ញ និងពិនិត្យបញ្ជាក់ឯកសារក្នុងបំណងកំណត់អោយ

---

[65] ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញនិងសេវាឆ្នាំ២០០០, មាត្រា៣០៖២។
[66] ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញនិងសេវាឆ្នាំ២០០០, មាត្រា៣០៖៣។
[67] ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញនិងសេវាឆ្នាំ២០០០, មាត្រា៣០៖៦។
[68] ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញនិងសេវាឆ្នាំ២០០០, មាត្រា៣០៖៤។
[69] ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញនិងសេវាឆ្នាំ២០០០, មាត្រា៣០៖៥។
[70] ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញនិងសេវាឆ្នាំ២០០០, មាត្រា៣២។

បាននូវអត្តសញ្ញាណលើផលិតផលទំនិញ ហើយរកអោយបាននូវលក្ខណៈសមស្របជាយថាហេតុលើផលិតផល ទំនិញនោះទៅនឹងចរិតលក្ខណៈដែលត្រូវបង្ហាញ ឬដើម្បីស្រាវជ្រាវរកថា តើលក្ខខណ្ឌកំណត់សំរាប់ការផលិត សំរាប់កិច្ចសហត្ថារករណ៍ និងសំរាប់ពាណិជ្ជកម្មនូវផលិតផលទំនិញនោះត្រូវបានគោរពតាមច្បាប់ ឬយ៉ាងណា[71]។

ភ្នាក់ងារត្រួតពិនិត្យត្រូវរៀបចំសំណុំឯកសារកំណត់ហេតុ ព្រឹត្តប័ត្រវិភាគព្រមទាំងរបាយការណ៍កោលសល្យវិច័យនិងសំអាងដទៃទៀតបើមាន ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រង គុណភាព សុវត្ថិភាព លើផលិតផល ទំនិញនិងសេវាឡើងនៅថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០០។

ភ្នាក់ងារត្រួតពិនិត្យអាចធ្វើការឃាត់ទុកបណ្តោះអាសន្ន ការចាត់ចែងអោយមានលក្ខណៈសមស្រប ការប្តូរទិសដៅការរឹបអូស និងការកំទេចចោលនូវផលិតផលទំនិញ ព្រមទាំងការធ្វើអោយសមស្របឡើងវិញនូវសេវាដោយអនុលោមទៅតាមបែបបទនៃច្បាប់។ វិធានការអោយមានការសមស្របឡើងវិញ ការប្តូរទិសដៅ ការរឹបអូសនិងការកំទេចចោល នឹងអាចចែងទៅបានដោយភ្នាក់ងារមានសមត្ថកិច្ច លុះត្រាតែមានការអនុញ្ញាតពីប្រធានស្ថាប័នរបស់ខ្លួន និងមានការយល់ព្រមពីព្រះរាជអាជ្ញាអមតុលាការខេត្តក្រុង។[72]

## ផ្នែកទី៣៖ ការដាក់ទណ្ឌកម្មចំពោះជនល្មើស

រដ្ឋាភិបាលក៏បានកំណត់នូវទោសប្បញ្ញត្តិដើម្បីទប់ស្កាត់ និងបង្រ្កាបនូវការមិនគោរព និងមិនរាងចាលចំពោះជនល្មើសដែលបានប្រព្រឹត្តល្មើសនឹងច្បាប់ទាំងនេះផងដែល។ ដែលក្នុងនោះផងដែលទាក់ទងទៅនឹងផលិតផលទំនិញដែលគ្មានគុណភាពរួមទាំងឱសថ ទៀតនោះគេបានចាប់ទុកបទល្មើសមួយចំនួនដែលទាក់ទងខាងលើនេះគឺជាបទល្មើសព្រហ្មទណ្ឌ និងបទល្មើសមួយចំនួនទៀតត្រឹមពិន័យជាប្រាក់តែប៉ុណ្ណោះ ។

### កថាខណ្ឌ១៖ ការពិន័យជាប្រាក់

រដ្ឋាភិបាលបានកំណត់ថា ចំពោះជនទាំងឡាយណាដែលប្រព្រឹត្តល្មើស នឹងបទប្បញ្ញាត្តិដែលបានកំណត់អោយផលិតករ អនុវត្តអោយបានខ្ជាប់ខ្ជួនទាក់ទងទៅនិងការបិទសញ្ញាគុណភាពនោះនឹងត្រូវពិន័យជាប្រាក់ពី ៥០០.០០០ (ប្រាំសែន)រៀល ដល់ ១.០០០.០០០ (មួយលាន)រៀល។

[71] ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញនិងសេវាឆ្នាំ២០០០, មាត្រា៣៣។
[72] ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញនិងសេវាឆ្នាំ២០០០, មាត្រា៥២។

គឺដោយសារតែការបិទសញ្ញាគុណភាពជាការកំណត់នូវ ព័ត៌មានដែលទាក់ទងទៅនឹងផលិតផល និង ដើម្បីលើកកម្ពស់ផលិតផលក្នុងស្រុកផលដែរ។

ក្នុងសង្គមបច្ចុប្បន្នក៏មានបញ្ហាមួយចំនួនទាក់ទងទៅនឹងឱសថផងដែល ។ ដូចជាករណីមានជនមួយចំនួនបានធ្វើការនាំចូលនូវឱសថដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល និងបានធ្វើការផ្សព្វផ្សាយ លក់នូវផលិតផលឱសថនោះ។ នៅក្នុងបញ្ហាខាងលើនេះអ្នកដែលធ្វើការនាំចូលនូវផលិតផលឱសថ ដែលគ្មានការអនុញ្ញាតនោះ ត្រូវបានចាប់ទុកជាជនល្មើសដោយមូលហេតុថាបានប្រព្រឹត្តិគ្រប់ធាតុផ្សំនៃបទល្មើសដែលច្បាប់ចែងថា អាចចាត់ទុកជាបទល្មើសបានលុះត្រាតែមានធាតុផ្សំបី គឺធាតុផ្សំនីត្យានុកូល ធាតុផ្សំសត្យានុម័ត និងធាតុផ្សំអត្តនោម័ត។ ដូច្នោះ ជនល្មើសនឹងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន)រៀល ដល់ ៥.០០០.០០០(ប្រាំលាន)រៀល ដោយសារតែជនល្មើសបានធ្វើការ ផ្សព្វផ្សាយលក់នូវផលិតផលឱសថដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល។[73] ជនល្មើសក៏ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន)រៀល ដល់ ១០.០០០.០០០(ដប់លាន)រៀល បន្ថែមទៀតពីលើការពិន័យខាងលើផងដែរនេះបើគិតទៅតាមគោលការណ៍បូកទោស ដោយសារតែជនល្មើសបានធ្វើការនាំចូលនូវផលិតផលឱសថដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល។ ដោយសារធាតុផ្សំនីត្យានុកូលបានធ្វើការហាមឃាត់ដូចការលើកឡើងខាងលើ៖

- បើក បិទ ឬប្តូរទីតាំងគ្រឹះស្ថានលក់ដុំឱសថ គ្រឹះស្ថាននាំចូល ចែកចាយឱសថគ្រឹះស្ថាននាំចូល នាំចេញឱសថ ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល
- ប្រព្រឹត្តល្មើសនឹងបែបបទ និង លក្ខខណ្ឌពាណិជ្ជកម្ម អាហារ័ណ នីហារ័ណ ឱសថ
- នាំចូល ឬនាំចេញ ផលិតផលឱសថដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល
- ចែកចាយ តាំងលក់ ឬលក់ផលិតផលឱសថ និងគ្រឿងសំអាងដែលគ្មានចុះលេខទិដ្ឋាការ ឬ បញ្ជីការពីក្រសួងសុខាភិបាល
- លក់ឱសថខូចគុណភាព និង ឱសថផុតកំណត់ប្រើប្រាស់[74]

---

[73] ច្បាប់ស្តីពីការគ្រប់គ្រងឱសថ,លេខ/ជស/រកម/០៦៩៦/០២,២៨ ធ្នូ ២០០៧,មាត្រា ១០ (ពីពេលនេះហៅថា ច្បាប់ស្តីពីការគ្រប់គ្រងឱសថឆ្នាំ២០០៧)។

[74] ច្បាប់ស្តីពីការគ្រប់គ្រងឱសថឆ្នាំ២០០៧,មាត្រា ១១។

### កថាខណ្ឌ២៖ ការបង្ខំលើរូបរាងកាយ

នៅក្នុងបទល្មើសដែលទាក់ទងទៅនឹង ផលិតផលទំនិញ និងឱសថដែលខូចគុណភាព ឬហួសរយៈពេលប្រើប្រាស់នោះ រាជរដ្ឋាភិបាលក៏បានកំណត់ដាក់ទោសដោយធ្វើការបង្ខំលើរូបកាយផងដែលចំពោះជនល្មើស។

ដូចជាក្នុងករណីដែល ម្ចាស់ផលិតកម្មទឹកស៊ីអ៊ីវមួយកន្លែងបានបើកធ្វើអាជីវកម្មរបស់ខ្លួនដោយមិនបានសុំការអនុញ្ញាតពីក្រសួងដែលមានសមត្ថកិច្ច រួមទាំងបិទបាំងមិនឲ្យមានការពិនិត្យគុណភាពនៃផលិតផលរបស់ខ្លួនថែមទៀត។ ទង្វើរបស់ម្ចាស់អាជីវកម្មទឹកស៊ីអ៊ីវមួយកន្លែងនេះបានប្រព្រឹត្តិល្មើសនឹងច្បាប់ស្តីពីការ គ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងសេវា។ ដូចដែលបានរៀបរាប់ខាងលើ បានបញ្ជាក់ប្រាប់យ៉ាងច្បាស់ថាម្ចាស់អាជីវកម្មទឹកស៊ីអ៊ីវនោះបានប្រព្រឹត្តបទល្មើស ដែលរួមមានទាំងធាតុផ្សំសត្យានុម័ត អត្តនោម័ត និងរួមទាំងធាតុផ្សំនីត្យានុកូលដូចដែលមានលើកឡើងខាងក្រោមនោះ៖

- ការផលិត ឬ ការធ្វើពាណិជ្ជកម្មនៃផលិតផលទំនិញ ឬសេវាដោយគ្មានប្រតិវេទន៍ គ្មានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច។ ដែលតម្រូវអោយមុននឹង ផលិតអ្វីមួយនោះ ម្ចាស់ពាណិជ្ជកម្មត្រូវធ្វើការស្នើរសុំ និង ទទួលការត្រួតពិនិត្យពីក្រសួងមានសមត្ថកិច្ចជាមុនសិនទើបពួកគេអាចធ្វើអាជីវកម្មទាំងនោះបាន។
- ធ្វើការគេចវេះ ឬប៉ុនប៉ងគេចវេះពីការត្រួតពិនិត្យ
- ការធ្វើពាណិជ្ជកម្មលើផលិតផលទំនិញ ឬសេវាពុំបានត្រួតពិនិត្យ
- រក្សាទុកនៅគ្រប់ទីកន្លែងផលិត ទីកន្លែងសហាត្ថាករណ៍ និងទីកន្លែងពាណិជ្ជកម្មនៅផលិតផលក្លែងបន្លំ
- ម្ហូបអាហារដែលប្រែប្រួលខូចគុណភាពបរិភោគមិនបាន ឬមានជាតិពុល ឬមិនស្របនឹងលក្ខណៈវិនិច្ឆ័យគុណភាពផ្នែកអតិសុខុមជីវសាស្ត្រ ឬ អនាម័យដែលបានកំណត់។
- រក្សារទុកផលិតផលឧបករណ៍សំរាប់កិច្ចបន្លំ ឬ ក្លែងចំពោះទំនិញគ្រប់មុខ
- ការផលិតប្រើប្រាស់ ការធ្វើពាណិជ្ជកម្ម ការរក្សាទុកនូវរង្វាស់រង្វាល់ និងឧបករណ៍សម្រាប់វាស់វែង សំរាប់វាស់វាល់ ឬថ្លឹងដែលខុសដោយពុំទៀតទាត់សំរាប់ប្រើប្រាសសំរាប់ផលិតកម្ម ឬពាណិជ្ជកម្មទំនិញ។
- ការធ្វើពាណិជ្ជកម្មនូវបណ្តាលផលិតផល និងឧបករណ៍ដែលសំដៅយកមកបំពេញកិច្ចបន្លំ ឬ ក្លែងមុខទំនិញទាំងឡាយ។

ក្នុងករណីដូចដែលបានរៀបរាប់ខាងលើនេះ ម្ចាស់អាជីវកម្មផលិតទឹកស៊ីអ៊ីវបានប្រព្រឹត្តិល្មើសនៅចំនុចបើកអាជីវកម្មដោយគ្មានការអនុញ្ញាត រួមទាំងព្រមអោយមន្ត្រីជំនាញចុះត្រួតពិនិត្យទីតាំង

អាជីវកម្មរបស់ខ្លួននោះ តម្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ)ថ្ងៃ ដល់ ១(មួយ)ខែ និង ពិន័យជាប្រាក់ពី ១.០០០.០០០(មួយលាន)រៀល ដល់ ៥.០០០.០០០(ប្រាំលាន)រៀល ឬ ទោសណាមួយនៃទោសទាំងពី។[75]

នៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃកំពុងតែមានជនខិលខូចមួយចំនួនបានប្រើនូវល្បិចទុច្ចរិតក្នុងការប្រកបរបបចិញ្ចឹមជីវិតដែលច្បាប់បានហាមឃាត់។ ដូចជាក្នុងករណីអ្នកលក់ផលិតផលសាប៊ូអនឡាយ ម្នាក់បានធ្វើការលាយនូវសារធាតុសាប៊ូដែលមិនសុទ្ធម្យ៉ាងចូលទៅក្នុងដបសាប៊ូដែលគេធ្វើការដាក់លក់នោះដើម្បីទទួលបានផលចំនេញច្រើន។ វាគឺជាអំពើចេតនារបស់ជនល្មើស ដែលកើតចេញពីឆន្ទៈផ្ទាល់របស់ជនល្មើស ដែលវាជាហេតុបង្កើតបាននូវធាតុផ្សំសត្យានុម័ត និង ធាតុផ្សំអត្តនោម័ត ចំពោះទង្វើបែបនេះក៏មានការហាមឃាត់ដោយច្បាប់ផងដែរ ដែលជាធាតុផ្សំនីត្យានុកូលដូចដែលមានខាងក្រោមនេះស្រាប់៖

- ក្លែងបន្លំតាមមធ្យោបាយ ឬវិធីណាក៏ដោយលើផលិតផលទំនិញឬសេវាចំពោះអត្តសញ្ញា យថាប្រភេទ ប្រភេទ ប្រភព គុណភាពខាងរូបធាតុ ឬខាងទ្រទ្រង់រាងកាយ ធាតុផ្សំ បរិមាណ។ ឬធ្វើការក្លែងផលិតផលទំនិញដែលជាកម្មវត្ថុធ្វើពាណិជ្ជម្ម ឬទុកសំរាប់ធ្វើពាណិជ្ជកម្មដោយធ្វើការកែច្នៃផលិតផលទំនិញតាមរបៀបណាមួយ ដោយធ្វើការបញ្ចូលបន្ថែម ការដកចេញ ឬការប្តូរជំនួសនៃភាគណាមួយ ឬភាគទាំងមូលដែលពុំត្រូវអនុញ្ញាតអោយធ្វើដោយបទប្បញ្ញត្តិ ឬដោយទំលាប់ដោយមិនសមស្រប។
- ការធ្វើពាណិជ្ជកម្មដោយដឹងថាផលិតផល ក្លែងក្លាយ។
- ការធ្វើពាណិជ្ជកម្មនូវផលិតផលម្ហូបអាហារដែលប្រែប្រួលខូចគុណភាពបរិភោគមិនបាន ឬមានជាតិពុល ឬមិនស្របនឹងលក្ខណៈវិនិច្ឆ័យគុណភាពផ្នែកអតិសុខុមជីវសាស្ត្រ ឬអនាម័យកំណត់តាមបទប្បញ្ញត្តិរបស់ក្រសួងពាក់ព័ន្ធ។

ដូច្នេះជនល្មើសនឹងត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១(មួយ)ខែ ដល់ ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី ៥.០០០.០០០(ប្រាំលាន)រៀល ដល់ ១០.០០០.០០០ (ដប់លាន)រៀល ឬ ទោសណាមួយក្នុងចំណោមទោសណាមួយនៃទោសទាំងពីរ។[76] ដោយសារតែជនល្មើសបានប្រព្រឹត្តិល្មើសនឹងច្បាប់ដែលបានហាមឃាត់មិនអោយធ្វើការលក់នូវផលិតផលក្លែងក្លាយ។ ក្នុងករណីមិនរាងចាលចំពោះបទល្មើសនឹង ត្រូវផ្តន្ទាទោសទ្វេឡើង ទាំងការផ្តន្ទាទោសពិន័យជាប្រាក់ ទាំងការផ្តន្ទាទោស

[75] ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញនិងសេវាឆ្នាំ២០០០, មាត្រា ៦២។
[76] ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញនិងសេវាឆ្នាំ២០០០, មាត្រា ៦៣។

ដាក់ពន្ធធានាគារដោយពុំទាន់គិតបញ្ចូលនូវទោសព្រហ្មទណ្ឌធ្ងន់ធ្ងរ ចំពោះបច្ច័យនៃបទល្មើស ដែលបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាព សុវត្ថិភាព ឬដល់អាយុជីវិតរបស់អ្នកប្រើ។

ក្នុងករណីដែលជនល្មើសបានលួចធ្វើការនាំចូល ឬចែកចាញនូវផលិតផលឱសថដែលមានសារធាតុញៀន នឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ ឆ្នាំដល់ ១០ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន)រៀល ដល់ ៥០.០០០.០០០(ហាសិបលាន)រៀល។ ដែលនេះជាធាតុផ្សំនីត្យានុកូលនៃបទល្មើស ដែលមាននៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងឱសថ ក្នុងនោះបានចែងហាមឃាត់រាល់សកម្មភាព៖

- ផលិត នាំចូល ឬស្តុកឱសថញៀន ឱសថប្រព័ន្ធសរសៃប្រសាទ សារធាតុញៀន សារធាតុផ្សំគ្រឿងញៀន ដែលកំណត់ក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- ចែកចាយ តាំងលក់ ឬលក់ឱសថញៀន ឬឱសថសរសៃប្រសាទដែលគ្មានផលប្រយោជន៍ខាងវេជ្ជសាស្ត្រ ដែលក្រសួងសុខាភិបាលបានហាមឃាត់
- ផលិត នាំចូល ចែកចាយ តាំងលក់ ឬលក់ឱសថក្លែងក្លាយ

ករណីបទល្មើសខាងលើ បានបង្កឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ ឬអាយុជីវិតមនុស្ស សត្វ ក្រសួងសុខាភិបាលត្រូវចេញប្រកាសផ្អាកសកម្មភាពផលិត អាហារ័ណ នីហារ័ណ និងពាណិជ្ជកម្មឱសថជាបន្ទាន់ និង កសាងសំណុំរឿងបញ្ជូនទៅតុលាការដើម្បីផ្តន្ទាទោសតាមច្បាប់ ។[77]

ចំពោះទោសទាំងឡាយណា ដែលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ដល់ ១០.០០០.០០០(ដប់លាន)រៀល ក្រសួងសុខាភិបាលមានសិទ្ធពិន័យអន្តរការណ៍។ ក្នុងករណីរឹងរូសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ក្រសួងសុខាភិបាលត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការ។ ក៏ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ខែ ទៅ ៦ខែ ឬ ផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន)រៀល ដល់ ១០.០០០.០០០(ដប់លាន)រៀល ឬទោសទាំងពីរ ចំពោះជនណាដែលរារាំងប្រឆាំងមិនអោយមន្ត្រីជំនាញធ្វើការអនុវត្តច្បាប់នេះ។

ទាំងអស់នេះសុទ្ធសឹងតែជាទោសដែលបានបង្កដោយសារតែផលិតផលមានសារធាតុគីមីផលិតផល ខូចគុណភាព រួមទាំងឱសថដែលហួសកាលបរិច្ឆេទប្រើប្រាស់ និងមានសារធាតុញៀន ដែរវាគឺជាចំនុចសំខាន់មួយដែលត្រូវអនុវត្ត មិនថាចំពោះមន្ត្រី ឬ ពាណិជ្ជករ និង ផលិតករឡើយ ពួកគេត្រូវតែមានការទទួលខុសត្រូវទៅលើទង្វើដែលពួកគេបានធ្វើ និង អនុវត្តអោយបានល្អចំពោះភារកិច្ចរបស់ពួកគេ ដើម្បីការអភិវឌ្ឍន៍ អោយកាន់តែរីកចម្រើនទៅមុខ និងធានាអោយបាននូវសុខសុវត្ថិភាព ផ្នែកសុខភាពជូនជនរួមជាតិទាំងអស់ផងដែល៕

[77] ច្បាប់ស្តីពីការគ្រប់គ្រងឱសថឆ្នាំ២០០៧,មាត្រា ១២។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការបកស្រាយខាងលើនៃប្រធានបទស្តីពី "**ការទទួលខុសត្រូវលើវិការៈទំនិញ**" ប្រធានបទមួយនេះ គឺពិតជាបានផ្តល់ផលប្រយោជន៍យ៉ាងច្រើនសម្រាប់សិស្សនិស្សិត ដើម្បីទទួលបានបន្ថែមនូវចំណេះដឹងថ្មីមួយទៀតពាក់ព័ន្ធនឹងការទទួលខុសត្រូវលើទំនិញមានវិការៈ។ ដោយនៅក្នុងនោះមានបានលើកពីការទទួលខុសត្រូវតាមកិច្ចសន្យា អំពើអនីត្យានុកូល វិធានការបង្ក្រាបទំនិញក្លែងក្លាយ និងខូចគុណភាព អំពីតួនាទី និងភារកិច្ចរបស់មន្ត្រីកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម និងការផ្តន្ទាទោសទៅលើផលិតករ និងអ្នកលក់ទំនិញខូចគុណភាព។ អំពីអនីត្យានុកូល គឺជារបបសងសំណងនៃការខូចខាត ក្នុងករណីដែលបានបំពានទៅលើសិទ្ធ ឬផលប្រយោជន៍របស់អ្នកដទៃ ដោយខុសច្បាប់កំហុសចេតនា ឬ អចេតនា។ ជនល្មើសដែលប្រព្រឹត្តអំពីនោះត្រូវតែទទួលខុសត្រូវ ដោយសងសំណងនៃការខូចខាតទាំង សម្ភារៈ ផ្លូវចិត្ត និងរូបរាងកាយឱ្យជនរងគ្រោះ។ ដើម្បីឱ្យមានការទទួលខុសត្រូវនោះ គឺការព្យសនកម្មត្រូវមានទំនាក់ទំនងហេតុនិងផល ដោយជនរងគ្រោះទទួលរងព្យសនកម្មដោយសារតែទង្វើចារី។ ដូច្នេះក្នុងករណីផលិតករ និងអ្នកចែកចាយ ផលិតនិងលក់ទំនិញដែលគ្មានគុណភាព ឬទំនិញមានសារធាតុគីមីដោយមិនគិតដល់ការប៉ះពាល់ដល់អ្នកទិញ អ្នកផលិតទំនិញ និងអ្នកលក់ទំនិញត្រូវតែទទួលខុសត្រូវតាមអំពីអនីត្យានុកូល ដែលបានចែងក្នុងក្រមរដ្ឋប្បវេណី មាត្រា៧៥២ ទោះបីជាគ្មានចំណងគតិយុត្តជាមួយអ្នកទិញក៏ដោយ។

ម្យ៉ាងទៀតក្នុងការសិក្សាស្រាវជ្រាវមួយនេះក៏បានលើកពីការទទួលខុសត្រូវតាមកិច្ចសន្យា ដោយលើកយកការទទួលខុសត្រូវតាមកិច្ចសន្យាលក់ទិញ និងកិច្ចសន្យាដឹកជញ្ជូន ដើម្បីឱ្យមានការទទួលខុសត្រូវតាមកិច្ចសន្យាលុះត្រាតែភាគីទាំងពីរនោះមានចំណងគតិយុត្តជាមួយគ្នា ដោយមានឆន្ទៈព្រមព្រៀងគ្នាក្នុងការចុះកិច្ចសន្យា។ ដើម្បីបង្កើតកិច្ចសន្យាបានលុះត្រាតែគូរភាគីមានការព្រមព្រៀង មានសមត្ថភាពតាមច្បាប់ និងកម្មវត្ថុស្របច្បាប់។ កិច្ចសន្យាអាចជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់។ នៅពេលដែលគូរភាគីបានព្រមព្រៀងចុះកិច្ចសន្យា ហើយគូរភាគីមានសិទ្ធ និងករណីយកិច្ចចំពោះគ្នាទៅវិញទៅមក។ នៅពេលដែលអ្នកលក់បានបង្កើតកិច្ចសន្យាជាមួយអ្នកទិញ អ្នកលក់មានករណីយកិច្ច ប្រគល់ទំនិញ ថែរក្សាទំនិញ ផ្តល់ព័ត៌មានអំពីទំនិញ និងធានាថាទំនិញដែលគ្មានវិការៈអ្នកទិញមានករណីយកិច្ចប្រគល់ប្រាក់ និងយកទំនិញ បើទំនិញនោះមានវិការៈដោយសារតែកំហុសរបស់អ្នកលក់ អ្នកលក់ត្រូវតែទទួលខុសត្រូវចំពោះអ្នកទិញ ដោយសារតែគាត់មិនអនុវត្តកាតព្វកិច្ចដែលមានក្នុងកិច្ចសន្យាដូចជាផ្តល់ទំនិញមានវិការៈ ភាគីនោះត្រូវតែសង

សំណងការខូចខាតទៅភាគីម្ខាងទៀត ។ ដូច្នេះបើសិនភាគីណាមួយក្នុងកិច្ចសន្យាមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ភាគីនោះត្រូវតែទទួលខុសត្រូវចំពោះភាគីម្ខាងទៀត ដោយសំណងទៅភាគីដែលខូចខាត ម្ចាស់បំណុលអាចទាមទារសំណងឱ្យកូនបំណុលអនុវត្តកាតព្វកិច្ចពេញលេញ ដូចជាការប្រគល់វត្ថុជំនួស ការជួសជុលវិការៈ ការរំលាយកិច្ចសន្យា ការកាត់បន្ថយតម្លៃតាមកិច្ចសន្យា។ នៅពេលដែលកូនបំណុលមិនបានអនុវត្តកាតព្វកិច្ចដោយស្ម័គ្រចិត្តទេ ម្ចាស់បំណុលបង្ខំកូនបំណុលឱ្យអនុវត្តកាតព្វកិច្ចតាមនីតិវិធីអនុវត្តដោយបង្ខំ។ ចំពោះការគណនាសំណង ក្រមរដ្ឋប្បវេណីក៏បានចែងកំណត់អំពីសំណង ដែលអាចទាមទារបានសំណងនៃការខូចខាតតាមសម្ភារៈនិងផ្លូវចិត្ត ប៉ុន្តែការទាមទារសំណងមិនមែនបានតាមអំពើចិត្តគ្រប់ពេលវេលានោះទេ ក្រមរដ្ឋប្បវេណីក៏បានកំណត់អាជ្ញាយុកាលនៃការរំលត់សិទ្ធនិងការរំលាយកិច្ចសន្យា។ ក្រមរដ្ឋប្បវេណីនៅព្រះរាជណាចក្រកម្ពុជាបានចែងយ៉ាងច្បាស់ពីការទទួលខុសត្រូវតាមកិច្ចសន្យា ដោយម្ចាស់បំណុល និងកូនបំណុលមានសិទ្ធ និងករណីយកិច្ចរៀងៗខ្លួនក្នុងកិច្ចសន្យា ផ្តល់សិទ្ធិ និងយុត្តិធម៌ស្មើគ្នាចំពោះគូរភាគីដែលមានចំណងគតិយុត្តជាមួយគ្នា។

ដូច្នេះកូនបំណុលត្រូវសងសំណងនៃការខូចខាតទៅម្ចាស់បំណុល ដែលទទួលរងការខូចខាតដោយសារតែមិនអនុវត្តករណីយកិច្ច ដែលជាទណ្ឌកម្មនៃការមិនគោរពនៃការអនុវត្តករណីយកិច្ច។ ដោយជំពូកចុងក្រោយលើកពីការទទួលខុសត្រូវតាមផ្នែកព្រហ្មទណ្ឌ វិធានការនៃការទប់ស្កាត់ និងហាមឃាត់ទំនិញខូចគុណភាព និងនីតិវិធីត្រួតពិនិត្យ ផ្តន្ទាទោសជនដែលប្រព្រឹត្តបទល្មើស ដូចជាការដកហូត និងកំទេចចោលទំនិញខូចគុណភាព ពិន័យជាប្រាក់ និងទោសដាក់ពន្ធនាគារ។

សរុបសេចក្តីមក ការសិក្សាស្រាវជ្រាវនេះបានរកឃើញថា មិនថាផលិតករ អ្នកលក់ទំនិញ ឬ អ្នកដឹកជញ្ជូន គឺសុទ្ធតែជាអ្នកមានកាតព្វកិច្ចត្រូវទទួលខុស នៅពេលដែលផលិតផល ឬ ទំនិញមានវិការៈដែលបង្កឱ្យមានផលប៉ះពាល់ដល់អ្នកប្រើប្រាស់ទំនិញនោះ។ ការទទួលខុសត្រូវនឹងកើតមាន ទោះបីជាបុគ្គលខ្លះមានចំណងគតិយុត្តជាមួយគ្នា បុគ្គលខ្លះទៀតពុំមានចំណងគតិយុត្តនឹងគ្នាក៏ដោយ ឱ្យតែទំនិញនោះមានវិការៈ ហើយបង្កឱ្យមានការខូចខាតដល់អ្នកទិញ។ ការទទួលខុសត្រូវលើទំនិញមានវិការៈសុទ្ធតែបានកំណត់យ៉ាងច្បាស់លាស់ក្នុងក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីការគ្រប់គ្រងគុណភាពសុវត្ថិភាពលើផលិតផលទំនិញនិងសេវា និងច្បាប់ស្តីពីការគ្រប់គ្រងឱសថ ។ យ៉ាងណាក្តីលើការអនុវត្តជាក់ស្តែង ការប្តឹងទាមទារសំណងផ្អែកលើទំនិញមានវិការៈនេះ គឺពុំសូវកើតមាននោះទេ ដោយហេតុថា ការយល់ដឹងអំពីសិទ្ធិ និង ច្បាប់ក្នុងសង្គមកម្ពុជាសព្វថ្ងៃនៅមានកម្រិតនៅឡើយ។ ម្យ៉ាងវិញទៀត មន្ត្រីត្រួតពិនិត្យលើបញ្ហាទំនិញ ក៏ពុំសូវសកម្មនាំឱ្យអ្នកជំនួញកាន់តែមានឱកាសក្នុងការបន្តសកម្មខុសច្បាប់របស់ពួកគេ។ ជាអនុសាសនិក្នុងការកែលំអរលើករណីទាំងនេះ គឺយើងត្រូវ

តែពង្រឹងនូវសមត្ថភាពរបស់មន្ត្រីត្រួតពិនិត្យលើទំនិញទាំងនេះឱ្យកាន់តែសកម្មថែមទៀត ដើម្បីទប់ស្កាត់នូវទំនិញខូចគុណភាព។ ជាពិសេសគឺ ប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់ផ្ទាល់ គឺពួកគេត្រូវស្វែងយល់អំពីគុណភាពនៃទំនិញមុននឹងទិញ ហើយយល់ដឹងអំពីសិទ្ធិដែលខ្លួនមាននៅពេលមានការប្តឹងទាមទារសំណងចំពោះទំនិញមានវិការៈទៅតុលាការ។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ពាក់ព័ន្ធ និង លិខិតបទដ្ឋានគតិយុត្ត


- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។
- ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧ ។
- ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧/០៦/០២១,០៦ កក្កដា ២០០៦។
- ច្បាប់ស្តីពីការគ្រប់គ្រងឱសថ, លេខ ជស/រកម/០៦៩៦/០២/,២៨ ធ្នូ ២០០៧។
-ច្បាប់ស្តីពីការគ្រប់គ្រងគុណភាពសុវត្ថិភាពលើផលិតផលទំនិញនិងសេវា,លេខ នស/រកម/០៦០០/០០១, ២១ មិថុនា ២០០០។
- សេចក្តីព្រាងច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម,តុលា ២០០៩។


## ២. ឯកសារមេរៀន


- ក្រសួងយុត្តិធម៌. ២០១០.សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី.ភ្នំពេញ។
- ក្រុមការងារនៃអនាគតគ្រូះបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជា:ជីវ:តុលាការ. ២០១៣.សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី បោះពុម្ពលើកទី១.ភ្នំពេញ។
- ក្រសួងយុត្តិធម៌. ២០១៦.មេរៀនស្តីពីក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី.ភ្នំពេញ។
- ណូមូរ៉ា តូយូហ៊ីរ៉ូ. ២០១១.សេចក្តីផ្តើមនីតិរដ្ឋប្បវេណី, ភ្នំពេញ។
- ខ្មែរណូត. ស្លឹកស្រស់និងនំស្រួយនៅផ្សារអូរឬស្សី៨៦គីឡូក្រោមត្រូវបានសមត្ថកិច្ចកំទេចចោលបន្ទាប់ពីធ្វើតេស្តរកឃើញសារធាតុគីមីហាមឃាត់.២០១៨ https://komsan.khmernotes.com/news/92637 (បានចូលមើលថ្ងៃ ១៥ កក្កដា ២០១៨) ។
- ក្រសួងព័ត៌មាន. សាខាកាំកុងត្រូលកំពត-កែបចុះត្រួតពិនិត្យទំនិញក្នុងផ្សារដើម្បីលើកកម្ពស់ការគ្រប់គ្រងគុណភាពសុវត្ថិភាពផលិតផលទំនិញ,១៤កញ្ញា២០១៦។ https://www.pdikampot.info/news/81-news_13-09-16_01.htm. (បានចូលមើលថ្ងៃ ១៥ កក្កដា ២០១៨) ។

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

--------

រដ្ឋសភា

# ច្បាប់

# ស្តីពី

# ការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និង សេវា

# ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះ :

-រាល់សហគ្រាសពាណិជ្ជកម្ម

-រាល់ផលិតករក្នុងគោលដៅពាណិជ្ជកម្ម

-អ្នកនាំចូល អ្នកនាំចេញទំនិញ អ្នកលក់ដូរទំនិញ

-សេវាករនៃសេវាកម្មដែលពាក់ព័ន្ធនឹងផលិតផលទំនិញ

-អ្នកឃោសនាពាណិជ្ជកម្មអំពីផលិតផល ទំនិញនិងសេវា

-អង្គការសង្គមនិងអង្គការក្រៅរដ្ឋាភិបាលដែលចូលរួមក្នុងសកម្មភាពផលិតកម្មពាណិជ្ជកម្ម ឬជំនួយមនុស្សធម៌ ។

**មាត្រា ២.-**

ផលិតកម្មក្នុងន័យនៃច្បាប់នេះសំដៅលើរាល់ប្រតិបត្តិការរួមមាន : ការចិញ្ចឹមសត្វ ការយកទឹកដោះសត្វ ការប្រមូលផលដំណាំ ការបេះផ្លែឈើ ការនេសាទ សត្តឃាត ការផលិត ការកែច្នៃ និងការវេចខ្ចប់ផលិតផលទំនិញ . រួមទាំងការស្តុកទុកក្នុងរយៈពេលផលិតនិងការបំពេញសេវា មុនដំណើរការពាណិជ្ជកម្មលើកដំបូង ។

ពាណិជ្ជកម្មក្នុងន័យនៃច្បាប់នេះ សំដៅលើរាល់ប្រតិបត្តិការស្តីពី :

-ការស្តុកទុក ការដឹកជញ្ជូន ការកាន់កាប់ក្នុងគោលបំណងលក់ដូរ ការដាក់តាំងលក់ ការលក់នូវរាល់មុខទំនិញ

-ការប្រគល់អោយដោយឥតគិតថ្លៃនូវគ្រប់ផលិតផលអាហារីណកម្ម-នីហារីណកម្ម ព្រមទាំងការដាក់លក់ ការលក់សេវា ឬការផ្តល់សេវាដោយឥតគិតថ្លៃ ។

## ជំពូកទី ២

## សិទ្ធិអ្នកប្រើនិងភាតព្វកិច្ចរបស់ភាគីសេដ្ឋកិច្ច

**មាត្រា ៣.-**

ផលិតករនិងសេវាករមានកាតព្វកិច្ចបញ្ជាក់បង្ហាញជាភាសាខ្មែរលើផលិតផល ទំនិញ និង សេវារបស់ខ្លួនអំពីធាតុផ្សំ វិធីប្រើប្រាស់ កាលបរិច្ឆេទផលិតផល និងរយៈពេលហួសកំណត់ប្រើប្រាស់រួមទាំងគោលការណ៍ផ្សេងៗទៀត ដែលធានាបាននូវសុវត្ថិភាព និងសុខភាពអ្នកប្រើ មុននឹងផលិតផល ទំនិញនិងសេវានេះ ចូលក្នុងដំណើរការធ្វើពាណិជ្ជកម្ម ។

ពាណិជ្ជករ អាជីវករមានកាតព្វកិច្ចអនុវត្តត្រឹមត្រូវទៅតាមសេចក្តីបញ្ជាក់បង្ហាញដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ ។

**មាត្រា ៤.-**

ផលិតករនិងសេវាករត្រូវបំពេញនូវកាតព្វកិច្ចក្នុងការធានាអំពីភាពពិតនៃធាតុផ្សំនិងរូបភាពនៃផលិតផលទំនិញ ឬសេវារបស់ខ្លួន ដើម្បីចៀសវាងកុំអោយអ្នកប្រើមានការភ័ន្តច្រឡំ ឬចៀសវាងធ្វើអោយមានការប៉ះពាល់ដល់ការប្រកួតប្រជែង ។

ពាណិជ្ជករនិងអាជីវករក៏ត្រូវបំពេញកាតព្វកិច្ចដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើចំពោះមុខទំនិញ ឬសេវាដែលខ្លួនយកមកធ្វើពាណិជ្ជកម្ម ។

**មាត្រា ៥.-**

ពាណិជ្ជករ អាជីវករនិងសេវាករដែលទទួលខុសត្រូវលើផលិតផល ទំនិញ ឬសេវាណាមួយដែលខ្លួនយកមកធ្វើពាណិជ្ជកម្មលើកដំបូងនៅព្រះរាជាណាចក្រកម្ពុជា ត្រូវតែពិនិត្យបញ្ជាក់អោយច្បាស់ថា ផលិតផលទំនិញឬសេវានោះមានលក្ខណៈត្រឹមត្រូវទៅនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

តាមសំណើរបស់ភ្នាក់ងារត្រួតពិនិត្យដូចចែងក្នុងមាត្រា ២៧ នៃច្បាប់នេះ ផលិតករក្នុងស្រុក ពាណិជ្ជករនាំចូលនិងសេវាករដែលទទួលខុសត្រូវអំពីពាណិជ្ជកម្មលើក

ដំបូងលើផលិតផល ទំនិញនិងសេវា ត្រូវបង្ហាញភស្តុតាងនៃការពិនិត្យបញ្ជាក់និងការត្រួតពិនិត្យដែលបានធ្វើរួចមកហើយ ។

មាត្រា ៦.-

រាល់ផលិតផលទំនិញ ឬសេវាទាំងឡាយណាដែលអាចប៉ះពាល់ដល់សុវត្ថិភាពឬសុខភាពនៃអ្នកប្រើផលិតកម្ម ឬពាណិជ្ជកម្មនៃផលិតផល ទំនិញនិងសេវាទាំងនោះតម្រូវអោយមានការធ្វើប្រតិវេទន៍ជាមុន ជូនដល់ស្ថាប័នមានសមត្ថកិច្ច និងមានការអនុញ្ញាតជាមុនពីស្ថាប័នមានសមត្ថកិច្ច ក្រោយពីមានការពិនិត្យរួចព្រមទាំងបញ្ជាក់បង្ហាញអំពីវិធីប្រើជាភាសាខ្មែរ ។

មាត្រា ៧.-

ត្រូវហាមឃាត់ជាដាច់ខាតនូវការផលិត ឬការធ្វើពាណិជ្ជកម្មនៃផលិតផលទំនិញ ឬសេវាដែលមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ដែលគ្មានការធ្វើប្រតិវេទន៍និងគ្មានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច ។

មាត្រា ៨.-

ត្រូវហាមឃាត់ជាដាច់ខាត :

-ការគេចវេះ ឬការប៉ុនប៉ងគេចវេះពីការត្រួតពិនិត្យដូចមានចែងក្នុងមាត្រា ៦ ខាងលើ

-ការធ្វើពាណិជ្ជកម្មលើផលិតផលទំនិញ ឬសេវាដែលពុំបានទទួលការត្រួតពិនិត្យ ។

មាត្រា ៩.-

អាហរណកម្មនៃផលិតផលទំនិញ ដែលមានលក្ខណៈមិនសមស្របនឹងច្បាប់នេះ អាចត្រូវបានអនុញ្ញាត ប្រសិនណាផលិតផលនោះត្រូវដឹកជញ្ជូនជាលក្ខណៈឆ្លងកាត់សំរាប់ធ្វើនីហរណកម្មបន្តតែប៉ុណ្ណោះ ។

មាត្រា ១០.-

អាហរ័ណកម្មនៃផលិតផលទំនិញ ដែលមានលក្ខណៈមនុស្សធម៌ ឬដែលពុំមានគោលដៅពាណិជ្ជកម្ម អាចអនុវត្តបានលុះត្រាតែមានការអនុញ្ញាតពិសេសពីរាជរដ្ឋាភិបាលតាមសំណើរបស់ក្រសួងមានសមត្ថកិច្ច ។

ការអនុញ្ញាតពិសេសនេះនឹងអាចធ្វើទៅបាន លុះត្រាតែផលិតផលនិងទំនិញទាំងនោះសមស្របទៅនឹងរាល់ការអនុវត្តដោយត្រឹមត្រូវនៃពាណិជ្ជកម្មអន្តរជាតិ ឬសមស្របទៅនឹងវិធានដែលទទួលស្គាល់លើផ្ទៃអន្តរជាតិ ។

មាត្រា ១១.-

ការផលិតនូវផលិតផលទំនិញណាមួយដែលច្បាប់នេះមិនអនុញ្ញាតអោយធ្វើពាណិជ្ជកម្មលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានអនុញ្ញាត បើកាលណាផលិតផលទំនិញនោះត្រូវទុកសំរាប់តែធ្វើនីហរ័ណកម្មទៅកាន់ប្រទេសណាមួយ ដែលការលក់ទំនិញនោះមានលក្ខណៈស្របច្បាប់នៃប្រទេសនោះ និងក្នុងក្របខ័ណ្ឌនៃកិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិជាក់លាក់ ។

មាត្រា ១២.-

ការនាំចេញនិងនាំចូលត្រូវបង្ហាញវិញ្ញាបនប័ត្របញ្ជាក់លក្ខណៈសមស្របនៃទំនិញចំពោះផលិតផល :

-ដែលអាចប៉ះពាល់ដល់សុខភាព ឬសុវត្ថិភាពអ្នកប្រើ

-ដែលអាចប៉ះពាល់ដល់ភាពស្មោះត្រង់នៃកិច្ចការជំនួញ

-ក្នុងទិសដៅរក្សា ឬលើកកំពស់គុណភាពផលិតផលទំនិញក្នុងស្រុក

-ដែលមានការទាមទារចាំបាច់នៃពាណិជ្ជកម្មអន្តរជាតិ ឬអនុសញ្ញាអន្តរជាតិ ។

ការត្រួតពិនិត្យវិញ្ញាបនប័ត្របញ្ជាក់លក្ខណៈសមស្របនៃទំនិញជាសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម និងក្រសួងពាក់ព័ន្ធ ។

មាត្រា ១៣.-

ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការបច្ចេកទេសអន្តរជាតិក្នុងកិច្ចការត្រួតពិនិត្យទំនិញនាំចេញនិងនាំចូលជាសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម លើកលែងតែឧស្ម័ននិងប្រេងកាត ។

## ជំពូកទី ៣

## សញ្ញាគុណភាពនិងកិច្ចសារលិខិតបទដ្ឋាន

មាត្រា ១៤.-

សញ្ញាគុណភាពគឺជាសញ្ញាសំគាល់ដោយឡែកសំរាប់បញ្ជាក់អំពីកំរិតគុណភាពលើផលិតផលទំនិញ ឬសេវាដែលផលិតករ ឬសេវាករអាចយកមកបិទភ្ជាប់លើទំនិញ ឬសេវារបស់ខ្លួនដោយឥតបង្ខំ ។ ការបិទសញ្ញាគុណភាពសំដៅឆ្លើយតបនឹងតម្រូវការពិតមានរបស់អ្នកប្រើ និងដើម្បីជំរុញអោយផលិតករនិងសេវាករធ្វើអោយបានប្រសើរ និងលើកកំពស់គុណភាពនៃផលិតផលក្នុងស្រុក ។

ក្នុងករណីបិទសញ្ញាគុណភាព ផលិតករនិងសេវាករត្រូវតែអនុវត្តអោយបានខ្ជាប់ខ្ជួនតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៥៩ នៃច្បាប់នេះ ។

បែបបទនៃការកំណត់សញ្ញាគុណភាពត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងពាណិជ្ជកម្មនិងក្រសួងពាក់ព័ន្ធ ។

មាត្រា ១៥.-

បទដ្ឋានក្នុងន័យនៃច្បាប់នេះ គឺជាយថាប្រភេទបច្ចេកទេសសំរាប់សាធារណជនដែលធ្វើឡើងដោយកិច្ចសហប្រតិបត្តិការ និងការយល់ព្រមជាឯកច្ឆន្ទរាល់ភាគីសាមីឈរលើមូលដ្ឋាននៃផលិតផលទំនិញរួមរបស់វិទ្យាសាស្ត្រ បច្ចេកទេសនិងបទពិសោធន៍ ហើយត្រូវបានអនុម័តយល់ព្រមដោយស្ថាប័នជាតិមួយដែលទទួលដឹងថា មានសកម្មភាពក្នុងវិស័យបទដ្ឋានសំរាប់អនុវត្តសាចុះសាឡើងឬជានិរន្តន៍ ហើយដែលការប្រតិបត្តិតាមនោះពុំមានលក្ខណៈចាប់បង្ខំឡើយ ។

ត្រូវបានបង្កើតនូវប្រព័ន្ធជាតិមួយដើម្បីផ្តល់បទដ្ឋាននិងឯកសារបច្ចេកទេស ដែលអាចផ្តល់ដំណោះស្រាយបញ្ហាបច្ចេកទេសនិងពាណិជ្ជកម្ម ទាក់ទងទៅនឹងផលិតផល ទំនិញនិងសេវា ដែលអាចចោទឡើងផ្ទួនៗគ្នា ក្នុងទំនាក់ទំនងរវាងដៃគូសេដ្ឋកិច្ចវិទ្យាសាស្ត្រ បច្ចេកទេស ឬសង្គម ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃវិទ្យាស្ថានជាតិផ្នែកកំរិតបទដ្ឋាន ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៤

## ការបង្ក្រាបការក្លែងបន្លំពាណិជ្ជកម្ម

**មាត្រា ១៦.-**

ទោះជាភាគីចុះកិច្ចសន្យាក្តី មិនមែនភាគីចុះកិច្ចសន្យាក្តី ឬក៏តាមរយៈតតិយជនក្តី ត្រូវហាមឃាត់ការក្លែងបន្លំ ឬការប៉ុនប៉ងក្លែងបន្លំតាមមធ្យោបាយ ឬវិធីណាក៏ដោយលើផលិតផល ទំនិញនិងសេវាចំពោះ :

- អត្តសញ្ញាណ យថាប្រភេទ ប្រភេទ ប្រភព គុណភាពខាងរូបធាតុ ឬខាងទ្រទ្រង់រាងកាយ ធាតុផ្សំ បរិមាណ
- កិច្ចត្រួតពិនិត្យដែលបានធ្វើ វិធីប្រើ សម្បទាចំពោះការប្រើប្រាស់ គ្រោះថ្នាក់ភ្ជាប់នឹងការប្រើប្រាស់ ការប្រុងប្រយ័ត្នដែលត្រូវប្រកាន់យកនៃគ្រប់ផលិតផល ទំនិញ ឬសេវា
- វិធីនិងកាលបរិច្ឆេទនៃការផលិតនិងការប្រើប្រាស់ ឬនៃការបរិភោគបណ្តាផលិតផលទំនិញ ។

**មាត្រា ១៧.-**

ត្រូវបានហាមឃាត់ជាដាច់ខាតការក្លែងផលិតផលទំនិញដែលជាកម្មវត្ថុធ្វើពាណិជ្ជកម្ម ឬទុកសំរាប់ធ្វើពាណិជ្ជកម្ម ដោយធ្វើការកែច្នៃផលិតផលទំនិញតាមរបៀបណាមួយ ដោយធ្វើការបញ្ចូលបន្ថែម ការដកចេញ ឬការប្តូរជំនួសនៃភាគណាមួយ ឬភាគទាំង

មូលដែលពុំត្រូវអនុញ្ញាតអោយធ្វើដោយបទប្បញ្ញត្តិ ឬដោយទំលាប់ បើពុំមានបទប្បញ្ញត្តិ ឬដែលមិនសមស្របទៅនឹងបទប្បញ្ញត្តិ ។

ការធ្វើពាណិជ្ជកម្មនៃផលិតផលទំនិញណាមួយដោយដឹងថា ផលិតផលទំនិញនោះជាផលិតផលទំនិញក្លែងក្លាយ ត្រូវហាមឃាត់ជាដាច់ខាត ។

**មាត្រា ១៨.-**

ត្រូវហាមឃាត់ការធ្វើពាណិជ្ជកម្មនូវផលិតផលម្ហូបអាហារដែលមានសភាពប្រែប្រួលខូចគុណភាព ឬមានជាតិពុល ឬផលិតផលនោះមិនស្របនឹងលក្ខណៈវិនិច្ឆ័យគុណភាពផ្នែកអតិសុខុមជីវសាស្ត្រឬអនាម័យ ដែលកំណត់តាមបទប្បញ្ញត្តិនៃក្រសួងពាក់ព័ន្ធ។

**មាត្រា ១៩.-**

ត្រូវហាមឃាត់ការរក្សាទុកនៅគ្រប់ទីកន្លែងផលិត ទីកន្លែងសហគ្រាសរណ៍ និងទីកន្លែងធ្វើពាណិជ្ជកម្មនូវ :

- ផលិតផលក្លែងបន្លំ
- ម្ហូបអាហារដែលប្រែប្រួលខូចគុណភាពបរិភោគមិនបាន ឬមានជាតិពុល ឬមិនស្របនឹងលក្ខណៈវិនិច្ឆ័យគុណភាពផ្នែកអតិសុខុមជីវសាស្ត្រ ឬអនាម័យកំណត់តាមបទប្បញ្ញត្តិ
- ផលិតផលឧបករណ៍សំរាប់កិច្ចបន្លំ ឬក្លែងចំពោះទំនិញគ្រប់មុខ
- ត្រូវហាមឃាត់ការផលិត ការប្រើប្រាស់ ការធ្វើពាណិជ្ជកម្ម ការរក្សាទុកនូវរង្វាស់រង្វាល់និងឧបករណ៍សំរាប់វាស់វែង សំរាប់វាល់ ឬថ្លឹង ដែលខុសឬពុំទៀងទាត់ក្នុងការប្រើប្រាស់សំរាប់ផលិតកម្ម ឬពាណិជ្ជកម្មទំនិញ ។

**មាត្រា ២០.-**

ត្រូវហាមឃាត់ការធ្វើពាណិជ្ជកម្មនូវបណ្តាផលិតផល និងឧបករណ៍ដែលសំដៅយកមកបំពេញកិច្ចបន្លំ ឬក្លែងមុខទំនិញទាំងឡាយ ។

មាត្រា ២១.-

ត្រូវហាមឃាត់រាល់ការផ្សាយពាណិជ្ជកម្មគ្រប់ប្រភេទ ទោះតាមទំរង់ណាក៏ដោយដែលមានលក្ខណៈភូតកុហក ពង្វាងការពិត ក្លែងបន្លំឬធ្វើអោយមានការភ័ន្តច្រឡំអំពីគុណភាពសុវត្ថិភាពលើផលិតផល ទំនិញនិងសេវាដែលទាក់ទិនទៅនឹង :

- ប្រសិទ្ធិភាពមុខនាទី
- អត្តសញ្ញាណ យថាប្រភេទ ប្រភេទ ប្រភព គុណភាពខាងរូបធាតុ ឬខាងទ្រទ្រង់រាងកាយ ធាតុផ្សំ បរិមាណ របៀបនិងកាលបរិច្ឆេទនៃការផលិត
- កាលបរិច្ឆេទផុតកំណត់ប្រើប្រាស់ វិធីនិងល័ក្ខខ័ណ្ឌនៃការប្រើប្រាស់
- របៀបនៃការលក់ អត្ថិភាព តំលៃ
- ការធានាអះអាងផ្សេងៗទៀតដែលបានសន្យា ។

អ្នកសុំផ្សាយដំណឹងពាណិជ្ជកម្ម ដែលបានចាត់ចែងអោយធ្វើការផ្សាយពាណិជ្ជកម្មដើម្បីប្រយោជន៍ខ្លួន ត្រូវទទួលខុសត្រូវ ក្នុងឋានៈជាអ្នកដើមអាទិ៍ ។

អ្នកសុំផ្សាយដំណឹងពាណិជ្ជកម្មត្រូវផ្តល់ពត៌មាន អំពីខ្លឹមសារទាំងឡាយដែលបញ្ជាក់ពីគុណភាព សុវត្ថិភាព ព្រមទាំងការអះអាងផ្សេងទៀតក្នុងការផ្សាយពាណិជ្ជកម្មជូនស្ថាប័នត្រួតពិនិត្យដែលមានចែងក្នុងមាត្រា ២៧នៃច្បាប់នេះ ។ ករណីដែលខ្លឹមសារនៃការផ្សាយពាណិជ្ជកម្មណាផ្ទុយនឹងវាក្យខ័ណ្ឌ១ និង ២ខាងលើ ត្រូវអនុវត្តតាមមាត្រា ២៦នៃច្បាប់នេះ ។

## ជំពូកទី ៥

## វិធានការទប់ស្កាត់ផលិតផល ទំនិញ និង សេវា ដែលអាចបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬគ្រោះថ្នាក់ដែលអាចនឹងកើតបន្ទាន់

មាត្រា ២២.-

ចំពោះផលិតកម្ម សហគ្គាករណ៍ ពាណិជ្ជកម្មនៃផលិតផលទំនិញ ឬសេវាដែលអាចបង្កអោយមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬអាចបង្កអោយមានគ្រោះថ្នាក់បន្ទាន់ ចំពោះសុខភាព ឬសុវត្ថិភាពដល់អ្នកប្រើ ក្រសួងមានសមត្ថកិច្ចអាចចាត់វិធានការ :

- បញ្ឈប់ជាស្ថាពរ ឬសិរាប់រយៈពេលកំណត់មួយ

- បិទទ្វារគ្រឹះស្ថានផលិតជាបណ្ដោះអាសន្ន ឬជាស្ថាពរ

- ក្នុងករណីចាំបាច់បន្ទាន់អាចធ្វើការឃាត់ទុកនៅនឹងកន្លែងរឹបអូស ឬបំផ្លាញចោលនូវផលិតផលទំនិញទាំងនោះ ។

ការបំផ្លាញចោលអាចធ្វើទៅបានលុះត្រាតែមានការព្រមព្រៀងគ្នាជាមុនដែលអាចធ្វើឡើងជាលាយលក្ខអក្សររវាងអាជ្ញាធរមានសមត្ថកិច្ចនិងម្ចាស់ផលិតផលទំនិញកើតហេតុ ។ ក្នុងករណីគ្មានការព្រមព្រៀងរវាងអាជ្ញាធរមានសមត្ថកិច្ច និងម្ចាស់ផលិតផលទំនិញកើតហេតុនោះ ភាគីម្ចាស់ផលិតផលទំនិញកើតហេតុ អាចប្ដឹងទៅតុលាការខេត្តក្រុង ក្នុងរយៈពេលដែលមានកំណត់ក្នុងវិធានការ ។

ផលិតកម្ម សហគ្គាករណ៍ ពាណិជ្ជកម្មព្រមទាំងគ្រឹះស្ថាននានាដែលត្រូវបានបញ្ឈប់ឬបិទទ្វារជាបណ្ដោះអាសន្ន អាចដំណើរការឡើងវិញបាន លុះត្រាតែមានការអនុញ្ញាតពីក្រសួងមានសមត្ថកិច្ច ។

**មាត្រា ២៣.-**

ក្រសួងមានសមត្ថកិច្ចអាចចេញប្រកាសបង្គាប់ដល់នីតិបុគ្គល ឬរូបវ័ន្តបុគ្គលដែលមានចែងក្នុងមាត្រា ១ នៃច្បាប់នេះតម្រូវអោយកែប្រែចាំបាច់សំដៅគោរពកាតព្វកិច្ចផ្នែកគុណភាព សុវត្ថិភាពដែលកំណត់នៅក្នុងមាត្រា៣ នៃច្បាប់នេះ ។

ការចំណាយក្នុងការផ្សព្វផ្សាយនូវកិច្ចព្រមានទប់ទល់ ឬវិធានការប្រុងប្រយ័ត្នក្នុងការប្រើប្រាស់នោះ ព្រមទាំងអោយមានការប្រមូលផលិតផលត្រលប់មកវិញ ដើម្បីធ្វើការផ្លាស់ប្ដូរកែប្រែ ឬការសងតំលៃទាំងស្រុងឬមួយផ្នែកវិញ ជាបន្ទុកផ្ទាល់របស់អ្នកទទួលខុសត្រូវ ដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ ។

**មាត្រា ២៤.-**

វិធានការដូចគ្នានិងបណ្ដាវិធានការនានានៃមាត្រា ២២ និងមាត្រា ២៣ នៃច្បាប់នេះ អាចចាត់ចែងឡើងដើម្បីធានាសុវត្ថិភាពនិងកិច្ចបំពេញសេវា ។

# ជំពូកទី ៦

## នីតិវិធីនៃការត្រួតពិនិត្យគុណភាព

## សុវត្ថិភាព លើផលិតផល ទំនិញ និង សេវា

**មាត្រា ២៥.-**

រាល់បទល្មើសនឹងច្បាប់នេះ ត្រូវបានស្រាវជ្រាវនិងអង្កេតយ៉ាងហ្មត់ចត់ដោយអនុលោមទៅតាមបណ្តាបទប្បញ្ញត្តិនៃមាត្រា ២៨ ដល់មាត្រា ៥១ នៃច្បាប់នេះ ។ បទប្បញ្ញត្តិទាំងនេះ មិនអាចរារាំងទៅដល់ករណីនៃភស្តុតាងលើបទល្មើសទាំងឡាយដែលបានលើកឡើងតាមមធ្យោបាយដទៃទៀតឡើយ ។

រាល់វិធានការប្រាតិភោគត្រូវគោរពនិងប្រតិបត្តិតាមវិធានទាំងឡាយដែលមានចែងក្នុងមាត្រា ៥២ ដល់មាត្រា ៥៨ នៃច្បាប់នេះ ។

**មាត្រា ២៦.-**

ក្រសួងពាណិជ្ជកម្មនិងក្រសួងពាក់ព័ន្ធមានសមត្ថកិច្ចបង្ក្រាបការធ្វើពាណិជ្ជ-កម្មក្លែងបន្លំដោយអនុវត្តច្បាប់នេះ ។ ក្រសួងទាំងនេះត្រូវរៀបចំអង្គភាពជំនាញដើម្បីទទួលបន្ទុកបង្ក្រាបការក្លែងបន្លំ និងការត្រួតពិនិត្យទំនិញនៅពេលនាំចេញនិងនាំចូល ។

**មាត្រា ២៧.-**

រាល់សកម្មភាពពិនិត្យស្រាវជ្រាវអំពីគុណភាព សុវត្ថិភាពលើផលិតផលទំនិញនិងសេវា ព្រមទាំងពិនិត្យកំណត់ហេតុបទល្មើស ឬចាត់វិធានការប្រាតិភោគជាសមត្ថ-កិច្ចរបស់ភ្នាក់ងារត្រួតពិនិត្យក្រសួងពាណិជ្ជកម្ម ដោយសហការជាមួយក្រសួងពាក់ព័ន្ធ ។

**មាត្រា ២៨.-**

ភ្នាក់ងារត្រួតពិនិត្យដែលមានចែងក្នុងមាត្រា ២៧ នៃច្បាប់នេះ មានសមត្ថកិច្ចពិនិត្យបញ្ជាក់ អង្កេត ធ្វើកំណត់ហេតុ និងធ្វើសវនកម្មនៃបញ្ហាដែលពាក់ព័ន្ធ ។ កំណត់ហេតុនេះមានតំលៃជាបន្ទាល់ រហូតដល់មានការបង្ហាញភស្តុតាងផ្ទុយ ។

បុគ្គលជាប់អង្កេតត្រូវបង្កលក្ខណៈងាយស្រួលនិងផ្តល់លទ្ធភាពសំរាប់កិច្ចប្រតិបត្តិការត្រួតពិនិត្យ ជូនភ្នាក់ងារដែលចុះត្រួតពិនិត្យ ។

ភ្នាក់ងារត្រួតពិនិត្យអាចស្នើសុំនូវកំលាំងជំនួយដើម្បីការពារនិងធ្វើអន្តរាគមន៍ ។

**មាត្រា ២៩.-**

ភ្នាក់ងារត្រួតពិនិត្យដែលមានចែងក្នុងមាត្រា ២៧ នៃច្បាប់នេះ អាចចូលទៅពិនិត្យក្នុងទីកន្លែងផលិតកម្ម សហគ្រាសករណ៍ ពាណិជ្ជកម្ម អាជីវកម្ម និងសេវាកម្មព្រមទាំងចូលពិនិត្យក្នុងមធ្យោបាយដឹកជញ្ជូនទំនិញ ឃ្លាំងស្តុកទំនិញ ការិយាល័យ និងកន្លែងផ្សេងៗទៀតដែលពាក់ព័ន្ធ ។

ប្រសិនបើទីកន្លែងណាមួយខាងលើត្រូវបានប្រើប្រាស់ជាកន្លែងសំរាប់ស្នាក់នៅផងនោះ ភ្នាក់ងារអាចចូលទៅត្រួតពិនិត្យបានតែក្នុងពេលកំពុងមានសកម្មភាព ។ ក្នុងករណីក្រៅពេលធ្វើសកម្មភាព ត្រូវតែមានការអនុញ្ញាតពីព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង និងវត្តមាននៃអាជ្ញាធរឃុំ-សង្កាត់ ។

**មាត្រា ៣០.-**

ភ្នាក់ងារត្រួតពិនិត្យដែលបានចែងនៅក្នុងមាត្រា ២៧នៃច្បាប់នេះ អាចសាកសួរ ធ្វើការចំលង ឬដកហូតឯកសារដែលពាក់ព័ន្ធនឹងការអង្កេត ។

ក្នុងករណីដកហូត តម្រូវអោយមានកំណត់ហេតុជាផ្លូវការមួយដែលត្រូវតាក់តែងភ្លាមៗ ។

ឯកសារដកហូតទាំងអស់នេះ ត្រូវបិទបោះត្រាពីភ្នាក់ងារត្រួតពិនិត្យ ។ ភ្នាក់ងារត្រួតពិនិត្យត្រូវចេញបង្កាន់ដៃសំគាល់នូវការដកហូត និងផ្តល់នូវកំណត់ហេតុជូនដល់បុគ្គលដែលបានទទួលការដកហូត ។

កំណត់ហេតុដែលតាក់តែងឡើងដោយពុំគោរពតាមគោលការណ៍នេះ ត្រូវចាត់ទុកជាមោឃៈ ។

រាល់ឯកសារដកហូតទាំងនោះនឹងត្រូវភ្ជាប់ជាមួយនីតិវិធីដែលបានកំណត់នៅក្នុងមាត្រា ៥១នៃច្បាប់នេះ ឬប្រគល់អោយទៅសាមីខ្លួនវិញ ប្រសិនបើពុំមានហេតុការណ៍គួរអោយស្ដីបន្ទោសណាមួយ ត្រូវធ្វើចំពោះខ្លួនគេទេនោះ កំណត់ហេតុនៃការប្រគល់ត្រលប់វិញ ត្រូវលើកឡើងតាមទំរង់ដូចគ្នានេះដែរ ។

បើឯកសារដកហូតមានសារៈសំខាន់ចាំបាច់សំរាប់ការបន្តសកម្មភាពរបស់សហគ្រាស ភ្នាក់ងារត្រួតពិនិត្យត្រូវផ្ដល់ច្បាប់ចំលងតាមសំណើ ឯការចំណាយត្រូវស្ថិតក្នុងបន្ទុករបស់សាមីខ្លួន ។

មាត្រា ៣១.-

ភ្នាក់ងារត្រួតពិនិត្យដែលមានចែងក្នុងមាត្រា ២៧នៃច្បាប់នេះ អាចដកហូតនូវគ្រប់វត្ថុតាង ឬគ្រប់គំរូទំនិញសម្រាប់ប្រើជាវត្ថុតាង តាមនីតិវិធីមួយដែលមានចែងដោយអនុក្រឹត្យ ។

មាត្រា ៣២.-

ភ្នាក់ងារត្រួតពិនិត្យដែលមានចែងក្នុងមាត្រា ២៧ នៃច្បាប់នេះ អាចប្រមូលដោយធ្វើកំណត់ហេតុនូវសេចក្ដីពោលអះអាងហេតុការណ៍នានានៃបុគ្គលដែលអាចផ្ដល់នូវពត៌មាន ដែលមានប្រយោជន៍ដល់ការអង្កេតរបស់គេ ។

កំណត់ហេតុនៃសេចក្ដីពោលអះអាងហេតុការណ៍ត្រូវមានសេចក្ដីបញ្ជាក់ដូចតទៅ :

- លេខរៀងផ្ដល់ដោយអ្នកតាក់តែងកំណត់ហេតុ
- កាលបរិច្ឆេទ ម៉ោងនិងទីកន្លែងដែលការអះអាងត្រូវបានធ្វើឡើង
- អត្តសញ្ញាណ ឋានៈនិងអាស័យដ្ឋាននៃអ្នកអះអាងនៃម្ចាស់ហេតុការណ៍
- អត្តសញ្ញាណ ឋានៈនិងអាស័យដ្ឋាននៃម្ចាស់កំណត់ហេតុ
- សេចក្ដីបញ្ជាក់មានអត្ថប្រយោជន៍ទាំងឡាយរបស់អ្នកធ្វើកំណត់ហេតុសំរាប់រាយការណ៍ដោយស្មោះត្រង់នូវពត៌មានផ្ដល់ដោយអ្នកអះអាងហេតុការណ៍

- ហត្ថលេខារបស់អ្នកអះអាងហេតុការណ៍និងរបស់ម្ចាស់កំណត់ហេតុ ។

បើសិនជាអ្នកធ្វើសេចក្តីប្រកាសមិនចង់ ឬមិនចេះចុះហត្ថលេខា ឬក៏មិនចេះអានអក្សរ សេចក្តីបញ្ជាក់អំពីសភាពនេះត្រូវកត់ត្រាឡើងក្នុងកំណត់ហេតុ ។ កំណត់ហេតុដែលតាក់តែងឡើងដោយមិនគោរពតាមគោលការណ៍ទាំងអស់នេះ ត្រូវចាត់ទុកជាមោឃៈ ។

**មាត្រា ៣៣.-**

ភ្នាក់ងារត្រួតពិនិត្យដែលមានចែងក្នុងមាត្រា ២៧ នៃច្បាប់នេះបំពេញការកិច្ចត្រួតពិនិត្យផលិតផល ទំនិញនិងសេវាដោយការពិនិត្យផ្ទាល់ភ្នែក ឬដោយមធ្យោបាយនៃឧបករណ៍វង្វាស់វង្វាល់សាមញ្ញ និងពិនិត្យបញ្ជាក់ឯកសារក្នុងបំណងកំណត់អោយបានន្ទូវអត្តសញ្ញាណលើផលិតផល ទំនិញនិងសេវា ហើយរកអោយឃើញនូវលក្ខណៈសមស្របជាយថាហេតុលើផលិតផល ទំនិញនិងសេវានោះទៅនឹងចរិតលក្ខណៈដែលត្រូវបង្ហាញ ឬដើម្បីស្រាវជ្រាវរកថា តើល័ក្ខខ័ណ្ឌកំណត់សំរាប់ការផលិត សំរាប់កិច្ចសហគ្រាការណ៍និងសំរាប់ពាណិជ្ជកម្មនូវផលិតផល ទំនិញឬសេវានេះត្រូវបានគោរពតាម ឬយ៉ាងណា ។

ភ្នាក់ងារត្រូវរាយការណ៍អំពីការពិនិត្យនិងកត់ហេតុរបស់ខ្លួនក្នុងកំណត់ហេតុដែលត្រូវមាន :

- លេខរៀងផ្តល់ដោយអ្នកធ្វើការពិនិត្យហេតុ
- កាលបរិច្ឆេទ ម៉ោងនិងទីកន្លែងដែលការពិនិត្យកត់ហេតុនោះបានធ្វើឡើង
- អត្តសញ្ញាណ មុខវិជ្ជាជីវៈ និងអាស័យដ្ឋានរបស់បុគ្គលិកដែលជាកម្មវត្ថុនៃកិច្ចត្រួតពិនិត្យ
- គ្រប់ពត៌មានដែលមានលក្ខណៈសំរាប់បញ្ជាក់ដោយលំអិតនូវតំលៃនៃកិច្ចពិនិត្យកត់ហេតុដែលបានធ្វើ
- លេខចុះបញ្ជីនៅស្ថាប័នជាកន្លែងធ្វើការងាររបស់អ្នកធ្វើកិច្ចពិនិត្យកត់ហេតុ
- ហត្ថលេខាអ្នកធ្វើកិច្ចពិនិត្យកត់ហេតុ ។

របាយការណ៍អំពីការពិនិត្យនិងកត់ហេតុដែលតាក់តែងឡើងដោយពុំគោរព តាមគោលការណ៍ទាំងអស់នេះ ត្រូវចាត់ទុកជាមោឃៈ ។

ភ្នាក់ងារអាចភ្ជាប់មកជាមួយនូវរូបថតនៃភាពមិនប្រក្រតីដែលពិនិត្យឃើញ ដើម្បីជាលក្ខណៈសំរាប់ឆ្លុះបញ្ចាំងបន្ថែម ។

**មាត្រា ៣៤.-**

លើកលែងតែករណីចែងក្នុងមាត្រា ៤០នៃច្បាប់នេះ កិច្ចយកគំរូសំរាប់វិភាគ ទាំងឡាយត្រូវមានយ៉ាងហោចណាស់ នូវគំរូទំនិញចំនួនបី ។

គំរូទីមួយ ទុកសំរាប់ភ្នាក់ងារមានសមត្ថកិច្ចបញ្ជូនទៅមន្ទីរពិសោធន៍ទទួល បន្ទុកធ្វើការវិភាគ ចំណែកឯគំរូពីរផ្សេងទៀតទុកសំរាប់ប្រើប្រាស់ក្នុងរយៈកាលនៃប្រតិបត្តិ ការជាយថាហេតុនៃការវិភាគតបវិញដូចមានកំណត់ក្នុងមាត្រា ៤៧ ដល់មាត្រា ៥០ នៃ ច្បាប់នេះ ។

**មាត្រា ៣៥.-**

អ្នកកាន់កាប់ផលិតផលដែលភ្នាក់ងារបានយកគំរូទំនិញត្រូវចុះហត្ថលេខា លើកំណត់ហេតុ ។ អ្នកកាន់កាប់នោះអាចកត់ត្រាបញ្ជាក់លើកំណត់ហេតុនូវសេចក្តីកត់ សំគាល់នានាអំពីប្រភព ឬចរិតលក្ខណៈនៃផលិតផលនោះ ដែលគេយល់ថាមានអត្ថប្រ-យោជន៍ ។ ប្រសិនបើអ្នកកាន់កាប់នោះមិនចង់ ឬមិនចេះចុះហត្ថលេខា ឬក៏មិនចេះអាន អក្សរនោះ ការកំណត់សំគាល់អំពីសភាពនេះត្រូវកត់ត្រាឡើងក្នុងកំណត់ហេតុ ។

តាមសំណើពីអ្នកកាន់កាប់ផលិតផល ភ្នាក់ងារយកគំរូទំនិញត្រូវផ្តល់ជូន នូវបង្កាន់ដៃដែលមានបញ្ជាក់អំពីប្រភេទ បរិមាណនិងតំលៃនៃផលិតផលដែលយកធ្វើជា គំរូនោះ សំរាប់ការគិតគូរសងថ្លៃជាយថាហេតុនៅពេលក្រោយ ។

**មាត្រា ៣៦.-**

នីតិវិធីនៃការយកគំរូទំនិញជាសមត្ថកិច្ចជំនាញរបស់ភ្នាក់ងារ ដោយតម្រូវ អោយគំរូទាំងបីមានលក្ខណៈដូចគ្នានិងមានចរិតបង្ហាញលក្ខណៈតំណាងអោយឡូត៍ទំនិញ ដែលត្រូវត្រួតពិនិត្យ ។

មាត្រា ៣៧.-

គំរូទំនិញនីមួយៗត្រូវរក្សាទុកដោយបិទបោះត្រា ។ ការបិទបោះត្រានេះត្រូវមានភ្ជាប់នូវផ្លាកបញ្ជាក់ដែលមានកំណត់ជាអាទិ៍ :

- ឈ្មោះទំនិញដែលត្រូវហៅនៅពេលកាន់កាប់ក្នុងបំណងសំរាប់លក់ពេលដាក់លក់ឬបានលក់ហើយ

- កាលបរិច្ឆេទ ម៉ោងនិងទីកន្លែងនៃការយកគំរូ

- អត្តសញ្ញាណនិងអាស័យដ្ឋានរបស់បុគ្គលដែលការយកគំរូទំនិញត្រូវបានធ្វើនៅកន្លែងរបស់គេ

- លេខរៀងផ្តល់សំរាប់ប្រតិបត្តិការនេះដោយអ្នកយកគំរូ

- លេខចុះបញ្ជីនៃការយកគំរូទំនិញ ផ្តល់ដោយស្ថាប័នសាធារណៈដែលអ្នកយកគំរូទំនិញបំពេញការងារ ព្រមទាំងការបញ្ជាក់យ៉ាងច្បាស់លាស់ចំពោះស្ថាប័ននោះ

- កំណត់សំគាល់អត្ថប្រយោជន៍ទាំងឡាយដែលអាចអោយមន្ទីរពិសោធន៍បានដឹងនូវគោលដៅស្រាវជ្រាវ ដោយមានឯកសារជាក់លាក់ភ្ជាប់មកជាមួយនឹងផ្លាកបញ្ជាក់

- ហត្ថលេខានៃអ្នកយកគំរូទំនិញ និងហត្ថលេខារបស់អ្នកកាន់កាប់ផលិតផលទំនិញដែលបានយកគំរូ ។

មាត្រា ៣៨.-

គំរូទំនិញមួយក្នុងចំណោមគំរូទំនិញទាំងបី ត្រូវរក្សាទុកនៅក្រោមកិច្ចថែរក្សារបស់អ្នកកាន់កាប់ឬម្ចាស់ផលិតផលដែលត្រូវបានយកគំរូទំនិញ ។ ភ្នាក់ងារត្រួតពិនិត្យត្រូវណែនាំអំពីរបៀបរបបនៃការរក្សាទុកគំរូទំនិញដល់អ្នកទាំងនោះ សំដៅធានាលក្ខណៈសម្បត្តិមួយដើម្បីអោយការវិភាគនៅពេលក្រោយអាចធ្វើទៅបានត្រឹមត្រូវ ។

បើសាមីខ្លួនប្រកែកពុំព្រមទទួលទុក ការបញ្ជាក់ហេតុការណ៍នេះត្រូវធ្វើក្នុងកំណត់ហេតុ ហើយគំរូទំនិញត្រូវថែរក្សាទុកជាមួយគំរូទំនិញទាំងពីរផ្សេងទៀតដោយភ្នាក់ងារត្រួតពិនិត្យ ។

មាត្រា ៣៩.-

គំរូទំនិញពីរផ្សេងទៀតត្រូវបញ្ជូនដោយមានភ្ជាប់កំណត់ហេតុ ទៅទីស្នាក់ការនៃស្ថាប័នជំនាញសាធារណៈដែលអ្នកយកគំរូទំនិញបំពេញការងារ ។

ស្ថាប័នសាធារណៈនេះទទួលយកគំរូទំនិញទាំងនោះទៅរក្សាទុក ចុះបញ្ជីនិងចុះលេខចូលនៅលើផ្លាកសញ្ញាព្រមទាំងលើកំណត់ហេតុ ។ បន្ទាប់មកស្ថាប័ននេះបញ្ជូនគំរូទំនិញមួយទៅមន្ទីរពិសោធន៍មានសមត្ថកិច្ច ហើយថែរក្សាទុកដាក់គំរូទំនិញមួយផ្សេងទៀតក្នុងលក្ខណៈសម្បត្តិដែលអាចធានាការរក្សាទុកបានល្អ ។

ក្នុងករណីតម្រូវអោយមានការរក្សាទុកតាមល័ក្ខខ័ណ្ឌពិសេស គំរូទំនិញទាំងពីរឬជាយថាហេតុគំរូទំនិញទាំងបី យោងតាមវាក្យខ័ណ្ឌ២ នៃមាត្រា ៣៨ ក្នុងច្បាប់នេះអាចបញ្ជូនទៅមន្ទីរពិសោធន៍ដោយប្រគល់បន្ទុកអោយមន្ទីរពិសោធន៍នោះលើកវិធានការចាំបាច់ ។

មាត្រា ៤០.-

ចំពោះផលិតផលទំនិញណាមួយដែលមិនអាចជាកម្មវត្ថុនៃការយកគំរូទំនិញជាបីបាន ដោយហេតុផលនៃចរិតលក្ខណៈឬតំលៃរបស់វានោះ ការយកគំរូទំនិញត្រូវធ្វើឡើងជាគំរូទំនិញតែមួយគត់ទៅលើផលិតផលទាំងមូលឬមួយផ្នែក ។

ការអនុវត្តដូចវាក្យខ័ណ្ឌ១ខាងលើ ត្រូវធ្វើចំពោះផលិតផលទំនិញដែលការវិភាគដោយហេតុផលវិទ្យាសាស្ត្រឬបច្ចេកទេសអាចធ្វើបានតែក្នុងរយៈពេលមួយកំណត់ហើយដែលរារាំងឬធ្វើមិនអោយមានតំលៃដល់ការវិភាគនៅពេលក្រោយ ។

ត្រូវធ្វើកំណត់ហេតុនៃកិច្ចយកគំរូទំនិញតែមួយនេះ ហើយនៅលើគំរូទំនិញត្រូវបិទបោះត្រាដោយមានផ្លាកសញ្ញាក្នុងល័ក្ខខ័ណ្ឌដូចគ្នាដែលមានចែងក្នុងមាត្រា ៣៥និងមាត្រា ៣៧ នៃច្បាប់នេះ ។ កិច្ចយកគំរូទំនិញត្រូវចុះបញ្ជី ហើយវត្ថុគំរូទំនិញត្រូវធ្វើទៅអោយ ឬដាក់ក្រោមការចាត់ចែងរបស់មន្ទីរពិសោធន៍ តាមទំរង់បែបបទដូចដែលបានចែងនៅក្នុងមាត្រា ៣៩ នៃច្បាប់នេះ ។

មាត្រា ៤១.-

ការយកគំរូទំនិញដោយឡែកមួយទៀតហៅថាគំរូអង្កេត អាចធ្វើឡើងផងដែរ សំរាប់ការវិភាគនៅមន្ទីរពិសោធន៍ ឬសំរាប់ការកំណត់បញ្ជាក់ជាលក្ខណៈគ្រួសៗធ្វើដោយស្ថាប័នអធិការកិច្ចផ្ទាល់ ក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចជំនាញរបស់ខ្លួន ។ ការយកគំរូនេះធ្វើឡើងជាគំរូទំនិញតែមួយ ។

លទ្ធផលនៃការពិនិត្យគំរូអង្កេតនេះមានតំលៃសំរាប់តែជាពត៌មានប៉ុណ្ណោះ ហើយមិនអាចប្រើប្រាស់សំរាប់ធ្វើជាមូលដ្ឋាននៃការប្តឹងផ្តល់ ដូចមានចែងក្នុងមាត្រា ៥១ នៃច្បាប់នេះ ឬសំរាប់ជាវិធានប្រតិភោគដូចមានចែងក្នុងមាត្រា ៥២ ដល់មាត្រា ៥៨ នៃច្បាប់នេះឡើយ លើកលែងតែការឃាត់ទុកជាបណ្តោះអាសន្នដែលមានចែងនៅមាត្រា ៥៣ នៃច្បាប់នេះ ។

មាត្រា ៤២.-

ផលិតផលគំរូទំនិញត្រូវធ្វើការវិភាគដោយមន្ទីរពិសោធន៍របស់ស្ថាប័នរដ្ឋ ។

មន្ទីរពិសោធន៍សាធារណៈ ឬឯកជនផ្សេងទៀតដែលត្រូវបានទទួលស្គាល់ពីក្រសួងមានសមត្ថកិច្ច អាចទទួលកិច្ចការដើម្បីធ្វើការវិភាគផលិតផលគំរូទំនិញផងដែរ ។ ការទទួលស្គាល់ចំពោះមន្ទីរពិសោធន៍សាធារណៈ ឬឯកជន ត្រូវធ្វើដោយប្រកាសពីក្រសួងមានសមត្ថកិច្ច ។ ប្រកាសនេះ ត្រូវកំណត់អោយបានច្បាស់លាស់អំពីសមត្ថកិច្ចនៃមន្ទីរពិ-សោធន៍ទាំងនោះ ។

មាត្រា ៤៣.-

ក្នុងការវិភាគផលិតផលគំរូទំនិញ មន្ទីរពិសោធន៍ត្រូវប្រើវិធីវិភាគដែលត្រូវបានកំណត់ដោយប្រកាសនៃក្រសួងពាក់ព័ន្ធ ។

ក្នុងករណីពុំមានវិធីវិភាគខាងលើទេនោះ មន្ទីរពិសោធន៍ត្រូវអនុវត្តតាមវិធីវិភាគដែលត្រូវបានណែនាំអោយអនុវត្តតាមបែបបទអន្តរជាតិ ។ វិធីវិភាគនោះត្រូវចុះនៅក្នុងព្រឹត្តប័ត្រវិភាគ ។

មាត្រា ៤៤.-

ពេលបញ្ចប់ការងារ មន្ទីរពិសោធន៍ត្រូវតាក់តែងព្រឹត្តប័ត្រវិភាគដែលមានកត់ត្រាលទ្ធផលនៃការវិភាគស្រាវជ្រាវ ។ មន្ទីរពិសោធន៍អាចធ្វើការសន្និដ្ឋានទៅលើលក្ខណៈពុំសមស្របនៃផលិតផលទៅនឹងច្បាប់នេះ ឬបទប្បញ្ញត្តិជាក់ស្តែង ប្រសិនបើផលវិភាគទាំងនោះមានចរិតលក្ខណៈបំភ្លឺដល់ស្ថាប័នមានសមត្ថកិច្ច ។

មាត្រា ៤៥.-

បើព្រឹត្តប័ត្រវិភាគរបស់មន្ទីរពិសោធន៍បានបញ្ជាក់ថា ផលិតផលគំរូទំនិញមានលក្ខណៈស្របតាមចរិតលក្ខណៈដែលកំណត់ក្នុងច្បាប់ហើយ ស្ថាប័នដែលបានចាត់ចែងការយកគំរូទំនិញពុំមានពត៌មានផ្សេងណាទៀត ដែលបានបញ្ជាក់អំពីការក្លែងបន្លំទេនោះ ស្ថាប័ននេះត្រូវផ្តល់ដំណឹងដល់សាមីជនអំពីលក្ខណៈត្រឹមត្រូវនៃផលិតផលនោះ ។

មាត្រា ៤៦.-

បើការវិភាគបានបង្ហាញថាផលិតផលគំរូទំនិញមិនមានលក្ខណៈស្របទៅនឹងចរិតលក្ខណៈដែលកំណត់ដោយច្បាប់ទេនោះ វិធីដែលមានចែងនៅក្នុងមាត្រា ៤៧ដល់មាត្រា ៥០ នៃច្បាប់នេះ ត្រូវយកមកអនុវត្ត ។

មាត្រា ៤៧.-

បើលទ្ធផលនៃការវិភាគរបស់មន្ទីរពិសោធន៍បង្ហាញនូវលក្ខណៈពុំស្របទៅនឹងចរិតលក្ខណៈដែលកំណត់ដោយច្បាប់ ហើយក្រោយពីការយកគំរូ ឬការធ្វើអង្កេតចាំបាច់បន្ថែមផ្សេងទៀត ស្ថាប័នដែលបានអនុវត្តការត្រួតពិនិត្យត្រូវផ្តល់ដំណឹងដល់ជនជាប់សង្ស័យក្នុងបទល្មើសអំពីការទទួលខុសត្រូវចំពោះមុខច្បាប់ តាមផ្លូវតុលាការដោយមានការបញ្ជាក់ហេតុផលដល់សាមីជន ។

សាមីជនមានសិទ្ធិធ្វើការវិភាគតបវិញ និងជ្រើសរើសអ្នកជំនាញរបស់ខ្លួនក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ ។

បើសិនគ្មានការសុំសិទ្ធិក្នុងរយៈពេលកំណត់ខាងលើនេះទេ លទ្ធផលនៃការវិភាគដូចមានចែងក្នុងវាក្យខ័ណ្ឌ១ មិនអាចត្រូវជជែកតវ៉ាបានឡើយ លើកលែងតែមានករណីប្រធានស័ក្តិដែលប៉ះពាល់ដល់ការឆ្លើយតប ។

មាត្រា ៤៨.-

ការចំណាយសំរាប់អ្នកឯកទេសបំពេញការងារជាបន្ទុករបស់សាមីជនដែលស្នើសុំធ្វើការតបវិញ ។ ការជ្រើសរើសអ្នកឯកទេសខាងលើនេះ ត្រូវតែយកពីបញ្ជីរាយនាមអ្នកឯកទេស ដែលរៀបចំឡើងដោយតុលាការខេត្ត-ក្រុង ។

ក្នុងករណីពុំមានអ្នកឯកទេសដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងបញ្ជីរាយនាមខាងលើ ឬក្នុងករណីពុំទាន់មានបញ្ជីនេះទេនោះ សាមីជនអាចជ្រើសរើសអ្នកឯកទេសផ្សេងមួយទៀតបាន ។ ក្នុងករណីនេះ ការជ្រើសរើសតម្រូវអោយមានការយល់ព្រមពីតុលាការខេត្ត-ក្រុង ។ ការសំរេចកំណត់យល់ព្រមនេះ ត្រូវធ្វើក្នុងរយៈពេល៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការ ។

មាត្រា ៤៩.-

ផលិតផលគំរូរក្សាទុកបំរុងដោយស្ថាប័នដែលបានធ្វើការចុះបញ្ជីការយកគំរូត្រូវប្រគល់អោយអ្នកឯកទេសដូចមានចែងក្នុងមាត្រា ៤៨នៃច្បាប់នេះ ។ អ្នកឯកទេសមានរយៈពេល១(មួយ)ខែ ដើម្បីបង្ហាញដល់ស្ថាប័នដែលបានអនុវត្តការត្រួតពិនិត្យនូវការសន្និដ្ឋានរបស់ខ្លួន ដែលទាក់ទងតែទៅលើទិដ្ឋភាពវិទ្យាសាស្ត្របច្ចេកទេសតែប៉ុណ្ណោះ ។

ពេលណាការសន្និដ្ឋាននេះខុសប្លែកពីការសន្និដ្ឋានលើការវិភាគលើកទីមួយដូចមានចែងក្នុងមាត្រា ៤៧ អ្នកឯកទេសនិងនាយកមន្ទីរពិសោធន៍ដែលបានចាត់ចែងធ្វើការវិភាគលើកទីមួយ ត្រូវប្រជុំគ្នាដើម្បីពិភាក្សាវែកញែកករណីនេះ នៅពេលមួយដែលកំណត់ឡើងដោយស្ថាប័នអនុវត្តការត្រួតពិនិត្យ ។ បើមានតម្រូវការចាំបាច់ អ្នកទាំងពីររួមគ្នាធ្វើការវិភាគជាថ្មីទៀតនូវផលិតផលគំរូទិន្និញទីបីចុងក្រោយ ។ របាយការណ៍រួមត្រូវធ្វើឡើងហើយផ្ញើទៅស្ថាប័ននេះក្នុងរយៈពេល១(មួយ)ខែ ដោយគិតតាំងពីថ្ងៃរួមប្រជុំមក ។

អ្នកឯកទេសត្រូវប្រើវិធីមួយ ឬវិធីទាំងឡាយដែលត្រូវបានប្រើប្រាស់ដោយមន្ទីរពិសោធន៍ និងធ្វើការរកចំណុចកំណត់ដូចបានធ្វើការវិភាគលើកទីមួយ ។

### មាត្រា ៥០.-

បើសាមីជនទាមទារការវិភាគតបវិញចំពោះផលិតផលដែលមានគំរូតែមួយដូចមានចែងក្នុងមាត្រា ៤០ នៃច្បាប់នេះ តម្រូវអោយមានវិធានការចាត់ចែងដោយអនុវត្តតាមមាត្រា ៤៧ និងមាត្រា ៤៨ នៃច្បាប់នេះ ។ កិច្ចការវិភាគបន្ទាន់នេះត្រូវធ្វើលើសំណុំឯកសារនៃលទ្ធផលដែលបានពីការវិភាគលើកដំបូង ។

អ្នកឯកទេសដែលជ្រើសរើសដោយសាមីជននិងនាយកមន្ទីរពិសោធន៍ដែលបានចាត់ចែងធ្វើការវិភាគ ត្រូវប្រជុំគ្នាដើម្បីពិភាក្សាសេចក្តីសន្និដ្ឋាននៃការវិភាគ នៅពេលវេលាមួយដែលកំណត់ដោយស្ថាប័នអនុវត្តការត្រួតពិនិត្យ ។ របាយការណ៍រួមមួយត្រូវធ្វើឡើង ហើយបញ្ជូនមកស្ថាប័ននេះ ក្នុងរយៈពេល២(ពីរ)ថ្ងៃដោយគិតពីថ្ងៃប្រជុំមក ។

### មាត្រា ៥១.-

ក្នុងករណីដែលត្រូវប្តឹងទៅតុលាការ ភ្នាក់ងារត្រួតពិនិត្យត្រូវរៀបចំសំណុំឯកសារកំណត់ហេតុ ព្រឹត្តប័ត្រវិភាគព្រមទាំងរបាយការណ៍កោសល្យវិច័យនិងសំអាងដទៃទៀតបើមាន ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

### មាត្រា ៥២.-

ភ្នាក់ងារត្រួតពិនិត្យដែលមានចែងក្នុងមាត្រា ២៧នៃច្បាប់នេះ ត្រូវធ្វើការឃាត់ទុកបណ្តោះអាសន្ន ការចាត់ចែងអោយមានលក្ខណៈសមស្រប ការប្តូរទិសដៅ ការរឹបអូសនិងការកំទេចចោលនូវផលិតផលទំនិញ ព្រមទាំងការធ្វើអោយសមស្របឡើងវិញនូវសេវាដោយអនុលោមទៅតាមបែបបទនៃច្បាប់នេះ ។

វិធានការអោយមានការសមស្របឡើងវិញ ការប្តូរទិសដៅ ការរឹបអូសនិងការកំទេចចោល នឹងអាចចាត់ចែងទៅបានដោយភ្នាក់ងារមានសមត្ថកិច្ច លុះត្រាមានការ

អនុញ្ញាតពីប្រធានស្ថាប័នរបស់ខ្លួន និងមានការយល់ព្រមពីព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង ។ បទប្បញ្ញត្តិនេះពុំត្រូវបានអនុវត្តទេ បើបណ្តាវិធានការត្រូវបានបង្គាប់ឡើងក្នុងបញ្ញត្តិនៃមាត្រា ២២ ដល់មាត្រា ២៤ នៃច្បាប់នេះ ។

មាត្រា ៥៣.-

ការឃាត់ទុកបណ្តោះអាសន្នគឺជាវិធានការសំដៅហាមឃាត់ជាបណ្តោះអាសន្នរាល់ការចាត់ចែងពីសំណាក់អ្នកកាន់កាប់នូវផលិតផលទំនិញដែលពាក់ព័ន្ធដោយអនុវត្តទៅលើ :

ក- ឡូតិ៍ផលិតផលទំនិញមន្ទិលសង្ស័យ

ខ- ឡូតិ៍ផលិតផលទំនិញដែលបានទទួលស្គាល់តាមការពិនិត្យកត់ត្រាផ្ទាល់ថាពុំសមស្របនឹងចរិតលក្ខណៈដែលកំណត់ដោយច្បាប់ ឬឡូតិ៍ផលិតផលទំនិញដែលការប្រើប្រាស់ធម្មតាអាចធ្វើអោយប៉ះពាល់ដល់សុវត្ថិភាពឬសុខភាពនៃអ្នកប្រើ

គ- ឧបករណ៍សំរាប់បំពីការក្លែងបន្លំដូចដែលបញ្ជាក់ក្នុងមាត្រា ១៩ និងមាត្រា ២០ នៃច្បាប់នេះ ។

ឡូតិ៍ផលិតផលទំនិញមន្ទិលសង្ស័យដែលមានចែងក្នុងកថាខ័ណ្ឌ ក វាក្យខ័ណ្ឌ ២ ខាងលើ គឺសំដៅលើឡូតិ៍ផលិតផលទំនិញណាដែលក្រោយពីការពិនិត្យផ្ទាល់ និងឬបន្ទាប់ពីការយកគំរូដូចមានចែងក្នុងមាត្រា ៣៤ ដល់មាត្រា ៤១ នៃច្បាប់នេះឃើញថាត្រូវទទួលការពិនិត្យបញ្ជាក់បន្ថែម សំដៅអោយដឹងច្បាស់អំពីផលិតផលនោះតើសមស្រប ឬមិនសមស្របនឹងចរិតលក្ខណៈដែលកំណត់ក្នុងច្បាប់ ឬក្នុងល័ក្ខខ័ណ្ឌធម្មតានៃការប្រើប្រាស់ផលិតផលនោះ អាចប៉ះពាល់សុវត្ថិភាពឬសុខភាពរបស់អ្នកប្រើ ។ ប្រសិនបើលទ្ធផលនៃការពិនិត្យបញ្ជាក់បន្ថែមដែលត្រូវធ្វើក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការអតិបរិមាមិនបានបញ្ជាក់នូវការមន្ទិលសង្ស័យលើកទីមួយនោះទេ ការឃាត់ទុកបណ្តោះអាសន្នត្រូវលើកលែងជាបន្ទាន់ ។ ក្នុងករណីចាំបាច់ តាមសំណើរបស់ស្ថាប័នត្រួតពិនិត្យមានតែព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុងទេ ដែលមានសិទ្ធិពន្យាររយៈពេលឃាត់ទុកបណ្តោះអាសន្ននេះបាន ។ ផ្ទុយទៅវិញប្រសិនបើផលិតផលនោះមិនបង្ហាញពីចរិតលក្ខណៈដែលកំណត់ដោយច្បាប់

វិធានការមួយក្នុងចំណោមវិធានការប្រាតិភោគដែលមានចែងក្នុងមាត្រា ៥៤ ដល់មាត្រា ៥៧ នៃច្បាប់នេះ ត្រូវតែយកមកអនុវត្ត ។

ក្នុងករណី ក ខ និង គ ខាងលើ ការឃាត់ទុកបណ្តោះអាសន្នមិនអាចហួសរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃឡើយ ហើយត្រូវតែមានភ្ជាប់ជាមួយវិធានការមួយ នៃបណ្តាវិធានការដែលមានចែងក្នុងមាត្រា ៥៤ ដល់មាត្រា ៥៧ នៃច្បាប់នេះ ។

ពេលណាឃាត់ទុកបណ្តោះអាសន្នត្រូវបានបញ្ជាឡើងតាមគំនិតផ្តួចផ្តើមនៃភ្នាក់ងារត្រួតពិនិត្យ ដោយអនុលោមតាមកថាខ័ណ្ឌ ក ខ និង គ ខាងលើ អ្នកកាន់កាប់ផលិតផលទំនិញមានរយៈពេល ៣ (បី)ថ្ងៃនៃថ្ងៃធ្វើការប្តឹងតវ៉ានឹងវិធានការនេះទៅប្រធានស្ថាប័នរបស់ភ្នាក់ងារត្រួតពិនិត្យ ។ ប្រធានស្ថាប័នត្រូវធ្វើសេចក្តីសំរេចដាច់ណាត់ចុងក្រោយក្នុងរយៈពេល ៣ (បី)ថ្ងៃនៃថ្ងៃធ្វើការ ។ បណ្តឹងតវ៉ាពុំមានអនុភាពបញ្ឈប់វិធានការឃាត់ទុកបណ្តោះអាសន្នឡើយ ។

ក្នុងគ្រប់ករណីទាំងអស់ ផលិតផលទំនិញដែលត្រូវបានឃាត់ទុកបណ្តោះអាសន្ន ត្រូវដាក់អោយស្ថិតក្នុងបន្ទុកថែរក្សារបស់អ្នកកាន់កាប់ផលិតផលទំនិញទាំងនោះ ។

**មាត្រា ៥៤.-**

ការចាត់ចែងអោយមានលក្ខណៈសមស្រប ជាវិធានការតម្រូវអោយអ្នកកាន់កាប់ ឬម្ចាស់ផលិតផល ទំនិញឬសេវា ដើម្បីបញ្ចប់នូវមូលហេតុដែលបង្កអោយមានលក្ខណៈពុំសមស្រប ។

ការបញ្ចប់នូវមូលហេតុដែលបង្កអោយមានលក្ខណៈពុំសមស្របនេះរួមមានទាំងកិច្ចដំណើការអោយមានការប្រែប្រួលផលិតផល ទំនិញឬសេវានោះ ជាពិសេសការប្តូរលេខចំណាត់ថ្នាក់ផលិតផលទំនិញ ប្រសិនបើមានចំណាត់ថ្នាក់ច្រើន ហើយបើសិនជាឃើញថា ផលិតផលនោះអាចចាត់ថ្នាក់មកក្នុងប្រភេទផ្សេងដែលចំណាត់ថ្នាក់នោះ ផលិតផលទំនិញនឹងអាចយកលក់ដូរស្របច្បាប់បាន ។

**មាត្រា ៥៥.-**

ការប្តូរទិសដៅផលិតផលទំនិញមានន័យថា :

ក- ការបញ្ជូននូវផលិតផលដែលត្រូវបានឃាត់ទុកបណ្តោះអាសន្ន ឬរឹបអូស ដោយអនុលោមទៅតាមមាត្រា ៥៣និងមាត្រា ៥៦នៃច្បាប់នេះ ទៅសហគ្រាសដែលនឹងអាចប្រើប្រាស់ផលិតផលនោះជាលក្ខណៈផ្ទាល់ឬធ្វើការកែច្នៃអោយបានសមស្របតាមច្បាប់វិញ ក្រោមបន្ទុកចំណាយរបស់ម្ចាស់ផលិតផលទំនិញ

ខ- ការបញ្ជូនផលិតផលដដែលត្រលប់មកសហគ្រាសដែលទទួលខុសត្រូវធ្វើការវេចខ្ចប់ ធ្វើការផលិត ឬនីហរណកម្មនៃផលិតផលទំនិញទាំងនោះជាបន្ទុកចំណាយរបស់ម្ចាស់ផលិតផលទំនិញ ។

**មាត្រា ៥៦.-**

ការរឹបអូសផលិតផលទំនិញ គឺជាការដកហូតយកជាស្ថាពរនូវសិទ្ធិជាម្ចាស់កម្មសិទ្ធិ ហើយអនុវត្តតែក្នុងករណីដូចតទៅ :

ក-ចំពោះផលិតផលទំនិញដែលត្រូវបានទទួលស្គាល់ថាពុំសមស្របទៅនឹងច្បាប់និងបទប្បញ្ញត្តិសំរាប់អនុវត្តច្បាប់នេះ តាមការពិនិត្យឃើញដោយផ្ទាល់ និងឬបន្ទាប់ពីការយកគំរូ ដូចមានចែងក្នុងមាត្រា៣៨ដល់ មាត្រា៤០នៃច្បាប់នេះ ។

ខ-ក្នុងករណីដែលអ្នកកាន់កាប់ ឬម្ចាស់ផលិតផលមិនព្រមធ្វើអោយមានលក្ខណៈសមស្រប ឬប្តូរទិសដៅឬវិធានការទាំងនោះពុំអាចអនុវត្តបានចំពោះផលិតផលទំនិញនោះ

គ-ចំពោះឧបករណ៍សំរាប់ធ្វើការក្លែងបន្លំដូចមានចែងក្នុងមាត្រា ១៩ និងមាត្រា ២០ នៃច្បាប់នេះ

ឃ-ចំពោះផលិតផលទំនិញដែលក្នុងការប្រើប្រាស់ធម្មតាអាចផ្តល់នូវគ្រោះថ្នាក់ចំពោះសុខភាពឬសុវត្ថិភាពរបស់អ្នកប្រើ ។

ផលិតផលទំនិញរឹបអូសត្រូវបិទហើយបោះត្រា និងដាក់អោយរក្សាទុកដោយ

អ្នកកាន់កាប់ ឬបើមានការប្រកែកពុំព្រម ភ្នាក់ងារត្រួតពិនិត្យត្រូវកំណត់អោយរក្សាទុកនៅកន្លែងដែលខ្លួនជ្រើសរើស ។

**មាត្រា ៥៧.-**

ភ្នាក់ងារត្រួតពិនិត្យអាចធ្វើ ឬអោយគេធ្វើក្រោមការត្រួតពិនិត្យរបស់ខ្លួននូវការកំទេច ឬបំប្លែងភាពដើមនៃផលិតផលវិបអូស ពេលណាដែលផលិតផលនោះពុំអាចប្រើប្រាស់ស្របច្បាប់ និងប្រកបដោយផលប្រយោជន៍សេដ្ឋកិច្ចណាមួយបាន ។

**មាត្រា ៥៨.-**

បណ្តាវិធានការចែងក្នុងមាត្រា ៥៣ ដល់មាត្រា ៥៧ នៃច្បាប់នេះ អាចទាក់ទងតែនឹងផលិតផលទំនិញដែលកាន់កាប់ដោយពុំមានហេតុផលសមស្របនៅទីតាំងមួយនៃបណ្តាទីតាំងដែលបានរៀបរាប់ក្នុងមាត្រា ២៩ នៃច្បាប់នេះ ឬពេលណាដែលផលិតផលទំនិញត្រូវដាក់លក់ បានលក់ហើយ ឬបានចែកចាយដោយឥតគិតថ្លៃ ។

កំណត់ហេតុមួយត្រូវតាក់តែងភ្លាមនៅនឹងកន្លែងដោយភ្នាក់ងារត្រួតពិនិត្យ ។ កំណត់ហេតុត្រូវរៀបរាប់តាមចំណុចដែលមានចែងក្នុងមាត្រា ៣៣ នៃច្បាប់នេះព្រមទាំងមានសំរង់លំអិតនៃបណ្តាវិធានការដែលត្រូវបានជ្រើសរើសយកមកអនុវត្ត ដោយមានការបញ្ជាក់ហេតុផល ។ ច្បាប់ចំលងមួយច្បាប់នៃកំណត់ហេតុ ត្រូវប្រគល់ជូនដល់ដៃអ្នកកាន់កាប់ឬម្ចាស់ផលិតផលទំនិញ ។

**មាត្រា ៥៩.-**

បែបបទដែលទាក់ទងនឹងល័ក្ខខ័ណ្ឌនៃផលិតកម្ម សហគ្គាករណ៍ ពាណិជ្ជកម្ម សេវាកម្ម ព្រមទាំងការត្រួតពិនិត្យលើផលិតផល ទំនិញនិងសេវាទាំងអស់មានជាអាទិ៍ ខាងក្រោមនេះ ត្រូវកំណត់ដោយអនុក្រឹត្យ :

១-ចំពោះផលិតផល ទំនិញនិងសេវា

- និយមន័យ នាមករណ៍ ធាតុផ្សំ លក្ខណៈវិនិច្ឆ័យ ប្រភេទនៃគុណភាព ឬអនាម័យនិងបរិមាណនៃផលិតផលទំនិញ

- ផ្លាកសញ្ញា ទម្រង់នៃការបង្ហាញ ទម្រង់នៃការលក់និងទម្រង់នៃការវេចខ្ចប់នូវផលិតផលទំនិញ ព្រមទាំងសញ្ញាគុណភាពដែលអាចបិទភ្ជាប់លើផលិតផលទាំងនោះ

- ល័ក្ខខ័ណ្ឌនៃការប្រើប្រាស់ពាក្យពេចន៍និងល័ក្ខខ័ណ្ឌនៃការប្រើប្រាស់សិទ្ធនសេចក្តីនៃការឃោសនាពាណិជ្ជកម្ម ក្នុងបំណងចៀសវាងនូវការភ័ន្តច្រឡំ ហើយក្នុងករណីដែលមានការចាំបាច់ ល័ក្ខខ័ណ្ឌនៃការធ្វើការឃោសនាពាណិជ្ជកម្មប្រៀបធៀបរវាងរាល់ផលិតផលទំនិញនិងរវាងរាល់សេវា

- ទំរង់នៃការបង្ហាញនិងអត្ថន័យក្នុងវិក័យប័ត្រ ប័ណ្ណប្រគល់ឯក-សារបច្ចេកទេស ឯកសារពាណិជ្ជកម្ម ឬឯកសារនៃការផ្សាយពាណិជ្ជកម្មផ្សេងទៀត

- ល័ក្ខខ័ណ្ឌនៃការហាមឃាត់លើផលិតផលនិងសេវាទាំងឡាយកាលណាផលិតផល ទំនិញនិងសេវាទាំងនោះបំពេញមិនបាននូវកាតព្វកិច្ចទូទៅខាងសុវត្ថិ-ភាព ដែលកំណត់ក្នុងមាត្រា ៣ នៃច្បាប់នេះ

- បែបបទអនុវត្តនូវការអនុញ្ញាត ឬការប្រកាសជាមុនទាំងឡាយសំរាប់ផលិតកម្ម សំរាប់ពាណិជ្ជកម្មលើផលិតផល ទំនិញនិងសេវា ព្រមទាំងបែបបទនៃការរៀបចំអោយមានកិច្ចស្ម័យត្រួតពិនិត្យជាលក្ខណៈវិជ្ជាជីវៈ

- បណ្តាបញ្ញត្តិទាក់ទងទៅនឹងឧបករណ៍វង្វាស់វង្វាល់ និងការពិនិត្យបញ្ជាក់នៃឧបករណ៍ទាំងនោះ

- ការប្រុងប្រយ័ត្នដែលត្រូវប្រកាន់យក ការកែច្នៃ ការពិនិត្យបញ្ជាក់ការប្រើប្រាស់សម្ភារៈដើម្បីអោយផលិតផល ទំនិញនិងសេវា អាចត្រូវគ្នាជាមួយនឹងកិច្ចការពារបរិស្ថាន ។

២-ចំពោះម្ហូបអាហារ

- ការកែច្នៃស្របតាមច្បាប់ដែលធ្វើនៅលើម្ហូបអាហារ លក្ខណៈវិនិច្ឆ័យនៃភាពសុទ្ធ ដែលម្ហូបអាហារត្រូវធ្វើតាមគ្រឿងផ្សំមចូលក្នុងការផលិតម្ហូបអាហារសម្ភារៈដែលអាចត្រូវដាក់ជាប់ផ្ទាល់ជាមួយនឹងម្ហូបអាហារនិងផលិតផលប្រើប្រាស់ សំរាប់លាងសំអាតសម្ភារៈ

- ចរិតលក្ខណៈខាងអនាម័យ ខាងសុខភាព ឬខាងទ្រទ្រង់រាងកាយ បទដ្ឋានផ្នែកអតិសុខុមជីវសាស្ត្រ ដែលម្ហូបអាហារត្រូវធ្វើតាមវិធានអនាម័យ ត្រូវអនុវត្តទៅលើការដឹកជញ្ជូន និងទៅលើគ្រឹះស្ថានជាទីកន្លែងដែលគេផលិត ធ្វើសហគ្គាករណ៍ ឬធ្វើពាណិជ្ជកម្ម ព្រមទាំងទៅលើនិយោជិកបំពីការងារនៅក្នុងគ្រឹះស្ថាន វិញ្ញាបនប័ត្រ ផ្លាកសញ្ញា ឬត្រាសំគាល់ផ្នែកអនាម័យពាក់ព័ន្ធទៅនឹងម្ហូបអាហារ

- សភាពនៃសុខភាពរបស់អ្នកកាន់លាយជុំម្ហូបអាហារ ប្រសិនបើមានការចាំបាច់ ។

៣ - ចំពោះវិធីត្រួតពិនិត្យ

- ល័ក្ខខ័ណ្ឌអនុវត្តនៃបទប្បញ្ញត្តិទាំងឡាយក្នុងមាត្រា ៩ ដល់មាត្រា ១២ នៃច្បាប់នេះ ព្រមទាំងវិធីយកគំរូនិងវិធីធ្វើការវិភាគសំរាប់បង្ហាញនូវធាតុផ្សំលើផលិតផលទំនិញ នូវចរិតលក្ខណៈអតិសុខុមជីវសាស្ត្រ អនាម័យ ឬសុខភាព និងសំរាប់សំគាល់ការក្លែងបន្លំផលិតផលទំនិញ ឬសំរាប់បង្ហាញនូវសមត្ថភាព ចំពោះការប្រើប្រាស់នៃផលិតផលទំនិញ

- បើមានការចាំបាច់បែបបទអនុវត្ត បណ្តាវិធានការប្រាតិភោគដែលបានកំណត់ក្នុងមាត្រា ៥២ ដល់មាត្រា ៥៨ នៃច្បាប់នេះ

- សៀវភៅ បញ្ជី និងឯកសារទាំងឡាយដែលការកាន់កាប់ ឬការតាក់តែងដោយបុគ្គល ដែលចូលរួមធ្វើសកម្មភាពក្នុងផលិតកម្ម សហគ្គាករណ៍ ឬពាណិជ្ជកម្មលើផលិតផល ទំនិញនិងសេវាអាចត្រូវកំណត់ជាកំហិត ។

## មាត្រា ៦០.-

បទដ្ឋានជាតិ បទដ្ឋានអន្តរជាតិ ក្បួនខ្នាតនៃការប្រើប្រាស់ និងសេចក្តីណែនាំប្រតិបត្តិក្នុងការផលិតដែលមានការទាក់ទងដល់ផលិតផល ទំនិញនិងសេវា ត្រូវកំណត់ដោយអនុក្រឹត្យនិងបទដ្ឋាននានា ។

# ជំពូកទី ៧
## ទោសប្បញ្ញត្តិ

**មាត្រា ៦១.-**

ជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ១៤ វាក្យខ័ណ្ឌទី ២ និងវាក្យខ័ណ្ឌទី ៣ នៃច្បាប់នេះត្រូវពិន័យជាប្រាក់ពី ៥០០.០០០ (ប្រាំសែន)រៀល ដល់ ១.០០០.០០០ (មួយលាន)រៀល ។

**មាត្រា ៦២.-**

ជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៧ មាត្រា ៨ មាត្រា ១៩ ឬមាត្រា ២០ នៃច្បាប់នេះ ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ)ថ្ងៃ ដល់ ១(មួយ)ខែ និងពិន័យជាប្រាក់ពី ១.០០០.០០០(មួយលាន)រៀល ដល់ ៥.០០០.០០០(ប្រាំលាន)រៀល ឬទោសណាមួយនៃទោសទាំងពីរនេះ ។

**មាត្រា ៦៣.-**

ជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ១៦ មាត្រា ១៧ មាត្រា ១៨ ឬមាត្រា ២១ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ខែ ដល់ ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី ៥.០០០.០០០(ប្រាំលាន)រៀល ដល់ ១០.០០០.០០០(ដប់លាន)រៀល ឬទោសណាមួយនៃទោសទាំងពីរនេះ ។

**មាត្រា ៦៤.-**

ក្នុងករណីមិនរាងចាលចំពោះបទល្មើសនឹងមាត្រា ១៦ មាត្រា ១៧ មាត្រា ១៨ មាត្រា ១៩ មាត្រា ២០ ឬ មាត្រា ២១ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសទ្វេឡើង ទាំងការផ្តន្ទាទោសពិន័យជាប្រាក់ ទាំងការផ្តន្ទាទោសដាក់ពន្ធនាគារដោយពុំទាន់គិតបញ្ចូលនូវទោសព្រហ្មទណ្ឌធ្ងន់ធ្ងរ ចំពោះបច្ច័យនៃបទល្មើសដែលបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាព សុវត្ថិភាព ឬដល់អាយុជីវិតរបស់អ្នកប្រើ ។

**មាត្រា ៦៥.-**

ផលិតផលទំនិញនិងសម្ភារៈទាំងអស់ដែលជាកម្មវត្ថុនៃការបង្កឱ្យមានបទល្មើសនឹងមាត្រា ១៦ មាត្រា ១៧ មាត្រា ១៨ មាត្រា ១៩ មាត្រា ២០ ឬមាត្រា ២១ នៃច្បាប់នេះ ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។ ការរឹបអូសជាសមត្ថកិច្ចតុលាការ ។

ការខូចខាតផ្សេងទៀតដែលបណ្តាលមកពីបទល្មើសនឹងមាត្រា ១៦ មាត្រា ១៧ មាត្រា ១៨ មាត្រា ១៩ មាត្រា ២០ ឬមាត្រា ២១ នៃច្បាប់នេះ ជនល្មើសត្រូវទទួលខុសត្រូវខាងនីតិរដ្ឋប្បវេណីទៀតផង ។

**មាត្រា ៦៦.-**

ទោសប្បញ្ញត្តិដែលចែងក្នុងមាត្រា ៦៣ ខាងលើ ត្រូវអនុវត្តទៅលើបុគ្គលណាដែលបាន :

ក-ធ្វើអោយភ្នាក់ងារត្រួតពិនិត្យ ដែលមានចែងក្នុងមាត្រា ២៧ នៃច្បាប់នេះ ពុំអាចបំពេញភារកិច្ចបានទោះបីក្នុងរូបភាពណាក៏ដោយ

ខ-ប្រកែកពុំព្រមបង្ហាញឬបិទបាំងឯកសារគណនេយ្យបច្ចេកទេស ឬពាណិជ្ជកម្មដែលខ្លួនមានដូចមានចែងក្នុងវាក្យខ័ណ្ឌ ១ មាត្រា ៣០ នៃច្បាប់នេះ

គ-ប្រកែកពុំព្រមបង្ហាញអត្ថបទផ្សាយពាណិជ្ជកម្ម ឬពត៌មានសំរាប់បញ្ជាក់ហេតុផលនៃការផ្សាយពាណិជ្ជកម្ម

ឃ-មានចេតនាផ្តល់ពត៌មានមិនពិតឬដោយពង្វាងការពិត ឬដោយធ្វើអោយមានការភ័ន្តច្រឡំ ទោះតាមវិធីណាក៏ដោយដើម្បីជាកិច្ចឆ្លើយតបនឹងសំណើរបស់ភ្នាក់ងារដែលមានចែងក្នុងមាត្រា ២៧ នៃច្បាប់នេះ

ង-ចាត់ចែងដោយគ្មានការអនុញ្ញាតនូវទំនិញដែលត្រូវបានភ្នាក់ងារមានសមត្ថកិច្ចឃាត់ទុកជាបណ្តោះអាសន្ន ឬរឹបអូស

ច-មិនផ្តល់ទំនិញដែលជាគោលដៅនៃការឃាត់ទុកជាបណ្តោះអាសន្ន ឬនៃការរឹបអូសដល់ភ្នាក់ងារមានសមត្ថកិច្ចក៏ដូចជាមិនបានចាត់ចែងទំនិញឱ្យបានសម្រេចតាមទិសដៅកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ឬក៏មិនបានកែប្រែឱ្យបានសមស្របតាមការ

កំណត់នៃច្បាប់ទូវទំនិញដែលមានលក្ខណៈពុំសមស្រប ដូចមានចែងក្នុងមាត្រា ៥៣ ដល់ មាត្រា ៥៦ នៃច្បាប់នេះ ។

**មាត្រា ៦៧.-**

ភ្នាក់ងារត្រួតពិនិត្យដែលមានចែងក្នុងមាត្រា ២៧ នៃច្បាប់នេះត្រូវទទួលខុសត្រូវចំពោះនីតិរដ្ឋបាល ។

ភ្នាក់ងារត្រួតពិនិត្យត្រូវទទួលខុសត្រូវចំពោះការធ្វេសប្រហែសហើយបណ្ដាលឱ្យមានការថ្មោះធ្មោយ និងបច្ច័យផ្សេងៗដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ក៏ដូចជាផ្ទុយនឹងបទប្បញ្ញត្តិទាំងឡាយនៃលិខិតបទដ្ឋាននានាក្រោមច្បាប់នេះ ។

**មាត្រា ៦៨.-**

ទណ្ឌកម្មរដ្ឋបាលដែលត្រូវយកមកអនុវត្តចំពោះភ្នាក់ងារឬមន្ត្រីមានសមត្ថកិច្ចដែលមានកំណត់ក្នុងច្បាប់នេះរួមមាន :

ក-ទណ្ឌកម្មរដ្ឋបាលកំរិតដំបូងគឺការព្រមាន ឬការស្ដីបន្ទោសពីប្រធានស្ថាប័ន

ខ-ទណ្ឌកម្មរដ្ឋបាលកំរិតមធ្យមគឺការបញ្ឈប់ផ្ដល់ប្រាក់បៀវត្សនិងអត្ថប្រយោជន៍ផ្សេងៗទៀត ក្នុងរយៈពេលចាប់ពី ៦(ប្រាំមួយ)ខែឡើងទៅ

គ-ទណ្ឌកម្មរដ្ឋបាលកំរិតធ្ងន់គឺការដកហូតតួនាទី ឬពីមុខតំណែង ឬការបញ្ឈប់ពីការងារតែម្ដង ។

ទណ្ឌកម្មរដ្ឋបាលដែលមានចែងខាងលើនេះ នៅពុំទាន់គិតដល់អំពើល្មើសព្រហ្មទណ្ឌផ្សេងៗទៀត ។

**មាត្រា ៦៩.-**

ភ្នាក់ងារត្រួតពិនិត្យឬមន្ត្រីមានសមត្ថកិច្ចដែលឃុបឃិត ឬប្រព្រឹត្តរំលោភលើភារកិច្ចរបស់ខ្លួនក្នុងការអនុវត្តមាត្រា ១៤ ត្រូវទទួលទណ្ឌកម្មខាងរដ្ឋបាលនិងត្រូវពិន័យជាប្រាក់ដូចមានចែងក្នុងមាត្រា ៦១ នៃច្បាប់នេះ ។

ភ្នាក់ងារត្រួតពិនិត្យ ឬមន្ត្រីមានសមត្ថកិច្ចដែលបានឃុបឃិត ឬប្រព្រឹត្តិរំលោភលើភារកិច្ចរបស់ខ្លួនក្នុងការអនុវត្តមាត្រា ៧ មាត្រា ៨ មាត្រា ១៩ ឬមាត្រា ២០ នៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មរដ្ឋបាលកំរិតធ្ងន់ ព្រមទាំងទោសទាំងឡាយដែលបានចែងក្នុងមាត្រា ៦២ នៃច្បាប់នេះ ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ។

**មាត្រា ៧០.-**

ភ្នាក់ងារឬមន្ត្រីមានសមត្ថកិច្ចដែលបានឃុតឃិត ឬប្រព្រឹត្តិរំលោភលើភារកិច្ចរបស់ខ្លួនក្នុងការអនុវត្តមាត្រា ១៦ មាត្រា ១៧ មាត្រា ១៨ ឬមាត្រា ២១ នៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មរដ្ឋបាលកំរិតធ្ងន់ ព្រមទាំងទោសទាំងឡាយដែលមានចែងក្នុងមាត្រា ៦៣ នៃច្បាប់នេះ ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ។

**មាត្រា ៧១.-**

ត្រូវបានដកហូតលិខិតអនុញ្ញាតចេញដោយអាជ្ញាធរមានសមត្ថកិច្ច ចំពោះផលិតកម្មនិងពាណិជ្ជកម្មដូចមានចែងក្នុងមាត្រា ៦ ដែលពុំបានគោរពតាមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ។

**មាត្រា ៧២.-**

អ្នកឯកទេសទាំងក្នុងក្របខ័ណ្ឌនៃមន្ទីរពិសោធន៍រដ្ឋ ទាំងឯកជនដែលទទួលយកការវិភាគផលិតផលទំនិញគីរូដូចមានចែងក្នុងមាត្រា ៤២ ដល់មាត្រា ៥០ នៃច្បាប់នេះ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់នូវព្រឹត្តប័ត្រវិភាគរបស់ខ្លួនផ្ទាល់ ។

អ្នកឯកទេសវិភាគណាដែលបានឃុបឃិត ឬប្រព្រឹត្តិរំលោភលើភារកិច្ចរបស់ខ្លួនក្នុងការអនុវត្ត ត្រូវទទួលទោសដូចមានចែងក្នុងមាត្រា ៦១ មាត្រា ៦២ មាត្រា ៦៣ និងមាត្រា ៦៤ នៃច្បាប់នេះ ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ។

# ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៧៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧៤.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ច្បាប់នេះ ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០០ នាសម័យ
ប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ២ ។

ភ្នំពេញ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០០

ប្រធានរដ្ឋសភា

នរោត្តម រណឫទ្ធិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

## ស្តីពី

# ការគ្រប់គ្រងឱសថ

# ច្បាប់

ស្តីពី

# ការគ្រប់គ្រងឱសថ

# ព្រះរាជក្រម

នស / រកម / ០៦៩៦ / ០២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * * * * * * * *

ទទួលទាន
លេខ...១៤៨៣...
ថ្ងៃទី២៤...៦...៩៦ ម៉ោង...១០...
បញ្ជូនទៅ...[illegible]...

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស-៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៩៤ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស-រកម-០១៩៦-០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល

## ប្រកាសអោយប្រើ

ច្បាប់ស្តីពីការគ្រប់គ្រងឱសថ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៩៦ នាសម័យប្រជុំ លើកទី៦ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ជំពូកទី ១

## បទបញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះមានគោលដៅគ្រប់គ្រងឱសថក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២.-

ឱសថគឺជាសារធាតុមួយមុខ ឬច្រើនមុខដែលមានប្រភេទជាអាទិ៍ពី ជាតិគីមី ជីវផលិតផល ជាតិអតិសុខុមប្រាណ រុក្ខជាតិ លាយផ្សំឡើងសម្រាប់ :

- ប្រើប្រាស់ក្នុងការបង្ការឬព្យាបាលជម្ងឺមនុស្ស សត្វ
- ការស្រាវជ្រាវវេជ្ជសាស្ត្រ ឱសថសាស្ត្រ ឬធ្វើរោគវិនិច្ឆ័យ
- កែប្រែឬទ្រទ្រង់មុខងារនៃសរីរាង្គ ។

មាត្រា ៣.-

ត្រូវបានចាត់ទុកជាឱសថដែរ :

១-សេរ៉ូម ឬវ៉ាក់សាំង

២-ឈាម ឬផលិតផលដែលបានមកពីឈាម

៣-ឱសថបុរាណ

៤-ផលិតផលដែលផ្សំឡើងដោយមានជាតិពុល ដែលមានក្នុងបញ្ជីកំណត់ដោយអនុក្រឹត្យ។

មាត្រា ៤.-

អាចមានសិទ្ធិធ្វើផលិតកម្ម អាហរណនីហរណកម្ម និងពាណិជ្ជកម្មឱសថបាន ចំពោះឱសថការីដែលមានលក្ខណៈសម្បត្តិដូចខាងក្រោមនេះ :

- មានសញ្ជាតិខ្មែរ
- មានសញ្ញាប័ត្រជាឱសថការីទទួលស្គាល់ដោយក្រសួងសុខាភិបាល
- មិនដែលមានទោសបទល្មើសព្រហ្មទណ្ឌណាមួយ
- មានសុខភាពគ្រប់គ្រាន់អាចបំពេញការងារបាន ។

ចំពោះការផលិត អាហរណនីហរណកម្ម និងពាណិជ្ជកម្មឱសថបុរាណ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ២
## ការគ្រប់គ្រងជាតិពុលសម្រាប់វិស័យសុខាភិបាល

**មាត្រា ៥.-**

ជាតិពុលសំដៅលើឱសថ ឬសារជាតិ ឬសមាសធាតុនៃសារជាតិ ឬរុក្ខជាតិ ដែលអាចបង្កឱ្យគ្រោះថ្នាក់ដល់សុខភាព ឬឱ្យញៀនដល់មនុស្ស សត្វ ។

ជាតិពុលនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៦.-**

បែបបទនិងលក្ខខ័ណ្ឌក្នុងផលិតកម្ម អាហរ័ណ នីហរ័ណកម្ម និងពាណិជ្ជកម្មជាតិពុល ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៣
## ផលិតកម្ម អាហរ័ណ នីហរ័ណកម្ម និងពាណិជ្ជកម្មឱសថ

**មាត្រា ៧.-**

បែបបទនិងលក្ខខ័ណ្ឌបច្ចេកទេសផលិតកម្មនិងការប្រព្រឹត្តិទៅនៃគ្រឹះស្ថានផលិតឱសថ ត្រូវកំណត់ដោយអនុក្រឹត្យ ។

ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសុខាភិបាលនូវ :

-បែបបទនិងលក្ខខ័ណ្ឌក្នុងការសុំបើក ឬបិទ ឬប្តូរទីតាំងនៃគ្រឹះស្ថានលក់ឱសថ គ្រឹះស្ថានផលិតឱសថ និងគ្រឹះស្ថានអាហរ័ណនីហរ័ណឱសថ

-បែបបទនិងលក្ខខ័ណ្ឌក្នុងការសុំទិដ្ឋាការ បញ្ជីការឱសថ

-បែបបទនិងលក្ខខ័ណ្ឌបច្ចេកទេសគ្រប់គ្រងនិងថែរក្សាឱសថ

-បែបបទនិងលក្ខខ័ណ្ឌក្នុងការផ្សព្វផ្សាយឱសថ

-ព្រមទាំងបែបបទផលិតកម្ម អាហរ័ណ នីហរ័ណកម្ម និងពាណិជ្ជកម្មឱសថ ។

ការកំណត់ចំនួនគ្រឹះស្ថានលក់ឱសថត្រូវធ្វើឡើងដោយក្រសួងសុខាភិបាលដោយផ្អែកលើចំនួនប្រជាពលរដ្ឋក្នុងសង្កាត់ ឃុំ ជាមូលដ្ឋាន ។

មាត្រា ៨.-

១-ត្រូវមានការអនុញ្ញាតពីក្រសួងសុខាភិបាលចំពោះ :

-ការបើក បិទ ឬប្តូរទីតាំងនៃគ្រឹះស្ថានលក់ឱសថ គ្រឹះស្ថានអាហរ័ណ នីហរ័ណឱសថ និងគ្រឹះស្ថានផលិតឱសថ

-ការធ្វើអាជីវកម្ម អាហរ័ណ នីហរ័ណកម្មឱសថ

-ការនាំចូល នាំចេញ ស្តុកឱសថ និងវត្ថុធាតុដើមសម្រាប់ផលិតឱសថ

-ការផ្សព្វផ្សាយឱសថ ។

២-ផលិតកម្ម អាហរ័ណ នីហរ័ណកម្មនិងពាណិជ្ជកម្មឱសថសម្រាប់ផ្នែកបសុពេទ្យ ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងសុខាភិបាល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

៣-ក្នុងគ្រឹះស្ថានលក់ឱសថ ត្រូវមានវត្តមានរបស់ឱសថការី ។ ក្នុងករណីអវត្តមាន ត្រូវមានអ្នកជំនួស ដែលមានលក្ខណៈសម្បត្តិសមស្របកំណត់ដោយក្រសួងសុខាភិបាល ។

## ជំពូកទី ៤

## សមត្ថកិច្ចក្នុងការគ្រប់គ្រង

មាត្រា ៩.-

ការណែនាំ និងការត្រួតពិនិត្យដែលពាក់ព័ន្ធនឹងសកម្មភាពឱសថ ជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល ។

ចំពោះការណែនាំ និងការត្រួតពិនិត្យប្រភេទឱសថសម្រាប់ផ្នែកបសុព្យាបាល ជាសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

# ជំពូកទី ៥

## ទោសបញ្ញត្តិ

**មាត្រា ១០.-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០រៀល ( មួយលានរៀល ) ដល់ ១០.០០០.០០០រៀល ( ដប់លានរៀល ) និងផ្អាកផលិតកម្ម អាហរណនីហរណកម្ម និងពាណិជ្ជកម្មឱសថពី ០១ខែ ដល់ ០៣ខែ ឬទោសណាមួយក្នុងចំណោមទោសទាំងពីរខាងលើ ដោយពុំទាន់គិតដល់ការផ្តន្ទាទោសពីបទល្មើសផ្សេងៗទៀតចំពោះបុគ្គលណាដែលបាន :

១-ផ្សព្វផ្សាយឱសថដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

២-ប្រព្រឹត្តល្មើសនឹងបែបបទ ឬល័ក្ខខ័ណ្ឌ ផលិតកម្ម អាហរណនីហរណកម្ម និងពាណិជ្ជកម្មឱសថ ។

៣-បើក ឬប្តូរទីតាំង គ្រឹះស្ថានលក់ឱសថ គ្រឹះស្ថានផលិតឱសថ ឬធ្វើអាជីវកម្មអាហរណនីហរណកម្មឱសថ ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

៤-ផលិត ឬនាំចូល ឬនាំចេញ ឬស្តុកឱសថ វត្ថុធាតុដើមឱសថ ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

៥-លក់ឱសថគ្មានទិដ្ឋាការ ឬបញ្ជីការ ឬឱសថដែលក្រសួងសុខាភិបាលបានហាមឃាត់ ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ និងផ្អាកផលិតកម្ម អាហរណនីហរណកម្ម និងពាណិជ្ជកម្មឱសថទ្វេឡើងមួយជាពីរ ឬទោសណាមួយក្នុងចំណោមទោសទាំងពីរខាងលើ ។

ឱសថ វត្ថុធាតុដើម សម្ភារៈ ឧបករណ៍ផ្សេងៗដែលទាក់ទងនឹងបទល្មើសដែលមានចែងក្នុងចំណុច ៤និង៥ ត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ឬបំផ្លាញចោល ។

ក្រសួងសុខាភិបាលមានសិទ្ធិផ្អាកជាបណ្តោះអាសន្នភ្លាមនូវ ការផ្សព្វផ្សាយឱសថ ផលិតកម្ម អាហរណនីហរណកម្ម និងពាណិជ្ជកម្មឱសថដែលល្មើស រួចរៀបចំសំណុំរឿងបញ្ជូនទៅតុលាការ ។

មាត្រា ១១.-

ត្រូវផ្តន្ទាទោស ពិន័យជាប្រាក់ពី ១.០០០.០០០រៀល ( មួយលានរៀល ) ដល់ ៥.០០០.០០០រៀល ( ប្រាំលានរៀល ) ឬផ្តន្ទាទោសដាក់ពន្ធនាគារពី ០៦ថ្ងៃ ដល់ ០១ខែ ឬទោសទាំងពីរនេះ ចំពោះជនណាដែលរារាំងមិនឱ្យភ្នាក់ងារមានសមត្ថកិច្ចដែលមានចែងក្នុងមាត្រាខាងលើបំពេញភារកិច្ចអធិការកិច្ចរបស់ខ្លួន ។

មាត្រា ១២.-

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០រៀល ( ម្ភៃលានរៀល ) ដល់ ៥០.០០០.០០០រៀល ( ហាសិបលានរៀល ) ឬផ្តន្ទាទោសដាក់ពន្ធនាគារពី ០៥ឆ្នាំ ដល់ ១០ឆ្នាំ ឬទោសទាំងពីរនេះ ចំពោះជនណាដែលបានធ្វើផលិតកម្ម អាហរណនីហរណកម្ម និងពាណិជ្ជកម្ម ដោយចេតនានូវឱសថមានសារធាតុញៀនដោយគ្មានការអនុញ្ញាត ឱសថក្លែងក្លាយ ឱសថគ្មានគុណភាព ឱសថហួសរយៈពេលប្រើ ដែលប៉ះពាល់ដល់សុខភាព អាយុជីវិតរបស់អ្នកប្រើប្រាស់ ។

មាត្រា ១៣.-

ត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ១០,១១ និង ១២ ដែរ ចំពោះមន្ត្រីរាជការណា ដែលឃុបឃិត ឬប្រព្រឹត្តរំលោភលើភារកិច្ចរបស់ខ្លួនក្នុងការអនុវត្តមាត្រា ១០,១១ និង ១២ ។

## ជំពូកទី ៦

## អន្តរប្បញ្ញត្តិ

មាត្រា ១៤.-

ក្រោយពេលច្បាប់នេះចូលជាធរមានរហូតដល់ឆ្នាំ ២០០៥ ក្រសួងសុខាភិបាល មានសិទ្ធិចេញប្រកាសអនុញ្ញាតឱ្យមន្ត្រីសុខាភិបាលចូលនិវត្តន៍ដែលមានសមត្ថភាពបើកគ្រឹះស្ថានលក់ឱសថនៅតាមឃុំ សង្កាត់ណាដែលពុំទាន់មានគ្រឹះស្ថានលក់ឱសថត្រឹមត្រូវតាមការកំណត់ក្នុងមាត្រា ៤ និងមាត្រា ៧ នៃច្បាប់នេះ ។

## ជំពូកទី ៧

## អវសានប្បញ្ញត្តិ

**មាត្រា ១៥.-**

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ១៩៩៦
ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា
**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| --- | --- |
| ព្រះហស្តលេខា | ហត្ថលេខា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

បានបង្គំទូលថ្វាយ និង ជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី១ និង ទី២
ជ.រដ្ឋមន្ត្រីក្រសួងសុខាភិបាល
ហត្ថលេខា
**ឌី ណារ៉ុងរិទ្ធិ**

**លេខ : ៨៣ ច ល**

**ដើម្បីចម្លងចែក**
**ភ្នំពេញ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៩៦**
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុន សារី**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

3

ក្រសួងពាណិជ្ជកម្ម

3

## សេចក្តីព្រាង

# ច្បាប់

## ស្តីពី

# កិច្ចសន្យាពាណិជ្ជកម្ម

តុលា ឆ្នាំ ២០០៩

# ជំពូកទី ១១
# កិច្ចសន្យាដឹកជញ្ជូន

## ផ្នែកទី ១
## និយមន័យ និងវិសាលភាពនៃកិច្ចសន្យាដឹកជញ្ជូន

### មាត្រា ១៤៩.- និយមន័យ

កិច្ចសន្យាដឹកជញ្ជូនគឺជាកិច្ចសន្យាដែលពាណិជ្ជករម្នាក់ ហៅថាអ្នកដឹកជញ្ជូន ធ្វើការដឹកជញ្ជូនមនុស្ស (ដែលអាចជាពាណិជ្ជករ ឬមិនមែនជាពាណិជ្ជករ) ឬទំនិញរបស់ពាណិជ្ជករ ឬបុគ្គលមិនមែនជាពាណិជ្ជករពីកន្លែងមួយទៅកន្លែងមួយទៀតតាមមធ្យោបាយដឹកជញ្ជូន និងដោយទទួលការបង់ថ្លៃឈ្នួលពីពាណិជ្ជករម្ខាងទៀត អ្នករៀបចំការធ្វើដំណើរ អន្តរការី អ្នកផ្ញើរ ឬអ្នកទទួលទំនិញ ក្នុងរយៈពេលដែលបានព្រមព្រៀងគ្នា។

បទប្បញ្ញត្តិនៃជំពូកនេះអាចអនុវត្តលើប្រភេទកិច្ចសន្យាពាណិជ្ជកម្មណាមួយដែលទាក់ទងនឹងការដឹកជញ្ជូនទំនិញនិង/ឬអ្នកដំណើរ ទោះបីកិច្ចសន្យានោះមិនមែនជាកិច្ចសន្យាដឹកជញ្ជូនក៏ដោយ។

### មាត្រា ១៥០.- អ្នករៀបចំការធ្វើដំណើរ ឬអន្តរការី

អ្នករៀបចំការធ្វើដំណើរ ឬអន្តរការី គឺពាណិជ្ជករម្នាក់ ដែលអនុវត្តកិច្ចសន្យាមួយដូចដែលបានឱ្យនិយមន័យនៅក្នុងមាត្រា១៤៩ ខាងលើ ក្នុងនាមរបស់ខ្លួន ឬក្នុងនាមនីតិបុគ្គលមួយ ដើម្បីផ្តល់សេវាឱ្យបុគ្គលណាម្នាក់ក្នុងតម្លៃណាមួយដែលផ្សំរួមគ្នានូវសេវាដឹកជញ្ជូននិងសេវានៃការស្នាក់នៅ ដោយការងាររបស់គាត់ដាច់ដោយឡែកពីការដឹកជញ្ជូន ឬសេវាផ្សេងនានាដែលកើតចេញពីការដឹកជញ្ជូន និង/ឬ ការស្នាក់នៅ។

### មាត្រា ១៥១.- ការដឹកជញ្ជូនបន្ត និងផ្សំគ្នា

ការដឹកជញ្ជូនបន្ត ត្រូវបានប្រតិបត្តិដោយអ្នកដឹកជញ្ជូនជាច្រើនតាមការទទួលបន្ត ដោយប្រើប្រាស់មធ្យោបាយនៃការដឹកជញ្ជូនដូចគ្នា។

ការដឹកជញ្ជូនផ្សំគ្នា ត្រូវបានប្រតិបត្តិដោយអ្នកដឹកជញ្ជូនជាច្រើនតាមការទទួលបន្ត ដោយប្រើប្រាស់មធ្យោបាយដឹកជញ្ជូនផ្សេងគ្នា។

**មាត្រា ១៥២.- ការដឹកជញ្ជូនដោយមិនយកកម្រៃ**

នៅពេលដែលពាណិជ្ជករម្នាក់ផ្តល់ការដឹកជញ្ជូនអ្នកដំណើរ ឬទំនិញដោយមិនយកកម្រៃ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃជំពូកនេះ។

**មាត្រា ១៥៣.- កាតព្វកិច្ចរបស់អ្នកដឹកជញ្ជូន**

អ្នកដឹកជញ្ជូនដែលផ្តល់សេវាសាធារណៈក្នុងការដឹកជញ្ជូនអ្នកដំណើរណាម្នាក់ដែលបានស្នើរសុំនិងដឹកទំនិញនានាដែលគេស្នើរសុំឱ្យដឹកជញ្ជូន លើកលែងតែគាត់បដិសេធដោយមូលហេតុសមស្រប ដូចជាការបដិសេធបង់ថ្លៃឈ្នួលដោយអ្នកដំណើរ អ្នកផ្ញើរ ឬអ្នកទទួល ឬលើកលែងតែការដឹកជញ្ជូនអ្នកដំណើរ ឬទំនិញទាំងនោះត្រូវបានហាមឃាត់ដោយច្បាប់។

អ្នកធ្វើដំណើរ អ្នកផ្ញើរ ឬអ្នកទទួល ត្រូវបង់ថ្លៃឈ្នួលលើសេវា និងត្រូវគោរពតាមការណែនាំពីអ្នកដឹកជញ្ជូន ដោយអនុលោមតាមច្បាប់។

**មាត្រា ១៥៤.- ការទទួលខុសត្រូវរបស់អ្នកដឹកជញ្ជូន**

អ្នកដឹកជញ្ជូនមិនអាចបដិសេធ ឬកម្រិតការទទួលខុសត្រូវរបស់ខ្លួនបានឡើយ លើកលែងតែវិសាលភាពនិងកម្មវត្ថុនៃលក្ខខណ្ឌនានាត្រូវបានហាមឃាត់ដោយច្បាប់។

អ្នកដឹកជញ្ជូនត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលបណ្តាលមកពីការយឺតយ៉ាវ លើកលែងតែក្នុងករណីប្រធានសក្តិ ឬមានការព្រមព្រៀងផ្សេងរបស់ភាគីនៅក្នុងកិច្ចសន្យា ។

**មាត្រា ១៥៥.- ការផ្ទេរកិច្ចសន្យាដឹកជញ្ជូន**

នៅពេលដែលអ្នកដឹកជញ្ជូនប្រគល់ការអនុវត្តន៍កាតព្វកិច្ចទាំងស្រុង ឬមួយផ្នែករបស់ខ្លួនទៅឱ្យអ្នកដឹកជញ្ជូនផ្សេងទៀតដែលគាត់ទុកចិត្ត អ្នកដឹកជញ្ជូនជំនួសនោះត្រូវបានចាត់ទុកជាភាគីនៃកិច្ចសន្យា និងចងភ្ជាប់ដោយកាតព្វកិច្ចរបស់អ្នកដឹកជញ្ជូននោះតាមកិច្ចសន្យា។

អ្នកផ្ញើរត្រូវបញ្ចប់កាតព្វកិច្ចដោយការបង់ថ្លៃទៅឱ្យអ្នកដឹកជញ្ជូនណាម្នាក់ក្នុងចំណោមអ្នកដឹកជញ្ជូនទាំងអស់។

**មាត្រា ១៥៦.- សិទ្ធិអាទិភាព**

សិទ្ធិអាទិភាព និងការទទួលយកដោយសុចរិត ដូចដែលបានចែងនៅក្នុងក្រមរដ្ឋប្បវេណីដែលទាក់ទងនឹងការដឹកជញ្ជូនអ្នកដំណើរឬទំនិញត្រូវអនុវត្តចំពោះកិច្ចសន្យាដឹកជញ្ជូនបាន។

**មាត្រា ១៥៧.- ការអនុលោមតាមបទដ្ឋាននានារបស់ក្រសួង និងស្ថាប័នពាក់ព័ន្ធ**

ពាណិជ្ជករដែលប្រកបមុខរបរដឹកជញ្ជូន ត្រូវគោរពច្បាប់និងបទដ្ឋានគតិយុត្តនានាដែលគ្រប់គ្រងលើវិធីសាស្ត្រនៃការដឹកជញ្ជូន។

ពាណិជ្ជករដែលប្រកបមុខរបរដឹកជញ្ជូន ត្រូវគោរពលក្ខខណ្ឌនៃការធានារ៉ាប់រងដែលបានចែងនៅក្នុងច្បាប់និងបទដ្ឋានគតិយុត្តនានាដែលនៅជាធរមាន។

អ្នករៀបចំការធ្វើដំណើរ អន្តរការី អ្នកដឹកជញ្ជូនទំនិញ និង/ឬអ្នកដំណើរ តម្រូវឱ្យប្រតិបត្តិតាមបទដ្ឋាននានារបស់ក្រសួង និងស្ថាប័នពាក់ព័ន្ធដែលត្រូវអនុវត្តចំពោះអាជីវកម្មរបស់ពួកគាត់ នៅមុនពេលដែលពួកគាត់បានចុះកិច្ចសន្យាដឹកជញ្ជូន។

## ផ្នែកទី ២
## ការដឹកជញ្ជូនទំនិញ

**មាត្រា ១៥៨.- និយមន័យ**

ការដឹកជញ្ជូនទំនិញ ត្រូវចាប់ផ្តើមពីអ្នកដឹកជញ្ជូនទទួលទំនិញដែលស្ថិតនៅក្រោមការដឹកជញ្ជូនរបស់គាត់រហូតដល់ការប្រគល់ទំនិញនោះ។

**មាត្រា ១៥៩.- ប័ណ្ណដឹកជញ្ជូន (អញ្ញត្រប័ណ្ណ)**

ភាគីនៃកិច្ចសន្យាដឹកជញ្ជូនទំនិញ ត្រូវមានភស្តុតាងបញ្ជាក់កិច្ចសន្យានោះជាលាយលក្ខណ៍អក្សរ។

ប័ណ្ណដឹកជញ្ជូនដែលធ្វើជាលាយលក្ខណ៍អក្សរ ជាភស្តុតាងនៃកិច្ចសន្យាដឹកជញ្ជូនទំនិញ។

ភាគីនៃកិច្ចសន្យាដឹកជញ្ជូនឬប័ណ្ណដឹកជញ្ជូនដែលមិនសរសេរជាលាយលក្ខណ៍អក្សរ អាចស្នើសុំឱ្យតុលាការពាណិជ្ជកម្មដែលមានយុត្តាធិការកំណត់អំពីអានុភាពគតិយុត្តរបស់វាបាន។

**មាត្រា ១៦០.- ទម្រង់នៃប័ណ្ណដឹកជញ្ជូន**

ប័ណ្ណដឹកជញ្ជូនត្រូវធ្វើឡើងជាច្រើនច្បាប់ អ្នកដឹកជញ្ជូនត្រូវរក្សាទុកមួយច្បាប់ អ្នកផ្ញើររក្សាទុកមួយច្បាប់ និងមួយច្បាប់ទៀតត្រូវភ្ជាប់ជាមួយទំនិញរហូតដល់គោលដៅ។

ក្នុងករណីអវត្តមាននៃភស្តុតាងណាមួយនៃកិច្ចសន្យា ប័ណ្ណដឹកជញ្ជូនត្រូវបញ្ជាក់ភស្តុតាងដោយការទទួលទំនិញ ដោយអ្នកដឹកជញ្ជូនតាមការទទួលខុសត្រូវរបស់គាត់តាមលក្ខណៈធម្មជាតិរបស់ទំនិញ បរិមាណ និងលក្ខខណ្ឌជាក់លាក់។

**មាត្រា ១៦១.- ការប្រគល់ទំនិញ**

អ្នកដឹកជញ្ជូនត្រូវប្រគល់ទំនិញទៅឱ្យអ្នកទទួល ឬអ្នកកាន់កាប់ប័ណ្ណដឹកជញ្ជូន។

អ្នកកាន់កាប់ប័ណ្ណដឹកជញ្ជូនត្រូវប្រគល់វាទៅឱ្យអ្នកដឹកជញ្ជូន នៅពេលដែលអ្នកដឹកជញ្ជូនប្រគល់ទំនិញ។

**មាត្រា ១៦២.- សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកទទួល**

អ្នកទទួលទំនិញដោយផ្អែកតាមការព្រមព្រៀងឬកិច្ចសន្យា ត្រូវអនុវត្តសិទ្ធិ និងកាតព្វកិច្ចដែលបានចែង និងកំណត់នៅក្នុងកិច្ចសន្យា។

**មាត្រា ១៦៣.- កាតព្វកិច្ចរបស់អ្នកដឹកជញ្ជូនក្នុងការជូនដំណឹង**

អ្នកដឹកជញ្ជូនមានកាតព្វកិច្ចជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកទទួលទំនិញអំពីការទៅដល់នៃទំនិញ និងពេលវេលានៃការប្រគល់ទំនិញ លើកលែងតែការប្រគល់ទំនិញនៅលំនៅឋាន ឬទីកន្លែងពាណិជ្ជកម្មរបស់អ្នកទទួល។

**មាត្រា ១៦៤.- ការរកមិនឃើញអ្នកទទួល ឬការបដិសេធដោយអ្នកទទួល**

នៅពេលដែលមិនអាចរកឃើញអ្នកទទួល ឬមានការបដិសេធ ឬធ្វេសប្រហែសក្នុងការទទួលទំនិញពីអ្នកទទួលឬដោយហេតុផលផ្សេងៗដែលបណ្តាលឱ្យអ្នកដឹកជញ្ជូនទំនិញមិនអាចប្រគល់ទំនិញដោយសារករណីប្រធានសក្តិ អ្នកដឹកទំនិញត្រូវជូនដំណឹងទៅឱ្យអ្នកផ្ញើរទំនិញភ្លាម និងស្នើរសុំសេចក្តីណែនាំក្នុងការយកទំនិញទៅរក្សាទុក។ ប៉ុន្តែក្នុងករណីអាសន្ន ឬប្រធានសក្តិ អ្នកដឹកជញ្ជូនអាចបោះចោលទំនិញដែលខូចស្អុយរលួយដោយមិនបាច់ជូនដំណឹងទៅឱ្យអ្នកផ្ញើរទំនិញ។

បើសិន អ្នកដឹកជញ្ជូនទំនិញ មិនបានទទួលសេចក្តីណែនាំក្នុងរយៈពេល ១៥ (ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីថ្ងៃជូនដំណឹង គាត់អាចប្រគល់ទំនិញត្រលប់ទៅឱ្យអ្នកផ្ញើរវិញ។

**មាត្រា ១៦៥.- ការទទួលកម្រៃនៃការការពារ និងការរក្សាទំនិញរបស់អ្នកដឹកជញ្ជូន**

ចាប់ពីផុតរយៈពេលនៃការអនុញ្ញាតឱ្យយកទំនិញចេញ ឬចាប់ពីការជូនដំណឹងទៅឱ្យអ្នកផ្ញើរ កាតព្វកិច្ចរបស់អ្នកដឹកជញ្ជូនគឺត្រូវថែរក្សាទំនិញដោយប្រុងប្រយ័ត្នឱ្យដូចកិច្ចសន្យាបញ្ញើដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី។

អ្នកដឹកជញ្ជូនមានសិទ្ធិយកកម្រៃសមរម្យសម្រាប់ការការពារនិងការរក្សាទំនិញឱ្យល្អពីអ្នកទទួល ឬពីអ្នកផ្ញើរក្នុងករណីអ្នកទទួលមិនបានបង់កម្រៃ។

**មាត្រា ១៦៦.- កាតព្វកិច្ចរបស់អ្នកដឹកជញ្ជូន**

អ្នកដឹកជញ្ជូនមានកាតព្វកិច្ចក្នុងការដឹកជញ្ជូនទំនិញទៅដល់គោលដៅ។

អ្នកដឹកជញ្ជូនត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលបណ្តាលមកពីការដឹកជញ្ជូន លើកលែងតែអ្នកដឹកជញ្ជូនមានភស្តុតាងបញ្ជាក់ថាការខូចខាតនោះបណ្តាលមកពីករណីប្រធានសក្តិ ទំនិញខូចស្រាប់ ឬការប្រែប្រួលពីធម្មជាតិរបស់ទំនិញ។

**មាត្រា ១៦៧.- ការគិតអំពីកម្រិតរយៈពេល**

រយៈពេលប្តឹងការខូចខាតទៅអ្នកដឹកជញ្ជូន ត្រូវគិតពីពេលដែលអ្នកដឹកជញ្ជូនបានប្រគល់ទំនិញ ឬគិតពីថ្ងៃដែលទំនិញត្រូវបានទទួលនៅទីកន្លែងទំនិញទៅដល់ ឬទីកន្លែងដែលបានកំណត់។

ការកំណត់ពេលវេលាច្បាស់លាស់នៅក្នុងកិច្ចសន្យាដឹកជញ្ជូន មិនអាចតិចជាង ៣០ (សាមសិប) ថ្ងៃប្រតិទិននៃថ្ងៃដែលទំនិញមកដល់ទីកន្លែងណាមួយដែលបានកំណត់នៅក្នុងកិច្ចសន្យា។

ប្រសិនបើគ្មានការកំណត់រយៈពេលនៅក្នុងកិច្ចសន្យាដឹកជញ្ជូនទេ រយៈ-ពេល ៣០ (សាមសិប) ថ្ងៃប្រតិទិន ដែលបានចែងក្នុងកថាខ័ណ្ឌខាងលើត្រូវយកមកអនុវត្ត។

**មាត្រា ១៦៨.- សិទ្ធិប្តឹងតតាំងនឹងអ្នកដឹកជញ្ជូនបន្ត ឬផ្សំគ្នា**

ក្នុងករណីដែលមានការដឹកជញ្ជូនទំនិញបន្តឬផ្សំគ្នា ភាគីនៃកិច្ចសន្យាអាចប្តឹងទាមទារឱ្យអ្នកដឹកជញ្ជូនដែលបានចុះកិច្ចសន្យាឬអ្នកដឹកជញ្ជូនចុងក្រោយទទួលខុសត្រូវនូវសកម្មភាពនោះ។

**មាត្រា ១៦៩._ ការទទួលខុសត្រូវរបស់អ្នកដឹកជញ្ជូន**

ក្នុងករណីបាត់បង់ទំនិញ ការទទួលខុសត្រូវរបស់អ្នកដឹកជញ្ជូនមិនអាចលើសពីតម្លៃទំនិញដែលបានប្រកាសដោយអ្នកផ្ញើរឡើយ។

បើសិនតម្លៃទំនិញមិនបានប្រកាស គេត្រូវយកមូលដ្ឋានតម្លៃនៃទំនិញនៅទីកន្លែង និងនៅពេលវេលាផ្ញើរទំនិញ។

**មាត្រា ១៧០._ ឯកសារ និងតម្លៃ**

គ្មានអ្នកដឹកជញ្ជូនណាត្រូវដឹកជញ្ជូនឯកសារ រូបិយប័ណ្ណ ឬទំនិញដែលមានតម្លៃថ្លៃហួសពីការកំណត់ឡើយ ប្រសិនបើមិនបានចែងកាតព្វកិច្ចនោះនៅក្នុងកិច្ចសន្យាដឹកជញ្ជូន។ ប្រសិនបើអ្នកដឹកជញ្ជូនយល់ព្រមដឹកជញ្ជូនទំនិញទាំងនោះ គាត់មិនទទួលខុសត្រូវចំពោះការបាត់បង់ឬខូចខាតទេ លើកលែងតែសភាពឬតម្លៃរបស់ទំនិញត្រូវបានប្រកាស់ឱ្យបានដឹងជាមុន។

ការប្រកាសណាមួយដែលធ្វើឱ្យយល់ច្រឡំទៅលើសភាពនៃទំនិញឬតម្លៃទំនិញត្រូវបានបំបាំង អ្នកដឹកជញ្ជូនត្រូវបានរួចផុតពីការទទួលខុសត្រូវទាំងស្រុង។

**មាត្រា ១៧១._ ទំនិញខុសច្បាប់ឬគ្រោះថ្នាក់**

អ្នកផ្ញើរទំនិញ និងអ្នកដឹកជញ្ជូនមានកាតព្វកិច្ចផ្ទៀងផ្ទាត់ទំនិញដែលត្រូវដឹកជញ្ជូនដូចដែលបានចែងនៅក្នុងកិច្ចសន្យា ដើម្បីបញ្ជាក់ថាទំនិញនោះត្រូវបានអនុញ្ញាតឱ្យដឹកជញ្ជូនត្រឹមត្រូវតាមច្បាប់និងបទដ្ឋានគតិយុត្តដែលនៅជាធរមាន។

អ្នកផ្ញើរទំនិញដាក់ទំនិញដែលគ្រោះថ្នាក់ទៅឱ្យអ្នកដឹកជញ្ជូនដោយមិនបានបង្ហាញទំនិញពិតប្រាកដជាមុន ត្រូវសងទៅអ្នកដឹកជញ្ជូននូវការខាតបង់ឬកម្រៃនៃការរក្សាទំនិញដែលអ្នកដឹកជញ្ជូនរងគ្រោះពីការដឹកជញ្ជូនទំនិញនោះ។

**មាត្រា ១៧២._ សំណង**

អ្នកផ្ញើរទំនិញ ត្រូវសងសំណងខូចខាតទៅអ្នកដឹកជញ្ជូនក្នុងករណីទំនិញខូចស្រាប់ ហើយអ្នកផ្ញើរខកខាន ខ្វះខាតឬមិនបានជូនដំណឹងគ្រប់គ្រាន់ពីសភាពទំនិញនោះ។ ទំនិញខូចស្រាប់គឺទំនិញដែលខូចខាតពីធម្មជាតិរបស់វាឬដោយសារស្ថានភាពទំនិញនោះ។

អ្នកដឹកជញ្ជូននៅតែទទួលខុសត្រូវចំពោះតតិយជនដែលរងគ្រោះអំពីសភាពទំនិញ ការខកខាន ការខ្វះខាតនូវការជូនដំណឹងនោះ។ ប៉ុន្តែបន្ទាប់ពី

អ្នកដឹកជញ្ជូនបានសងទៅតតិយជន អ្នកដឹកជញ្ជូនអាចស្វែងរកសំណងពីអ្នកផ្ញើវិញបាន។

**មាត្រា ១៧៣.- ពេលវេលានៃការបង់ថ្លៃឈ្នួលនៃការផ្ទុក និងដឹកជញ្ជូនទំនិញ**

តម្លៃនៃការផ្ទុក និងដឹកជញ្ជូនទំនិញត្រូវបង់មុនពេលប្រគល់ទំនិញ លើកលែងតែមានការកំណត់នៅក្នុងប័ណ្ណដឹកជញ្ជូន។

ក្នុងករណីផ្សេងទៀត នៅពេលចាប់ផ្ដើមផ្ញើរទំនិញ បើសិនទំនិញមិនពិតដូចបានចែងនៅក្នុងកិច្ចសន្យា ឬតម្លៃទំនិញខ្ពស់ជាងតម្លៃដែលបានបង្ហាញ អ្នកដឹកជញ្ជូន អាចទាមទារតម្លើងតម្លៃដែលគាត់ត្រូវដឹកជញ្ជូនទំនិញនោះ។

**មាត្រា ១៧៤.- ការបង់ថ្លៃឈ្នួលដឹកជញ្ជូន**

នៅពេលដែលតម្លៃនៃការដឹកជញ្ជូនទំនិញត្រូវបានចែងនៅក្នុងកិច្ចសន្យាថាត្រូវបង់នៅពេលប្រគល់ទំនិញ អ្នកដឹកជញ្ជូនទំនិញមិនត្រូវប្រគល់ទំនិញឡើយ បើសិនគាត់មិនទាន់បានទទួលថ្លៃឈ្នួល។

អ្នកផ្ញើរទំនិញត្រូវបង់ថ្លៃឈ្នួល លើកលែងតែមានការកំណត់ផ្សេងនៅក្នុងប័ណ្ណដឹកជញ្ជូនទំនិញ។

**មាត្រា ១៧៥.- សិទ្ធិរបស់អ្នកដឹកជញ្ជូនក្នុងការឃាត់ទុកទំនិញ**

អ្នកដឹកជញ្ជូនអាចឃាត់ទុកទំនិញដែលត្រូវដឹករហូតដល់ថ្លៃឈ្នួលនៃការផ្ទុក ការដឹកជញ្ជូន និងរក្សាទំនិញឱ្យល្អត្រូវបានបង់។

យោងតាមសេចក្ដីណែនាំរបស់អ្នកផ្ញើរពីការបង់ថ្លៃឈ្នួលទាំងនោះដោយអ្នកទទួលទំនិញ ហើយអ្នកដឹកជញ្ជូនមិនបានស្នើរសុំការបង់ថ្លៃឈ្នួលពីអ្នកទទួលទំនិញតាមសេចក្ដីណែនាំទេ គាត់ត្រូវបាត់បង់សិទ្ធិក្នុងការទាមទារការបង់ថ្លៃឈ្នួលពីអ្នកផ្ញើរ។

# ជំពូកទី ១៤
# អន្តរប្បញ្ញត្តិ

## មាត្រា ២២៧.- អន្តរប្បញ្ញត្តិទាក់ទងនឹងតុលាការពាណិជ្ជកម្មនិងសុពលភាពនៃកិច្ចសន្យាពាណិជ្ជកម្ម

ក- បទប្បញ្ញត្តិទូទៅនៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវអនុវត្តចំពោះបណ្តឹងរដ្ឋប្បវេណីដែលទាក់ទងនឹងកិច្ចសន្យាពាណិជ្ជកម្មទាំងអស់ រហូតដល់ច្បាប់ស្តីពីតុលាការពាណិជ្ជកម្មចូលជាធរមាន និងនៅពេលនោះបណ្តឹងដែលទាក់ទងនឹងកិច្ចសន្យាពាណិជ្ជកម្ម ត្រូវតែកំណត់ដោយបទប្បញ្ញត្តិនៃច្បាប់ស្តីពីតុលាការពាណិជ្ជកម្ម។

ខ- អន្តរប្បញ្ញត្តិនៃច្បាប់ស្តីពីតុលាការពាណិជ្ជកម្ម ត្រូវអនុវត្តចំពោះបណ្តឹងដែលកំពង់កើតមានឡើងទាក់ទងនឹងកិច្ចសន្យាពាណិជ្ជកម្ម នៅពេលដែលច្បាប់ស្តីពីតុលាការពាណិជ្ជកម្មចូលជាធរមាន។

គ- កិច្ចសន្យាពាណិជ្ជកម្មដែលបានអនុម័ត បញ្ជាក់ ឬចុះបញ្ជី មុនពេលច្បាប់នេះចូលជាធរមាន ត្រូវរក្សាសុពលភាព និងចងភ្ជាប់កាតព្វកិច្ចចំពោះតតិយជន ផ្អែកតាមរបបតតិយុត្តិដែលអនុវត្តនៅពេលចុះហត្ថលេខា បង្អិលេខ ឬចុះបញ្ជី របស់ពួកគាត់ លើកលែងតែមានបញ្ញត្តិផ្សេងថែងក្នុងច្បាប់ និងបទដ្ឋាននានាដែលនៅជាធរមាន។

ឃ- ទម្រង់នៃលិខិត បង្អិលេខ ឬការចុះបញ្ជីកិច្ចសន្យាពាណិជ្ជកម្មដែលបានអនុម័តឬចុះបញ្ជីមុនពេលច្បាប់នេះចូលជាធរមាន មិនអាចកែប្រែបានឡើយ លើកលេងតែមានបញ្ញត្តិផ្សេងថែងក្នុងច្បាប់ និងបទដ្ឋាននានាដែលនៅជាធរមាន ឬភាគីនៃកិច្ចសន្យាពាណិជ្ជកម្មបានព្រមព្រៀងគ្នា។

ង- ច្បាប់ និងបទដ្ឋាននានាដែលមានមុនពេលច្បាប់នេះបានប្រកាសឱ្យប្រើអាចបន្តអនុវត្តលើកិច្ចសន្យាពាណិជ្ជកម្មនេះបាន។ ប៉ុន្តែ ការធ្វើវិសោធនកម្មកិច្ចសន្យាពាណិជ្ជកម្ម ការបន្ថែមខថែងដែលអនុវត្តដោយភាគីនៃកិច្ចសន្យាពាណិជ្ជកម្មឬកិច្ចសន្យាពាណិជ្ជកម្មដែលធ្វើថ្មីឡើងវិញ

ដោយផ្អែកលើមូលដ្ឋាននៃការអនុវត្តន៍កិច្ចសន្យាពាណិជ្ជកម្ម មុនពេលការប្រកាសឱ្យប្រើច្បាប់នេះ ត្រូវឋិតក្រោមវិសាលភាពនៃច្បាប់នេះ។

## ជំពូកទី ១៥
## អវសានប្បញ្ញត្តិ

### មាត្រា ២២៨._ ការទុកជានិរាករណ៍នូវបទប្បញ្ញត្តិពិសេស

ដើម្បីការពារកិច្ចសន្យាពាណិជ្ជកម្មដែលបានចែងនៅក្នុងមាត្រា ២២៧ កថាខណ្ឌ ង នៃច្បាប់នេះ រាល់បទប្បញ្ញត្តិនៃក្រឹត្យលេខ ៣៨ ស្តីពីកិច្ចសន្យានិងការទទួលខុសត្រូវក្រៅកិច្ចសន្យា និងបទប្បញ្ញត្តិនានាត្រូវទុកជានិរាករណ៍ នៅពេលការប្រកាសឱ្យប្រើច្បាប់នេះ រួមមាននិយមន័យដែលបានចែងនៅក្នុងច្បាប់នេះត្រូវជំនួសនិយមន័យដែលបានចែងនៅក្នុងមាត្រា១ ដល់មាត្រា ៩ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងការចុះបញ្ជី។

### មាត្រា ២២៩._ ការទុកជានិរាករណ៍នូវវិធាននានាដែលវិសមិតភាព

រាល់បទប្បញ្ញត្តិនានាដែលមានតម្លៃគតិយុត្តិស្មើរគ្នា ឬទាបជាង ត្រូវតែជំនួសដោយច្បាប់នេះ បើវាផ្ទុយពីច្បាប់នេះ។